សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Science Economiques

Royal University of Law and Economics


## សារណាបញ្ចប់ការសិក្សា

# លក្ខខណ្ឌនៃការបង្កើតកិច្ចសន្យា

ស្រាវជ្រាវចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **សាយ ប៉ៃឈិញ**

កញ្ញា **ស៊ា ខេមរាវត្តី**

សាស្ត្រាចារ្យណែនាំ

លោក **ហ៊ីង គឹមឡេង**



ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២២

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

# សេចក្ដីថ្លែងអំណរគុណ

ក្រុមសិក្សាស្រាវជ្រាវសារណាយើងខ្ញុំ ដែលជានិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាន់ទី២២ មហាវិទ្យាល័យនីតិសាស្ត្រ ដែលមានសមាជិកពីររូបគឺ៖

១. **លោក សាយ ប៉ៃឈិញ**

២. **កញ្ញា ស៊ា ខេមារត្តី**

## សូមគោរពជូនពរចំពោះ

លោកឪពុក អ្នកម្ដាយ ដែលជាអ្នកមានគុណដ៏លើសលុប ដោយលោកទាំងពីរបានផ្ដល់កំណើត លះបង់ អស់នូវកម្លាំងកាយចិត្ត ពុះពារគ្រប់ឧបសគ្គ នូវចិត្តសន្ដោសប្រណីក្នុងការចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មាន ប្រៀបប្រដៅ និងជួយឧបត្ថម្ភគ្រប់បែបយ៉ាងទាំងស្មារតី ទាំងសម្ភារៈតាំងពីកូននៅកុមារភាព រហូតដល់កូនទាំងអស់គ្នាបានបញ្ចប់បរិញ្ញាប័ត្រ ដោយលោកទាំងពីរខិតខំធ្វើការដោយមិនគិតពីការនឿយហត់របស់លោកទាំងទ្វេឡើយ។

គុណបការៈយ៉ាងធំអនេក និងវិសេសវិសាលនេះធ្វើឱ្យកូនៗចងចាំមិនអាចបំភ្លេចបាននូវការលះបង់របស់លោកមានគុណទាំងពីរដែលជាម្លប់ដ៏ប្រពៃ និងជាម្លប់ដ៏ត្រជាក់ត្រជុំសម្រាប់កូនៗគ្រប់រូបមានទំហំធំធេងគ្មានអ្វីប្រៀបផ្ទឹមបានឡើយ។ ទាំងអស់នេះដែលស្ថិតនៅក្នុងការចងចាំរបស់កូនជានិច្ច និងគ្មានថ្ងៃបំភ្លេចបានដែលស្ថិតក្នុងដួងព្រលឹងកូនជាដរាបគ្មានថ្ងៃសាបសូន្យឡើយ។

ឯកឧត្ដមបណ្ឌិត **លុយ ចណ្ណា** សាកលវិទ្យាធិការ និងលោកសាកលវិទ្យាធិការរង រួមទាំងគណៈគ្រប់គ្រង សាស្ត្រាចារ្យទាំងអស់នៃ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានអនុញ្ញាតឱ្យយើងខ្ញុំទាំងពីរូបបានសិក្សានៅសាកលវិទ្យាល័យនេះ ហើយថែមទាំងយកចិត្តទុកដាក់ ខិតខំអប់រំ និងពង្រឹងវិន័យសាកលវិទ្យាល័យតាំងពីចូលរៀនរហូតមកដល់ការសរសេរនូវសារណាបញ្ចប់បរិញ្ញាប័ត្រ។ ដោយសារតែទីកន្លែងនេះហើយជាថ្នាលបណ្ដុះបណ្ដាលឱ្យយើងខ្ញុំទាំងពីររូបបានសិក្សាស្វែងយល់នូវទិដ្ឋភាពគ្រប់បែបយ៉ាងដែលមានទាំងទិដ្ឋភាពផ្នែកទ្រឹស្ដី និងទិដ្ឋភាពផ្នែកសង្គម ហើយធ្វើឱ្យយើងខ្ញុំទាំងពីររូបបានក្លាយជានិស្សិតល្អ មិត្តភក្ដិល្អ និងពលរដ្ឋល្អក្នុងសង្គមជាតិ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះលោកសាស្ត្រាចារ្យ **ហ៊ីង គឹមឡេង** ដែលបានចំណាយពេលវេលាដ៏មានតម្លៃរបស់លោកផ្ទាល់ក្នុងការដឹកនាំសរសេរសារណា ដោយលោកបានផ្ដល់អនុសាសន៍ល្អៗ និងចំណេះដឹងបន្ថែមប្រកបដោយបទពិសោធន៍ ថែមទាំងជួយកែសម្រួលនូវចំណុចមួយចំនួនលើខ្លឹមសារនៃសារណានេះ យ៉ាងអស់ពីកម្លាំងកាយចិត្ត ប្រាជ្ញាស្មារតី ដោយមិនគិតពីការនឿយហត់ ដោយក្នុងគោលបំណងដើម្បីឱ្យកើតឡើងជាសារណាបញ្ចប់ថ្នាក់បរិញ្ញាប័ត្រប្រកបដោយជោគជ័យ ហើយក៏សូមថ្លែងអំណរគុណដល់លោកសាស្ត្រាចារ្យ **ហ៊ីង គឹមឡេង** ដែលបានផ្ដល់នូវដំបូន្មានដើម្បីលម្អនូវចំណុចខ្វះខាតក្នុងសារណាដល់យើងខ្ញុំទាំងពីរ។

# អារម្ភកថា

ឯកសារដ៏តូចមួយនេះចងក្រងឡើង ដើម្បីជាសក្ខីភាពក្នុងការបញ្ជាក់ពីចំណេះដឹងដែលយើងខ្ញុំទាំងពីររូបមាន និងទទួលបានតាមរយៈការសិក្សារយៈពេល ០៤ ឆ្នាំ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចនេះ។ ហើយឯកសារនេះ គឺស្របនឹងតម្រូវការរបស់សាកលវិទ្យាល័យ ដើម្បីឱ្យនិស្សិតទាំងអស់ចងក្រងជាសារណាមួយច្បាប់ មុននឹងបញ្ចប់ការសិក្សា។ ខណៈនេះយើងខ្ញុំទាំងពីររូប ក៏បានជ្រើសរើសនូវប្រធានបទមួយស្តីអំពី "**លក្ខខណ្ឌនៃការបង្កើតកិច្ចសន្យា**"។

ការជ្រើសរើសប្រធានបទនេះ ដោយយើងខ្ញុំទាំងរូបយល់ឃើញថា តថភាពក្នុងសង្គមខ្មែរនាពេលបច្ចុប្បន្ននេះ គឺមានការកើតឡើងនូវជម្លោះរវាងគូភាគីជាច្រើន ដែលស្តែងឡើងតាមជីវភាពរស់នៅប្រចាំថ្ងៃក៏ដូចជា គ្មានការព្រមព្រៀងទុកជាមុនចំពោះអង្គហេតុណាមួយទេ។ តាមការស្រាវជ្រាវបានបញ្ជាក់ថាទាំងសិស្សនិស្សិត និងប្រជាពលរដ្ឋពុំមានការយល់ដឹងពីបញ្ហានេះឱ្យបានទូលំទូលាយនៅឡើយទេ។ ដូចនេះធ្វើឱ្យមានការលំបាកជាច្រើនក្នុងការស្វែងរកឯកសារ ឱ្យបានត្រឹមត្រូវគ្រប់គ្រាន់ និងសមស្របចំពោះនិស្សិតស្រាវជ្រាវព្រមទាំងអនុវត្តច្បាប់។

ទោះបីជាមានការលំបាកយ៉ាងណាក៏ដោយ យើងខ្ញុំទាំងពីរមិនដែលមានចិត្តបោះបង់ចោលការស្រាវជ្រាវនេះឡើយ ប៉ុន្តែបែរជាជំរុញឱ្យយើងខ្ញុំមានកម្លាំងចិត្តក្នុងការសរសេរ និងការរៀបចំសារណានេះឡើង។ ម្យ៉ាងទៀតតាមរយៈនេះ បានធ្វើឱ្យរូបយើងខ្ញុំទាំងពីរនាក់កាន់តែមានការយល់ដឹងបន្ថែមទៀត អំពីលក្ខខណ្ឌនៃការបង្កើតកិច្ចសន្យា ដែលជាតម្រូវការចាំបាច់ នៅក្នុងការទំនាក់ទំនងរវាងប្រជាពលរដ្ឋក្នុងការប្រកបមុខរបររវាងគ្នា និងគ្នានៅក្នុងសង្គម។

យើងខ្ញុំទាំងពីររូប សង្ឃឹមថាឯកសារមួយនេះនឹងផ្តល់ផលប្រយោជន៍មួយចំនួនដល់មិត្តអ្នកអាន ដែលចង់ស្វែងយល់ពីខ្លឹមសារនៃបញ្ហានាពេលសព្វថ្ងៃ។ ម្យ៉ាងទៀតយើងខ្ញុំ ជឿថាឯកសារនេះពិតជាមានកំហុសឆ្គងដោយអចេតនាណាមួយពុំខាន ដូចនេះយើងខ្ញុំរង់ចាំទទួលរាល់ការរិះគន់ក្នុងន័យស្ថាបនាដើម្បីកែតម្រូវរាល់កំហុសខុសឆ្គងទាំងឡាយដែលធ្វើឱ្យសារណានេះកាន់តែល្អប្រសើរ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........ ១

**ជំពូកទី១**

**ការបង្កើតកិច្ចសន្យា**

**ផ្នែកទី១៖ លក្ខខណ្ឌគ្រឹះ** ........ ២

**១.១ ការព្រមព្រៀង** ........ ២

**១.២.សំណើ** ........ ៣

១.២.១.សំណើមាន ឬ គ្មានកំណត់អំឡុងពេលសម្រាប់ស្វីការ ........ ៤

១.២.២.សំណើមានការកំណត់អំឡុងពេលសម្រាប់ស្វីការ ........ ៤

១.២.៣.សំណើដែលគ្មានកំណត់អំឡុងពេលសម្រាប់ស្វីការ ........ ៤

**១.៣.ករណីលើកលែង: ការជួញដូរអចលនវត្ថុ** ........ ៥

**១.៤.ស្វីការ** ........ ៥

១.៤.១.និយមន័យ ........ ៥

**១.៥.លក្ខខណ្ឌ** ........ ៥

១.៥.១ស្វីការត្រូវធ្វើឡើងដោយអ្នកទទួលសំណើ ........ ៥

១.៥.២.ស្វីការត្រូវតែជូនដំណឹងអ្នកស្នើ ........ ៥

១.៥.៣.ស្វីការត្រូវតែដូចគ្នាទៅនឹងសំណើ ........ ៦

១.៥.៤.ស្វីការត្រូវតែធ្វើមុនពេលកំណត់ ........ ៦

**១.៦. វិធីនៃការធ្វើស្វីការ** ........ ៦

**ផ្នែកទី២៖ លក្ខខណ្ឌទម្រង់** ........ ៦

**២.១.កិច្ចសន្យាផ្ទាល់មាត់** ........ ៦

**២.២.កិច្ចសន្យាជាលាយលក្ខណ៍អក្សរ** ........ ៧

២.២.១.កិច្ចសន្យាឯកជន ឬលិខិតឯកជន ........ ៧

២.២.២.លិខិតឱឡារឹក ឬ លិខិតយថាភូត ........ ៨

# ជំពូកទី២

# មូលដ្ឋានគតិយុត្ត

**ផ្នែកទី១៖ សមត្ថភាពតាមគោលការណ៍គតិយុត្ត** ........ ១០

**១.១.សមត្ថភាពទទួលសិទ្ធិ** ........ ១០

**១.២.សមត្ថភាពខាងឆន្ទៈ** ........ ១១

១.២.១.អានុភាព ........ ១២

**១.៣.សមត្ថភាពក្នុងការធ្វើសកម្មភាព** ........ ១២

១.៣.១អនីតិជន ........ ១៣

១.៣.២.ជននៅក្រោមអាណាព្យាបាលទូទៅ ........ ១៥

១.៣.៣.ជននៅក្រោមហិតូបត្ថម្ភ ........ ១៧

**១.៤.ការការពារភាគីម្ខាងទៀត** ........ ១៨

**១.៥ កម្មវត្ថុ** ........ ១៩

១.៥.១.ភាពខុសច្បាប់ ........ ១៩

១.៥.២.ភាពផ្ទុយនិងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទំលាប់ល្អ ........ ១៩

១.៥.៣.អលទ្ធភាពតាំងពីដំបូង ........ ២០

**១.៦ តម្លៃតបស្នង** ........ ២១

**ផ្នែកទី២៖ វិការៈក្នុងការបង្ហាញឆន្ទៈ** ........ ២២

**២.១.ការភាន់ច្រឡំ** ........ ២២

២.១.១.គោលគំនិត ........ ២២

២.១.២.ការភាន់ច្រឡំអំពីចំណុចកិច្ចសន្យា ........ ២៣

២.១.៣.ការភាន់ច្រឡំទៅលើចំណុចសំខាន់នៃកិច្ចសន្យាដែលភាគីយល់ថាសំខាន់ ........ ២៣

២.១.៤.ការភាន់ច្រឡំដោយភាគីទាំងសងខាង ........ ២៤

២.១.៥ អានុភាពនៃការភាន់ច្រឡំ ........ ២៤

២.១.៦.ការការពារតតិយជន ........ ២៤

**២.២ ការឆបោក** ........ ២៥

២.២.១.គោលគំនិត ........ ២៥

២.២.២.ការឆបោករបស់តតិយជន ........ ២៥

២.២.៣. ការការពារតតិយជន ........ ២៦

**២.៣ ការគំរាមកំហែង** ........ ២៦
២.៣.១.គោលគំនិត ........ ២៦
២.៣.២.ការការពារតតិយជន ........ ២៧
**២.៤.ព័ត៌មានមិនពិត** ........ ២៧
២.៤.១.គោលគំនិត ........ ២៧
២.៤.២.ការការពារតតិយជន ........ ២៨
**២.៥.ការរំលោភលើស្ថានភាព** ........ ២៩
២.៥.១.គោលគំនិត ........ ២៩
២.៥.២.ការការពារតតិយជន ........ ២៩
**២.៦.ការគេចចំណេញហួសហេតុ** ........ ២៩
២.៦.១ គោលគំនិត ........ ២៩
២.៦.២ ការការពារតតិយជន ........ ៣០
**២.៧.ថបនីយផ្លូវចិត្ត** ........ ៣០
២.៧.១.គោលគំនិត ........ ៣០
២.៧.២.ការការពារតតិយជន ........ ៣១
**២.៨.ការបង្ហាញឆន្ទៈមិនពិត** ........ ៣១
២.៨.១.គោលគំនិត ........ ៣១
២.៨.២.ការការពារតតិយជន ........ ៣២
**សេចក្តីសន្និដ្ឋាន** ........ ៣៣
**អនុសាសន៍** ........ ៣៤
**ពន្យល់ពាក្យគន្លឹះ**
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

នៅក្នុងប្រទេសកម្ពុជាយើងសព្វថ្ងៃនេះ ប្រជាពលរដ្ឋទូទៅមិនថាជាអ្នកធ្វើការ ឬ អ្នកប្រកបមុខរបរជួញដូរ ពេលដែលពួកគេចង់សហការ ឬ ទិញទំនិញដោះដូររបស់របរអ្វីមួយគឺពួកគេតែងតែជៀសមិនផុតគឺ "បង្កើតកិច្ចសន្យា" ជាមួយភាគីរបស់ខ្លួនដើម្បីឱ្យភាគីទាំងសងខាងមានជំនឿទុកចិត្តគ្នាមិនមានផលប៉ះពាល់ភាគីណាមួយ ឬ សង្គមនោះឡើយ។ ដោយសារតែសេដ្ឋកិច្ចរបស់ប្រទេសជាតិមានការរីកចម្រើន ទើបបានធ្វើឱ្យប្រជាពលរដ្ឋមានការផ្លាស់ប្តូរ និងចង់បង្កលក្ខណៈងាយស្រួលដល់ការរស់នៅប្រចាំថ្ងៃរបស់ពួកគាត់។ ដើម្បីទទួលបានភាពងាយស្រួល និងមានទំនុកចិត្តរវាងគ្នានិងគ្នា ពួកគាត់បាន "បង្កើតកិច្ចសន្យា" ហើយមានពេលខ្លះគាត់បាន "បង្កើតកិច្ចសន្យា" ដោយមិនដឹងខ្លួនទៀតផង ហើយខ្លះទៀតក៏មិនបានចាប់អារម្មណ៍ថាគាត់កំពុង "បង្កើតកិច្ចសន្យា" ទាំងដែលមិនបានយល់ និងមិនបានដឹងថា កិច្ចសន្យា ជាអ្វីផងដែរ។

យោងតាមតថភាពជាក់ស្តែងយើងឃើញថា ការបង្កើតកិច្ចសន្យា អាចប្រព្រឹត្តទៅបានដោយមានច្រើនទម្រង់ ច្រើនសណ្ឋាន អាស្រ័យលើគូភាគីរៀងៗខ្លួនថាតើភាគីទាំងសងខាងនឹងអាចធ្វើកិច្ចសន្យាប្រភេទអ្វីដើម្បីចងជាកាតព្វកិច្ចអនុវត្តជាមួយគ្នាតែប៉ុណ្ណោះ។ កិច្ចសន្យាមានច្រើនប្រភេទដែលយើងអាចបានដឹង និងបានស្គាល់តាមដែលបានធ្លាប់បានអនុវត្តនៅក្នុងជីវភាពប្រចាំថ្ងៃមានដូចជា "កិច្ចសន្យាលក់-ទិញ" "កិច្ចសន្យាខ្ចីបរិភោគ" និង "កិច្ចសន្យាជួល"ជាដើម រួមទាំងកិច្ចសន្យាផ្សេងៗដែលយើងពុំអាចរៀបរាប់បានអស់សេចក្តី។ យ៉ាងណាមិញក្នុង "លក្ខខណ្ឌនៃការបង្កើតកិច្ចសន្យា" មាននៅក្នុងច្បាប់ "ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧" ។

ដោយសារតែប្រជាពលរដ្ឋយើងសព្វថ្ងៃនេះមិនបានយល់ដឹងពីការបង្កើតកិច្ចសន្យាច្បាស់លាស់នៅឡើយទើបធ្វើឱ្យកិច្ចសន្យាមួយចំនួនបានបង្កើតឡើងហើយតែមិនបានគោរពនូវវិធានក្នុងបទបញ្ញត្តិដែលបានចែងទើបធ្វើឱ្យកិច្ចសន្យានោះមិនអាចអនុវត្តបាន។ ដើម្បីអាចឱ្យកិច្ចសន្យាមួយបង្កើតឡើងនឹងអាចឱ្យភាគីទាំងសងខាងអនុវត្តបានស្របតាមក្រមរដ្ឋប្បវេណីនោះគឺត្រូវយល់ឱ្យបានច្បាស់ពី "លក្ខខណ្ឌនៃការបង្កើតកិច្ចសន្យា"។ ដូចនេះដើម្បីបង្កើតកិច្ចសន្យាមួយឱ្យបានល្អនឹងស្របតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ យើងខ្ញុំនឹងធ្វើការបកស្រាយទៅលើប្រធានបទ "លក្ខខណ្ឌនៃការបង្កើតកិច្ចសន្យា" ដែលត្រូវបកស្រាយមានពីរជំពូកគឺ ជំពូកទី១ស្តីពី ការបង្កើតកិច្ចសន្យា និងជំពូកទី២ សំដៅលើមូលដ្ឋានគតិយុត្ត ។

# ជំពូកទី១

# ការបង្កើតកិច្ចសន្យា

# ជំពូកទី១
# ការបង្កើតកិច្ចសន្យា

កិច្ចសន្យា គឺជាកិរិយាដែលមនុស្សពីរនាក់ ឬច្រើននាក់មានឆន្ទៈត្រូវគ្នាព្រមបង្កើត កែប្រែ ឬ រំលត់នូវកាតព្វកិច្ច[1]។ តាមរយៈការយល់ដឹងរបស់ប្រជាជនមួយចំនួនតែងតែគិតថា គ្រាន់តែការព្រមព្រៀងគ្នារវាងបុគ្គលនិងបុគ្គល នោះអាចបង្កើតបានជាកិច្ចសន្យាបានហើយ។ រីឯមួយចំនួនទៀតបានលើកឡើងថា លុះត្រាតែមានការសរសេរជាលាយលក្ខណ៍អក្សរ មានសាក្សីដឹងលឺទើបកិច្ចសន្យានោះអាចប្រព្រឹត្តទៅបាន។ ការលើកឡើងចំពោះមតិយោបល់ទាំងពីរខាងលើនេះមិនមានមួយណាត្រឹមត្រូវ ឬ មួយណាខុសទេ ព្រោះនៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មិនបានចែងជាលាយលក្ខណ៍អក្សរ ឬ គ្រាន់តែជាការសន្យារវាងបុគ្គលនឹងបុគ្គលទើបអាចយកជាផ្លូវការបាននោះឡើយ។ យ៉ាងណាមិញដើម្បីអាចឱ្យកិច្ចសន្យាមានអានុភាព ត្រូវបំពេញតាមលក្ខខណ្ឌពីរសំខាន់គឺៈ **លក្ខខណ្ឌគ្រឹះ** និង **លក្ខខណ្ឌទម្រង់**។ ជាងនេះទៅទៀតដើម្បីឱ្យកិច្ចសន្យា មានសុពលភាពត្រឹមត្រូវតាមផ្លូវច្បាប់ គេក៏បានចែងនូវចំណុចមួយដែលពាក់ព័ន្ធនឹងបុគ្គលដែលបានចុះកិច្ចសន្យានោះមានដូចជា ឆន្ទៈរបស់បុគ្គល សមត្ថភាព និងកម្មវត្ថុនៃកិច្ចសន្យាជាដើម។ ក្នុងជំពូកទី១នេះ យើងនឹងធ្វើការបែងចែកជាពីរផ្នែកធំ ដែលជាផ្នែកទី១ បកស្រាយអំពីលក្ខខណ្ឌគ្រឹះ រីឯផ្នែកទី២ នឹងធ្វើការបកស្រាយអំពីលក្ខខណ្ឌទម្រង់។

## ផ្នែកទី១ៈ លក្ខខណ្ឌគ្រឹះ

កិច្ចសន្យាដែលបានបង្កើតឡើងហើយ មិនមែនសុទ្ធតែមានសុពលភាពទាំងអស់នោះទេ។ កិច្ចសន្យាដែលអាចយកជាការបាន លុះត្រាតែកិច្ចសន្យានោះស្របទៅតាមលក្ខខណ្ឌសុពលភាពរបស់វាដែលមិនអាចខ្វះមួយណាបានឡើយ ដោយលក្ខខណ្ឌសុពលភាពនៃកិច្ចសន្យានេះមាន ការព្រមពៀងរបស់គូភាគីនៃកិច្ចសន្យា កម្មវត្ថុ និងមូលហេតុកិច្ចសន្យា រួមមានទាំងសមត្ថភាពក្នុងការចុះកិច្ចសន្យា។

### ១.១ ការព្រមព្រៀង

ការព្រមព្រៀងរបស់គូភាគីនៃកិច្ចសន្យាក្នុងការចុះកិច្ចសន្យា គឺត្រូវធ្វើឡើងដោយពិតប្រាកដ និងសេរី គ្មានការបង្ខិតបង្ខំដែលចេញដោយឆន្ទៈពិតប្រាកដរបស់គូភាគីក្នុងការអនុវត្តទៅតាមកិច្ចសន្យានោះ។ ការព្រមព្រៀងនេះអាចកើតឡើងបាននៅពេលដែលភាគីម្ខាងបានធ្វើសំណើ ហើយភាគីម្ខាងទៀតទទួលយកសំណើរ ហើយភាគីម្ខាងតបទៅនឹងសំណើនោះដែលគេហៅថាស្វីការ។

[1] មាត្រា ៣១១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

សរុបមក កិច្ចសន្យាត្រូវមានការត្រូវរ៉ូវគ្នារវាងសំណើ និងស្ទីការរបស់ភាគីម្ខាងៗនៃកិច្ចសន្យា ទើបអាចបង្កើតជាកិច្ចសន្យាបាន។

## ១.២.សំណើ

សំណើ គឺជាការសុំបង្កើតកិច្ចសន្យា ដែលធ្វើឡើងដោយឆន្ទៈជាមួយនឹងចំនងគតិយុត្តក្នុងករណីដែលមានស្ទីការរបស់ភាគីម្ខាងទៀតចំពោះសំណើនេះ។ ដូចនេះយើងអាចអោយនិយមន័យសំណើរថា ជាការស្នើបង្កើតកិច្ចសន្យា។ សំណើរអាចមានទម្រង់ច្រើនដូចជា សំណើអាចធ្វើឡើងដោយជាក់លាក់ ដោយសីតុណ្ហភាព ឬ ដោយប្រាកដប្រជា ។

សំណើជាក់លាក់ សំណើរត្រូវបានសំដែងឡើងតាមរយៈការសរសេរជាលាយលក្ខអក្សរ ឬជាពាក្យសំដី។ តែមានករណីខ្លះ គ្មានការសរសេរជាលាយលក្ខណ៍អក្សរ ឬ ពាក្យសំដីទេ គឺវាសំដែងឡើងដោយកាយវិការ ឬ ការប្រព្រឹត្តដែលគេអាចសន្និដ្ឋានបានថា ជាសំណើច្បាស់លាស់ ដូចជារថយន្តក្រុង តាក់ស៊ីដែលចតនៅចំណតដោយមានអ្នកបើកបរអង្គុយកាច់ចង្កូត ទំនិញដែលដាក់តាំងនៅក្នុងទូរកញ្ចក់ដោយមានកំណត់ពីតម្លៃ ។

សំណើដោយសីតុណ្ហភាព សំដៅលើរាល់សកម្មភាព ឬ អាកប្បកិរិយាដែលមិនបានសំដែងឡើងដើម្បីឱ្យគេដឹងពីឆន្ទៈចុះកិច្ចសន្យា ប៉ុន្តែសកម្មភាព ឬ អាកប្បកិរិយានេះគេសន្មតថា មានឆន្ទៈចុះកិច្ចសន្យា។ សំណើអាចធ្វើទៅកាន់ជនម្នាក់ ឬ ច្រើននាក់ជាកំណត់ ឬ ទៅកាន់សាធារណៈជនក៏បាន ម៉្យាងវិញទៀតសំណើក៏អាចធ្វើឡើងតាមរយៈពេលកំណត់ ឬ គ្មានពេលកំណត់ដែរ ។

សំណើប្រាកដប្រជា សំណើត្រូវតែបង្ហាញឱ្យបានច្បាស់លាស់ថា អ្នកធ្វើសំណើត្រូវបង្ហាញពីឆន្ទៈប្រាកដប្រជា ដើម្បីចុះកិច្ចសន្យា ។

លើសពីនេះ សំណើមានសុពលភាពត្រូវតែបង្ហាញពីបំណងយ៉ាងម៉ឺងម៉ាត់បច្ចុប្បន្នរបស់អ្នកផ្តល់សំណើក្នុងការធ្វើអ្វីមួយ តាមការព្រមព្រៀងដែលភ្ជាប់ទៅដោយកាតព្វកិច្ចតាមផ្លូវច្បាប់ ។

អនុភាពរបស់សំណើ សំណើត្រូវមានអានុភាពនៅពេលដែលសំណើនោះបានមកដល់ភាគីម្ខាងទៀត។ ដើម្បីឱ្យសំណើមានអានុភាពគត្តិយុត្តបាន លុះត្រាតែសំណើនោះត្រូវមានលក្ខណៈជាក់លាក់ និងតឹងរឹងពោលគឺសំដែងឆន្ទៈយ៉ាងពិតប្រាកដរបស់អ្នកស្នើក្នុងការធ្វើកិច្ចសន្យាណាមួយ។ មានន័យថានឹងចាត់សំណើរបានទាល់តែការស្នើនោះមានលក្ខណៈគ្រប់បែបយ៉ាងដែរព្រមព្រៀងទៅនឹងការស្នើខាងលើ និងបានបង្កើតជាកិច្ចសន្យាដោយមិនចាំបាច់មានការពិភាក្សាអ្វីទៀតឡើយ។

**១.២.១.សំណើមាន ឬ គ្មានកំណត់អំឡុងពេលសម្រាប់ស្វីការ**

សំណើ អាចជាសំណើដែលមាន ឬគ្មានកំណត់អំឡុងពេល។

**១.២.២.សំណើមានការកំណត់អំឡុងពេលសម្រាប់ស្វីការ**

សំណើអាចភ្ជាប់ជាមួយនឹងរយៈពេលសម្រាប់ស្វីការ[2]។ ប្រសិនបើវាមិនមានភាពច្បាស់លាស់ថាតើអ្នកស្នើបានកំណត់ថ្ងៃណាមួយនោះទេ នោះវាត្រូវគិតចាប់ពីថ្ងៃដែលសំណើត្រូវបានផ្ញើចេញ។ សំណើនេះត្រូវបានធ្វើឡើងដើម្បីជាប្រយោជន៍របស់អ្នកស្នើខ្លួនឯងផ្ទាល់ ព្រោះអ្នកស្នើអាចធ្វើសំណើនេះទៅបុគ្គលផ្សេងទៀតបាន ប្រសិនបើគាត់មិនបានទទួលស្វីការនៅក្នុងអំឡុងពេលនោះ។ ការកំណត់អំឡុងពេលនេះ គឺដើម្បីបញ្ជាក់អំពីឆន្ទៈរបស់អ្នកស្នើក្នុងការរង់ចាំអឡុងពេលសម្រាប់ស្វីការ ហើយប្រសិនបើអ្នកស្នើអាចដកសំណើនោះនៅពេលដែលគាត់ចង់ដកនោះ អ្នកទទួលសំណើអាចទទួលរងនូវការខូចខាតដែលមិនអាចរំពឹងទុកបាន។ ដូច្នេះ កថាខណ្ឌទី២ នៃមាត្រា៣៣៨ មិនអនុញ្ញាតឱ្យដកសំណើវិញបានទេ។ ប្រសិនបើមិនមានការឆ្លើយតបទៅនឹងសំណើនោះ ឬ ក៏អ្នកធ្វើស្វីការបដិសេធទៅនឹងសំណើនៅក្នុងអំឡុងពេលនោះ សំណើនោះនឹងបាត់បង់អានុភាព[3]។

**១.២.៣.សំណើដែលគ្មានកំណត់អំឡុងពេលសម្រាប់ស្វីការ**

ប្រសិនបើភាគីកំពុងនិយាយចរចាគ្នា ឧទាហរណ៍ដូចជា៖ ភាគីកំពុងនិយាយតទល់មុខគ្នា ឬ និយាយតាមទូរស័ព្ទហើយបើភាគីដែលទទួលសំណើមិនបានឆ្លើយតបភ្លាមៗ ហើយមិនផ្តល់ស្វីការទេ[4] សំណើនោះនឹងបាត់បង់អានុភាព។

ចំពោះសំណើដែលភាគីមិនកំពុងនិយាយគ្នា អ្នកស្នើមិនអាចដកសំណើរបស់ខ្លួនបានទេ ក្នុងអំឡុងពេលមួយដែលសមរម្យ[5]។ អ្នកស្នើអាចដកសំណើរបស់ខ្លួនបាន តែពេលដែលជូនដំណឹងអំពីការដកសំណើបានដល់ភាគីម្ខាងទៀត មុនពេលភាគីម្ខាងទៀតជូនដំណឹងអំពីស្វីការទៅអ្នកស្នើ[6]។

- **អំឡុងពេលសមរម្យ៖** ជាការបកស្រាយផ្អែកតាមស្ថានភាពជាក់ស្តែង ខ្លឹមសារនៃកិច្ចសន្យា និង ទំហំនៃវត្ថុជាដើម។

---

[2] មាត្រា៣៣៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[3] មាត្រា៣៣៨ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[4] មាត្រា៣៣៩ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[5] មាត្រា៣៣៩ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[6] មាត្រា៣៣៨ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

### ១.៣.ករណីលើកលែង: ការជួញដូរអចលនវត្ថុ

កិច្ចសន្យាមានអានុភាពដោយសារសំណើ និង ស្វីការត្រូវគ្នា[7]។ នេះគឺជាគោលការណ៍ទូទៅ។ ក៏ប៉ុន្តែ ទោះបីជាបញ្ញត្តិនៃកថាខណ្ឌទី១ ក្នុងមាត្រា៣៣៦ នេះក៏ដោយ ក៏កិច្ចសន្យាដែលភាគីម្ខាងទទួលករណីកិច្ចធ្វើអនុប្បទាននូវកម្មសិទ្ធិ ឬ ករណីកិច្ចធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុនឹងមានអានុភាព លុះត្រាតែបានធ្វើលិខិតយថាភូត[8]។

មូលហេតុដែលក្រមរដ្ឋប្បវេណីចែងថា លិខិតយថាភូតតម្រូវឱ្យមានក្នុងការធ្វើអនុប្បទានលទ្ធកម្មនៃកម្មសិទ្ធិលើអចលនវត្ថុ គឺមានដូចខាងក្រោម៖

១.ការពារចំពោះអ្នកដែលមានការយល់ដឹងតិចតួចអំពីការផ្ទេរ

២.ការពារចំពោះអ្នកទិញ ឬ អ្នកដែលមានការយល់ដឹងតិចតួច

៣.មធ្យោបាយបង្ហាញភស្តុតាងសម្រាប់បញ្ជាក់ពីអត្ថិភាព និងខ្លឹមសារនៃកិច្ចសន្យា។

### ១.៤.ស្វីការ

#### ១.៣.១.និយមន័យ

ស្វីការ គឺជាការបង្ហាញឆន្ទៈដែលអ្នកទទួលយកសំណើយល់ព្រមចំពោះសំណើនោះ[9]។ មានន័យថា ជាការឆ្លើយតបយល់ព្រមទៅនឹងសំណើក្នុងគោលបំណងដើម្បីបង្កើតកិច្ចសន្យា។ ស្វីការត្រូវមានអានុភាពនៅពេលដែលស្វីការនោះបានដល់អ្នកស្នើ។ ប៉ុន្តែប្រសិនបើដំណឹងអំពីការដកការស្នើការវិញ ដល់អ្នកស្នើ នៅពេលព្រមគ្នានឹងពេលស្វីការដល់ ឬមុនពេលស្វីការដល់នោះអានុភាពនៃស្វីការមិនត្រូវកើតឡើងឡើយ។

### ១.៥.លក្ខខណ្ឌ

#### ១.៥.១ស្វីការត្រូវធ្វើឡើងដោយអ្នកទទួលសំណើ

មានតែអ្នកទទួលសំណើប៉ុណ្ណោះ ទើបអាចធ្វើស្វីការចំពោះសំណើនោះក្នុងគោលបំណងបង្កើតកិច្ចសន្យាមួយបាន។ លើកលែងតែ ការតំណាង ឬជនដែលត្រូវបានកម្រិតសម្ថភាព។

#### ១.៥.២.ស្វីការត្រូវតែជូនដំណឹងអ្នកស្នើ

ស្វីការ ត្រូវមានអានុភាពនៅពេលដែលស្វីការនោះបានដល់អ្នកស្នើ។ កិច្ចសន្យាកើតឡើងនៅពេលដែលសំណើជួបនឹងស្វីការ។ ដូចនេះប្រសិនបើអ្នកទទួលសំណើចង់បង្កើតកិច្ចសន្យា នោះគាត់ត្រូវធ្វើយ៉ាងណាបញ្ជូនស្វីការរបស់គាត់ឱ្យបានទៅដល់ភាគីអ្នកធ្វើសំណើ។

---

[7] មាត្រា៣៣៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[8] មាត្រា៣៣៦ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[9] មាត្រា៣៣៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

### ១.៥.៣.ស្ទីការត្រូវតែដូចគ្នាទៅនឹងសំណើ

ស្ទីការ ដែលអ្នកបានដាក់លើសំណើ ឬកែប្រែសារធាតុផ្សេងនៃសំណើ មិនត្រូវក្លាយជាស្ទីការ សុពលភាព តែស្ទីការនោះមានអានុភាពជាសំណើថ្មី។ កិច្ចសន្យាត្រូវកើតឡើងនៅពេលដែលអ្នកធ្វើសំណើដើមធ្វើស្ទីការចំពោះសំណើថ្មីនោះ។

### ១.៥.៤.ស្ទីការត្រូវតែធ្វើមុនពេលកំណត់

ប្រសិនបើសំណើ ត្រូវបានគេរំលត់ មុនពេលធ្វើស្ទីការកើតឡើងនោះគ្មានសន្យាដែលមានសុពលភាពកើតឡើងនោះទេ។ ដោយហេតុថាកិច្ចសន្យាដែលមានសុពលភាពត្រូវកើតឡើងដោយសារ ការជួបគ្នារវាងសំណើដែលមានសុពលភាព និងស្ទីការដែលមានសុពលភាព។ ប្រសិនបើគូរភាគី កំពុងតែនិយាយទល់មុខគ្នា នោះនឹងមានភាពងាយស្រួលក្នុងការកំណត់ថា ពេលណាសំណើនឹងត្រូវរលត់ តែប្រសិនបើភាគីបានធ្វើទំនាក់ទំនងជាមួយគ្នាពីចម្ងាយ នោះវានឹងមានភាពពិបាកក្នុងការកំណត់ថាពេលណាសំណើនឹងត្រូវរលត់។

អ្នកស្នើ អាចចាត់ទុកថាស្ទីការបានមកដល់អ្នកស្នើ ក្រោយពេលផុតអំឡុងពេលសម្រាប់ស្ទីការ ជាសំណើថ្មី។

### ១.៦. វិធីនៃការធ្វើស្ទីការ

ស្ទីការ អាចត្រូវបានធ្វើឡើងតាមរយៈវិធីជាច្រើនដូចជា៖

-ផ្ទាល់មាត់

-លាយលក្ខណ៍អក្សរ

-អាកប្បកិរិយា

-ប្រព័ន្ធទំនាក់ទំនងសង្គម ទូរស័ព្ទ ទូសារ អ៊ីម៉ែល (Email) ហ្វេសប៊ុក (Facebook) ជាដើម។ល។

## ផ្នែកទី២៖ លក្ខខណ្ឌទម្រង់

ជាគោលការណ៍ កិច្ចសន្យាត្រូវបង្កើតឡើងដោយសំណើត្រូវគ្នាជាមួយស្ទីការ[10]។ ដូច្នេះមានន័យថា កិច្ចសន្យាកើតឡើង ដោយមិនចាំបាច់មានទម្រង់ជាក់លាក់នោះទេ បានសេចក្តីថា កិច្ចសន្យាត្រូវបានបង្កើតឡើងទោះបីជាបានធ្វើផ្ទាល់មាត់ក៏ដោយ។

### ២.១.កិច្ចសន្យាផ្ទាល់មាត់

លិខិតឥតសរសេរ គឺជាកិច្ចសន្យាផ្ទាល់មាត់ ឥតមានសរសេរតាមការព្រមព្រៀងជាលាយលក្ខណ៍អក្សរនោះទេ ឬ ដោយមានការនិយាយព្រមព្រៀងរវាងភាគីនៃកិច្ចសន្យាតែប៉ុណ្ណោះ។ នៅក្នុងជីវភាពប្រចាំថ្ងៃ កិច្ចសន្យាផ្ទាល់មាត់នេះត្រូវបានគេយកមកអនុវត្តជាប្រចាំទៅលើសកម្មភាពតូចតាចនានា ព្រោះកិច្ចសន្យានេះ

[10] មាត្រា ៣៣៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

មានភាពសាមញ្ញ ងាយស្រួល និងឆាប់រហ័សក្នុងការអនុវត្ត។ ប៉ុន្តែកិច្ចសន្យានេះ អាចផ្តល់ភាពលំបាកក្នុងការដោះស្រាយនៅពេលនៅពេលដែលគូភាគីនៃកិច្ចសន្យាមានវិវាទកើតឡើង ដោយសារការធ្វើឡើងដោយផ្ទាល់មាត់មានភាពលំបាកនៅក្នុងការរកភស្តុតាងមកបញ្ជាក់ថា កិច្ចសន្យានោះពិតបានកើយឡើងពិតប្រាកដ ឬយ៉ាងណាហើយក៏ពិបាកក្នុងការរកកំហុសរបស់ភាគីផងដែរ។ ម៉្យាងវិញទៀតនៅក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ ថ្វីបើសំណើ និងស្វីការត្រូវគ្នាអាចបង្កើតជាកិច្ចសន្យាបានក៏ពិតមែន ប៉ុន្តែចំពោះកិច្ចសន្យាមួយចំនួនត្រូវបានធ្វើជាលិខិតយថាភូត ទើបបង្កើតឱ្យកិច្ចសន្យានោះមានសុពលភាព។

ឧទាហរណ៍៖ **ក** ដែលជាអតិថិជន បាននិយាយទៅ **ខ** ដែលជាអ្នកលក់ថា តើអាវមួយនេះមានតម្លៃប៉ុន្មាន? **ខ** បាននិយាយថា អាវមានតម្លៃ ១០០០០៛ (មួយម៉ឺនរៀល) ហើយបន្ទាប់មក **ក** ក៏ប្រគល់លុយ ហើយ **ខ** ក៏ប្រគល់អាវ។

## ២.២.កិច្ចសន្យាជាលាយលក្ខណ៍អក្សរ

យើងសង្កេតឃើញថា កិច្ចសន្យាផ្ទាល់មាត់ងាយនឹងបាត់បង់អានុភាព ដូចនេះក្នុងសកម្មភាពជាក់ស្តែងដើម្បីឱ្យកិច្ចសន្យានឹងអាចជឿជាក់បាន កិច្ចសន្យាភាគច្រើនគេធ្វើឡើងជាលិខិតសរសេរ ឬ ជាលាយលក្ខណ៍អក្សរ។

កិច្ចសន្យាធ្វើឡើងដោយលាយលក្ខណ៍អក្សរនេះ គឺជាកិច្ចសន្យាដែលត្រូវបានសរសេរឡើងដោយគូភាគីនៃកិច្ចសន្យា ដែលជាទូទៅនៅក្នុងកិច្ចសន្យាមានសរសេរកាលបរិច្ឆេទ ស្នាមម្រាមដៃ និងកម្មវត្ថុនៃកិច្ចសន្យាជាដើម ដោយធ្វើឡើងជាទម្រង់លិខិត ០២ (ពីរ) ប្រភេទគឺកិច្ចសន្យាឯកជន ឬលិខិតឯកជន និងលិខិតឱឡារិក ឬ លិខិតយថាភូត (សារការី)។

ឧទាហរណ៍៖ ចំពោះមត៌កសាសន៍ ពុំអាចធ្វើបានឡើយ បើពុំផ្អែកតាមទម្រង់ដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណី។

ឧទាហរណ៍៖ កិច្ចសន្យាគ្រប់ប្រភេទស្តីពីប្រាក់ ឬវត្ថុដែលមានចំនួន ឬតម្លៃលើសពី ៥០០០ (ប្រាំពាន់) រៀល ត្រូវជាលាយលក្ខណ៍អក្សរ។

### ២.២.១.កិច្ចសន្យាឯកជន ឬលិខិតឯកជន

កិច្ចសន្យាឯកជន ឬលិខិតឯកជន គឺជាកិច្ចសន្យាដែលធ្វើឡើងដោយគូរភាគី តាមការព្រមព្រៀងណាមួយដើម្បីបង្កើតឱ្យមានលក្ខណៈគតិយុត្តសមស្របតាមច្បាប់។

កិច្ចសន្យាឯកជន ឬលិខិតឯកជន ជាលិខិតដែលធ្វើតែគ្នាឯង ឥតមានមន្ត្រីរាជការសាធារណៈណាមួយជួយធ្វើការដឹងលឺនោះទេ មានតែហត្ថលេខានៃគូភាគីតែប៉ុណ្ណោះ។ តាមសទ្ទានុក្រមរដ្ឋប្បវេណីលិខិតឯកជន គឺជាលិខិតទាំងឡាយណាដែលបង្កើតឡើងដោយបុគ្គលឯកជន ដោយមានចុះហត្ថលេខា ឬស្នាមមេដៃ។

នៅក្នុងជីវភាពសព្វថ្ងៃ លិខិតឯកជនអាចធ្វើឡើងដោយមេធាវីជាសាក្សី ឬ អ្នកតំណាងឱ្យភាគីនៃកិច្ចសន្យា ដើម្បីឱ្យលិខិតនេះមានកម្រិតនៃការជឿជាក់មួយកម្រិតថែមទៀត។ កិច្ចសន្យាលក់ទិញ អាចធ្វើឡើងដោយផ្ទាល់មាត់បាន តែក៏អាចត្រូវធ្វើតាមលិខិតឯកជនបាន លើកលែងតែកិច្ចសន្យាមួយចំនួនដែលច្បាប់បានកំណត់នៅក្នុងទម្រង់មួយជាក់លាក់ដូចជា៖ កិច្ចសន្យាលក់ទិញអចលនវត្ថុជាដើម ដែលត្រូវធ្វើឡើងតាមទម្រង់ជាលិខិតយថាភូត។

### ២.២.២.លិខិតឱឡារឹក ឬ លិខិតយថាភូត

ទោះជាលិខិតឯកជនមានលក្ខណៈត្រឹមត្រូវមួយអាចជឿជាក់បានមួយកម្រិតបន្ថែមពិតមែនប៉ុន្តែមិនអាចជំនួសដោយលិខិតយថាភូតបាននោះទេ ក្នុងករណីដែលក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានកំណត់ប្រភេទកិច្ចសន្យាណាត្រូវធ្វើឡើងដោយលិខិតយថាភូត។ ពាក្យថាយថាភូត គឺមានន័យថា តាមរឿងដែលកើតឡើងពិតប្រាកដ ដែលមានលក្ខណៈដែលប្រកបដោយទម្រង់ច្បាប់។ លិខិតយថាភូត គឺជាលិខិតដែលធ្វើឡើងតាមរូបមន្តដោយមន្ត្រីសាធារណៈ ដែលត្រូវបានបានអនុញ្ញាតឱ្យប្រតិបត្តិមុខងារនោះ។ តាមន័យចង្អៀត គឺជាលិខិតទាំងឡាយណាដែលរៀបចំដោយសារការី។ លើសពីនេះទៅទៀត យោងតាមមាត្រា៩ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី បានកំណត់លិខិតយថាភូត សំដៅទៅលើលិខិតដែលធ្វើឡើងដោយសារការី ឬលិខិតឯកជនដែលសារការីចុះនិទេស្សថា លិខិតនោះមានភាពត្រឹមត្រូវតាមច្បាប់ ម៉្យាងទៀតចំពោះមាត្រាមួយចំនួនក្នុងក្រមរដ្ឋប្បវេណី លិខិតដែលមន្ត្រីមានសមត្ថកិច្ចធ្វើឡើងដែលមានលក្ខណៈជានីតិវិធីនៃការចុះបញ្ជីក៏ជាលិខិតយថាភូតដែរ។

### គុណសម្បត្តិ និងគុណវិបត្តិនៃទម្រង់ជាលិខិតសរសេរទាំងពីរខាងលើ

ទម្រង់ទាំងពីរនៃកិច្ចសន្យាធ្វើឡើងជាលាយលក្ខណ៍អក្សរនេះ ត្រូវបានយកមកប្រើប្រាស់ចំពោះការព្រមព្រៀងដែលកម្មវត្ថុមានតម្លៃខ្ពស់ និងចំពោះកិច្ចសន្យាមួយចំនួនដែលច្បាប់តម្រូវឱ្យធ្វើជាលាយលក្ខណ៍អក្សរ។ នៅពេលដែលមានវិវាទ ព្រោះមានភស្តុតាង(កិច្ចសន្យា) ដែលធ្វើឱ្យគូភាគីពិបាកក្នុងការបដិសេធពីកំហុសរបស់ខ្លួន។ យ៉ាងណាមិញ កិច្ចសន្យានេះក៏បានផ្តល់ភាពលំបាកមួយចំនួនផងដែរ ដោយសារតែមានភាពស្មុគស្មាញ ចំណាយថវិការ និងពេលវេលាច្រើន ព្រោះជាទូទៅការតាក់តែង និងចងក្រងកិច្ចសន្យានេះឡើង ទាល់តែជាបុគ្គលមានសមត្ថភាពខាងផ្លូវច្បាប់ខ្ពស់ដូចជា៖ មេធាវី សារការី និងបុគ្គលដែលមានចំណេះដឹងច្បាប់ផ្សេងទៀត។

❖ **សម្គាល់**

ប៉ុន្តែក្នុងករណីដែលច្បាប់តម្រូវ កិច្ចសន្យាត្រូវគោរពតាមទម្រង់បែបជាក់លាក់៖

- កិច្ចសន្យាដែលចាំបាច់ត្រូវប្រគល់វត្ថុ (កិច្ចសន្យាភណ្ឌិត)៖កិច្ចសន្យានេះមានសុពលភាពនៅពេលប្រគល់វត្ថុ។

ឧទាហរណ៍៖ កិច្ចសន្យាខ្ចីប្រើ (មាត្រា៦២៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧)

- កិច្ចសន្យាជាលក្ខណៈទម្រង់ (កិច្ចសន្យាឧឡារិក)៖ កិច្ចសន្យានេះមានសុពលភាព នៅពេលធ្វើជាលាយលក្ខណ៍អក្សរ តាមទម្រង់ដែលច្បាប់តម្រូវ។

ឧទាហរណ៍៖ការលក់ទិញ អចលនវត្ថុ (មាត្រា ៣៣៦ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧) ធនលាភសាមយកមួយជីវិត (មាត្រា៧១៩ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧)។

# ជំពូកទី២
# មូលដ្ឋានគតិយុត្ត

# ជំពូកទី២

# មូលដ្ឋានគតិយុត្ត

## ផ្នែកទី១៖ សមត្ថភាពតាមគោលការណ៍គតិយុត្ត

រូបវន្តបុគ្គលទាំងឡាយ នៅពេលដែលមានរូបរាង និងធ្វើទំនាក់ទំនងនៅក្នុងសង្គមនឹងបង្កើតនូវសិទ្ធិ និងកាតព្វកិច្ចដែលជាលក្ខខណ្ឌតម្រូវតាមច្បាប់ ហើយដើម្បីអាចធ្វើបែបនេះបានលុះត្រាតែច្បាប់ទទួលស្គាល់ថាមានសមត្ថភាព។ ជាមួយគ្នានេះ សមត្ថភាពក្នុងការចុះកិច្ចសន្យា ដើម្បីការពារអសមត្ថជនក្នុងការចុះកិច្ចសន្យា កិច្ចសន្យាដែលបានបង្កើតឡើងដោយអសមត្ថជន ដោយមិនមានការយល់ព្រមពីអ្នកគ្រប់គ្រងស្របច្បាប់របស់ជននោះ។ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ បានការពារនូវផលប្រយោជន៍របស់ភាគីនៅក្នុងកិច្ចសន្យាដោយត្រូវបំពេញលក្ខខណ្ឌដែលមាននៅក្នុងច្បាប់ដូចជា សមត្ថភាពរបស់ភាគីនៅក្នុងកិច្ចសន្យា និងដើម្បីការពារពីការវិការៈនៃកិច្ចសន្យាគឺអ្វីដែលសំខាន់បំផុតនៅក្នុងកិច្ចសន្យាគឺ វិការៈក្នុងការបង្ហាញឆន្ទៈនៅក្នុងកិច្ចសន្យា។

សមត្ថភាពតាមផ្លូវច្បាប់ដែលមានកំណត់នៅក្នុងច្បាប់រដ្ឋប្បវេណី ត្រូវបានបែងចែកជា ០៣ (បី) គឺ សមត្ថភាពទទួលសិទ្ធិ សមត្ថភាពនៃឆន្ទៈ និងសមត្ថភាពក្នុងការធ្វើសកម្មភាព៖

### ១.១.សមត្ថភាពទទួលសិទ្ធិ

យោងទៅតាមក្រមរដ្ឋប្បវេណី រូបវន្តបុគ្គលគ្រប់រូបអាចក្លាយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ច[11] បានសេចក្តីថា ក្នុងឋានៈជាមនុស្សដោយមិនរើសអើង ភេទ វណ្ណៈ អាយុ មុខរបរ សាសនាជាអាទិ៍ ឡើយ ដោយគោរពនូវគោលការសមភាពនៃសមត្ថភាពទទួលសិទ្ធិ។ លក្ខណៈសម្បត្តិអាចក្លាយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ចនេះ ត្រូវបានឱ្យឈ្មោះថា «សមត្ថភាពទទួលសិទ្ធិ» កម្មវត្ថុនៃសមត្ថភាពទទួលសិទ្ធិ ក្រៅពីរូបវន្តបុគ្គល គឺជានីតិបុគ្គល[12]។ ជាគោលការណ៍ នៅក្នុងប្រទេសកម្ពុជា ជនបរទេសមានឋានៈអាចទទួលបាននូវសិទ្ធិដូចជាជនជាតិខ្មែរ ជាពិសេសគឺការបង្កើតកិច្ចសន្យាដែលគ្រាន់តែអនុលោមតាមការព្រមព្រៀងរបស់ភាគី និងស្ថិតនៅក្នុងការបកស្រាយច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិផ្សេងនៅក្នុងច្បាប់ ឬ អនុសញ្ញាអន្តរជាតិ ជាអាទិ៍ ដែលជនបរទេសមិនអាចធ្វើបាន ឬ មិនអាចទទួលបាននូវលទ្ធកម្មមួយចំនួន ដូចជា សិទ្ធិនៃកម្មសិទ្ធិចំពោះដីធ្លី ឬ សិទ្ធិធ្វើសកម្មភាពនយោបាយតែប៉ុណ្ណោះ។

[11] មាត្រា៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[12] មាត្រា៤៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

លក្ខខណ្ឌនៃការបង្កើតកិច្ចសន្យាស្របទៅតាមច្បាប់បាន លុះត្រាតែភាគីដែលបានបង្ហាញឆន្ទៈក្នុងការបង្កើតកិច្ចសន្យាតែប៉ុណ្ណោះមានសមត្ថភាពទទួលសិទ្ធិពេញលេញគឺ "នីតិជន"។ មានតែនីតិជនតែប៉ុណ្ណោះដែលមានសិទ្ធគ្រប់គ្រាន់ក្នុងការធ្វើកិច្ចសន្យា។ ប្រសិនបើភាគីណាម្ខាងនៃកិច្ចសន្យាមិនមានសមត្ថភាពទទួលសិទ្ធិនោះទេ នោះកិច្ចសន្យានឹងគ្មានសុពលភាពទេ លើកលែងតែជននោះមានអ្នកតំណាងដែលច្បាប់បានកំណត់ ឬ ទទួលបានអត្តាធីនភាព ដែលកិច្ចសន្យាមានសុពលភាពអាចអនុវត្តបាន។

**១.២.សមត្ថភាពខាងឆន្ទៈ**

សមត្ថភាពខាងឆន្ទៈ គឺសំដៅទៅលើសមត្ថភាពដែលអាចយល់ដឹង និង វិនិច្ឆ័យបានអំពីលទ្ធភាពតាមផ្លូវច្បាប់នៅសកម្មភាពរបស់ខ្លួន[13]។

ការបង្ហាញឆន្ទៈរបស់ភាគីដែលមានបំណងបង្កើតអានុភាពគតិយុត្តហៅថា ការបង្ហាញឆន្ទៈ[14]។ ការបង្ហាញឆន្ទៈ ត្រូវមានអានុភាពចាប់ពីពេលដែលការជូនដំណឹងអំពីការបង្ហាញឆន្ទៈបានដល់ភាគីម្ខាងទៀត[15]។ សកម្មភាព ត្រង់នេះមានន័យថា ជាកិច្ចសន្យា និងសកម្មភាពឯកតោភាគី[16]។ កិច្ចសន្យា ត្រូវបានបង្កើតអានុភាពគតិយុត្តដោយការព្រមព្រៀងរបស់ភាគីនៃកិច្ចសន្យា។ ធាតុផ្សំនៃការព្រមព្រៀងនេះ គឺ "ការបង្ហាញឆន្ទៈ" របស់ភាគីទាំងពីរ។

កិច្ចសន្យា គឺជាកិរិយាដែលមនុស្សពីរនាក់ ឬច្រើននាក់មានឆន្ទៈត្រូវគ្នាព្រមបង្កើត កែប្រែ ឬរំលត់នូវកាតព្វកិច្ច[17]។

សកម្មភាពឯកតោភាគី គឺជាសកម្មភាពដែលបង្កើតកែប្រែ ឬ រំលត់នូវកាតព្វកិច្ចដែលបង្ហាញឆន្ទៈនៃការចាត់ចែងទ្រព្យដោយភាគីម្ខាង ឬដោយអនុវត្តសិទ្ធិដែលទទួលបានតាមរយៈកិច្ចសន្យា ឬ តាមបញ្ញត្តិនៃច្បាប់[18]។ តាមគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន បុគ្គលអាចបង្កើតទំនាក់ទំនងគតិយុត្តរបស់ខ្លួនតាមរយៈសេរីភាពរបស់ខ្លួនបាន។ វាមានភាពចាំបាច់ណាស់សម្រាប់បុគ្គលដែលអាចបង្ហាញឆន្ទៈរបស់ខ្លួនដោយត្រឹមត្រូវ សមត្ថភាពខាងឆន្ទៈត្រូវបានទាញចេញពីគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន។

[13] មាត្រា១៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[14] មាត្រា៣១០ កថាខណ្ឌទី១នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[15] មាត្រា៣១០ កថាខណ្ឌទី២នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[16] មាត្រា១៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[17] មាត្រា៣១១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[18] មាត្រា៣១២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

**១.២.១.អានុភាព**

សកម្មភាពដែលភាគីបានធ្វើនៅក្នុងសកម្មភាព ដែលភាគីបានធ្វើនៅក្នុងស្ថានភាពដែលខ្លួនមិនអាចយល់ដឹង និងវិនិច្ឆ័យបានអំពីលទ្ធផលតាមផ្លូវច្បាប់នូវសកម្មភាពរបស់ខ្លួនអាចលុបចោលបាន[19]។ ជាមួយគ្នានេះផងដែលបុគ្គលម្នាក់ៗមានសេរីភាពនៅក្នុងការបង្ហាញឆន្ទៈ ក៏ប៉ុន្តែដើម្បីឱ្យការបង្ហាញឆន្ទៈនេះប្រព្រឹត្តទៅបានប្រកបដោយប្រសិទ្ធភាព វាមានភាពចាំបាច់ណាស់ដែលពួកគាត់ត្រូវមានសមត្ថភាពដែលអាចយល់ដឹង និង វិនិច្ឆ័យលើលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពដែលខ្លួនបានធ្វើ។ ហើយសកម្មភាពដែលខ្លួនបានធ្វើនោះ ដើម្បីអាចដឹងថា តើបុគ្គលម្នាក់ៗមានសមត្ថភាពខាងឆន្ទៈគឺត្រូវពិនិត្យមើលនូវលក្ខខណ្ឌពីរ (០២) ក្នុងការ វិនិច្ឆ័យគឺ៖

១.តើបុគ្គលនោះអាចយល់ដឹងពីអត្ថន័យតាមផ្លូវច្បាប់នូវសកម្មភាពដែលខ្លួនបានធ្វើដែរឬទេ[20]?

២.តើបុគ្គលនោះអាចវិនិច្ឆ័យពីលទ្ធផលតាមផ្លូវច្បាប់នូវសកម្មភាពរបស់ខ្លួនបានដែរឬទេ[21]?

ប្រសិនបើភាគីណាម្ខាងនៃកិច្ចសន្យាមិនមានសមត្ថភាពខាងឆន្ទៈនោះទេ នោះកិច្ចសន្យានោះមានសុពលភាព តែអាចលុបចោលបាន។

ឧទាហរណ៍៖ ការលុបកិច្ចសន្យាដែលខ្លួនបានចុះហត្ថលេខា ក្នុងស្ថានភាពគ្មានសមត្ថភាពខាងឆន្ទៈ ដោយសារការបរិភោគគ្រឿងស្រវឹងច្រើន ឬ ការប្រើប្រាស់ថ្នាំដែលធ្វើឱ្យមានការថយចុះខ្លាំងនូវសមត្ថភាពក្នុងការវិនិច្ឆ័យនូវសកម្មភាពរបស់ខ្លួន។

**១.៣.សមត្ថភាពក្នុងការធ្វើសកម្មភាព**

ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាបានចែងអំពីរបបសមត្ថភាព ដែលមានគោលបំណងដើម្បីការពារកុំឱ្យមានការខូចខាត ដែលកើតឡើងដោយសារកិច្ចការជំនួញរបស់អ្នកដែលពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការធ្វើសកម្មភាព។ សមត្ថភាពក្នុងការធ្វើសកម្មភាព គឺជាសមត្ថភាពក្នុងការធ្វើកិច្ចសន្យា ឬ សកម្មភាពឯកតោភាគីដែលមិនអាចលុបចោលបានដោយឯកឯង។ ប្រសិនបើភាគីណាម្ខាងនៃកិច្ចសន្យាមិនមានសមត្ថភាពក្នុងការធ្វើសកម្មភាពទេ នោះកិច្ចសន្យាមានសុពលភាពតែអាចលុបចោលបាន។ ជាមួយគ្នានេះផងដែរ លក្ខខណ្ឌនៃការបង្កើតកិច្ចសន្យាភាគីនៅក្នុងកិច្ចសន្យា ជាគោលការណ៍ត្រូវជានីតិជន ប៉ុន្តែមានករណីលើកលែងផងដែរចំពោះអនីតិជន ក្នុងករណីដែលអនីតិជន ទទួលបានអត្ថា

[19] មាត្រា១៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[20] សេចក្តីពន្យល់អំពីក្រមរដ្ឋប្បវេណី ចំណុច២.៣ ទំព័រ១៥ បោះពុម្ពឆ្នាំ២០១៧

[21] សេចក្តីពន្យល់អំពីក្រមរដ្ឋប្បវេណី ចំណុច២.៣ ទំព័រ១៥ បោះពុម្ពឆ្នាំ២០១៧

ធីនភាពដែលត្រូវចាត់ទុកថាទទួលបាននីតិភាព[22]។

ដូច្នេះភាគីនៅក្នុងកិច្ចសន្យាត្រូវតែមានសមត្ថភាពក្នុងការធ្វើសកម្មភាព មិនអាចឱ្យជនដែលច្បាប់បានហាត់ឃាត់ក្នុងការធ្វើសកម្មភាព(កិច្ចសន្យា) មិនអាចក្លាយជាភាគីនៅក្នុងកិច្ចសន្យាឡើយ។

ជនដែលត្រូវបានច្បាប់កម្រិតសមត្ថភាព ត្រូវតែទទួលការអនុញ្ញាត ពីអ្នកមានអំណាចមេបា អ្នកអាណាព្យាបាល ឬហិតូបត្ថម្ភកៈរបស់ជននោះជាមុនសិន ប្រសិនបើមិនទទួលបាននូវការអនុញ្ញាតនោះទេ សកម្មភាពរបស់ជននោះអាចលុបចោលបាន។ ប៉ុន្តែប្រសិនបើនេះតែឱ្យភាគីខាងអសមត្ថជនអាចលុបចោលបានសកម្មភាព ដោយសារអសមត្ថជនដោយមិនមានកម្រិត វាអាចធ្វើឱ្យបាត់បង់ដល់ស្ថិរភាពក្នុងការប្រកបកិច្ចការបាន។ ដូចនេះហើយទើបក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ បានចាត់ថ្នាក់ជនទាំង០៣ (បី) ប្រភេទនេះ ដើម្បីរក្សាតុល្យភាពរវាងការការពារជនដែលត្រូវបានកម្រិតសមត្ថភាព និងរក្សានូវស្ថិរភាពក្នុងការប្រកបកិច្ចការ។

ជនដែលបានកម្រិតសមត្ថភាពមានដូចជា៖

-អនីតិជន

-ជននៅក្រោមអាណាព្យាបាលទូទៅ

-ជននៅក្រោមហិតូបត្ថម្ភ

### ១.៣.១.អនីតិជន

- **គោលគំនិត**

អនីតិជន សំដៅទៅលើជនដែលមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ[23]។

- **សិទ្ធិលុបចោលសកម្មភាព**

សកម្មភាពដែលអនីតិជនបានធ្វើ ដោយមិនបានទទួលការយល់ព្រមពីអ្នកមានសិទ្ធិអំណាចមេបា ឬអ្នកមានអាណាព្យាបាលសម្រាប់អនីតិជនអាចលុបចោលបាន។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយចំពោះសកម្មភាពដែលទទួលសិទ្ធិ ឬ ឱ្យរួចផុតពីកាតព្វកិច្ច ឬសកម្មភាពដែលទាក់ទងទៅនឹងជីវភាពប្រចាំថ្ងៃ។ ដោយសារតែសកម្មភាពទាំងនេះ អនីតិជនពុំមានបាត់បង់នូវផលប្រយោជន៍របស់ខ្លួនទេ ហេតុនេះហើយមិនចាំបាច់ទទួលស្គាល់នូវការលុបចោលទេ។

[22] មាត្រា២២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[23] មាត្រា១៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

-សកម្មភាពទទួលសិទ្ធិ

-សកម្មភាពឱ្យរួចផុតពីកាតព្វកិច្ច

-សកម្មភាពដែលទាក់ទងនឹងសកម្មភាពប្រចាំថ្ងៃ។

- **ការចាត់ចែងទ្រព្យសម្បត្តិដែលអ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនអនុញ្ញាតឱ្យចាត់ចែង**

ការចាត់ចែងទ្រព្យសម្បត្តិដែលអ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនអនុញ្ញាតឱ្យចាត់ចែងដោយកំណត់គោលបំណងក្នុងទំហំនៃគោលបំណងនេះបាន។ ម៉្យាងទៀតអនីតិជនក៏អាចចាត់ចែងទ្រព្យសម្បត្តិដែលអ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនអនុញ្ញាតឱ្យចាត់ចែងដោយមិនកំណត់គោលបណងបានដែរ[24]។

ក្នុងករណីនេះ អ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនបានផ្តល់ទ្រព្យសម្បត្តិដូចជា ប្រាក់ដល់អនីតិជន ដោយមិនបានកំណត់គោលដៅប្រើប្រាស់ ឬសម្រាប់ចាយវាយកំប៉ិកកំប៉ុកប្រចាំថ្ងៃដោយមិនបានកំណត់គោលដៅប្រើប្រាស់ ទោះបីជាអនីតិជនក៏ដោយ ក៏ធ្វើកិច្ចសន្យាសុពលភាពពេញលេញបានដែរប្រសិនបើកិច្ចសន្យានោះស្ថិតក្នុងទំហំដែលអាចបង់តម្លៃបានដោយប្រាក់ដែលបានផ្តល់ឱ្យនោះ។

- **អនីតិជនដែលត្រូវបានអនុញ្ញាតឱ្យប្រកបអាជីវកម្ម**

អនីតិជន ដែលត្រូវបានអនុញ្ញាតឱ្យប្រកបអាជីវកម្មមួយប្រភេទ ឬ ច្រើនប្រភេទពីអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវមានសមត្ថភាពដូចអនីតិជនចំពោះមុខជំនួញនោះ[25]។

ឧទាហរណ៍៖ **ក** មានហាងលក់សម្លៀកបំពាក់មួយកន្លែងនៅភ្នំពេញ ហើយបានឱ្យ **ខ** ដែលជាកូនរបស់គាត់ជួយលក់សម្លៀកបំពាក់ក្នុងហាងនៅពេលដែល **ក** មិននៅ។ ដូចនេះ **ខ** អាចបង្កើតកិច្ចសន្យាដែលមានសុពលភាពមួយ ដោយខ្លួនឯងបាន ដោយហេតុថា **ខ** អាចលក់សម្លៀកបំពាក់ឱ្យទៅអតិថិជនបាន ដែលមកទិញសម្លៀកបំពាក់នៅក្នុងហាងរបស់ **ក** បាន។

ប្រសិនបើដឹងច្បាស់ថា អនីតិជននោះមិនអាចបំពេញកិច្ចការអាជីវកម្មនោះបាន អ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនអាចលុបចោលបាន ឬកម្រិតនូវការអនុញ្ញាតនៃការប្រកបអាជីវកម្មនោះបាន។

[24] មាត្រា១៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[25] មាត្រា២០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

- **អត្តាធីនភាព**

អនីតិជនដែលទទួលបានអត្តាធីនភាព ត្រូវចាត់ទុកថាបានដល់នីតិភាព[26]។ អនីតិជន អាចទទួលបាននូវអត្តាធីនភាព តាមវិធី ២ (ពីរ)យ៉ាងគឺៈ ការដាក់ពាក្យសុំទៅតុលាការ និងការរៀបអាពាហ៍ពិពាហ៍។

ក្នុងករណីដែលអនីតិជនដែលបានដល់អាយុ១៦ (ដប់ប្រាំមួយ)ឆ្នាំ ទ្រទ្រង់ជីវភាពរបស់ខ្លួនឯងដោយឯករាជ្យតុលាការអាចប្រកាសនូវអត្តាធីនភាពស្របនឹងផលប្រយោជន៍របស់អនីតិជននោះ។ ក្នុងករណីនេះ តុលាការត្រូវយោបល់ពីអ្នកមានអំណាចមេបា។

អនីតិជនដែលបានរៀបអាពាហ៍ពិពាហ៍ហើយ ត្រូវទទួលអត្តាធីនភាពដោយមិនចាំបាច់ការមានការប្រកាសពីតុលាការទេ[27]។ ប៉ុន្តែទោះបីជាភាគីលែងលះគ្នាក៏ដោយ ក៏អានុភាពនៃអត្តាធីនភាពមិនត្រូវបានរលត់ឡើយ[28]។ នៅពេលដែលអត្តាធីនភាពកើតឡើងអត្តាធីនភាព គឺអនីតិជនត្រូវបានចាត់ទុកថាបានដល់នីតិភាព។

- **កិច្ចសន្យាការងាររបស់អនីតិជន**

អ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន មិនអាចធ្វើកិច្ចសន្យាការងារជំនួសអនីតិជនបានឡើយ លើកលែងតែអនីតិជននោះបានផ្តល់សច្ចានុម័តលើកិច្ចសន្យានោះ។ ក្នុងករណីដែលយល់ឃើញថា កិច្ចសន្យាការងាររបស់អនីតិជនអាចធ្វើឱ្យខូចប្រយោជន៍ ឬ ស្ថាប័នរដ្ឋបាលអាចរំលាយកិច្ចសន្យានោះឆ្ពោះទៅអនាគតបាន[29]។

អ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន មិនអាចធ្វើកិច្ចសន្យាការងារជំនួសអនិតិជនបានឡើយ ពីព្រោះដើម្បីការពារកុំឱ្យឪពុកម្តាយ កេងប្រវ័ញ្ចកម្លាំងពលកម្មលើអនីតិជន។ ដូចនេះ អនីតិជនត្រូវបង្កើតកិច្ចសន្យាការងារដោយខ្លួនឯង ដោយមានការយល់ព្រមពីអ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន។

### ១.៣.២.ជននៅក្រោមអាណាព្យាបាលទូទៅ

[26] មាត្រា២២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[27] មាត្រា២១ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[28] មាត្រា២១ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[29] មាត្រា២៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

- **គោលគំនិត**

ជននៅក្រោមអាណាព្យាបាលទូទៅ គឺជាជនដែលស្ថិតនៅក្នុងស្ថានភាព ជានិរន្តរ៍ដែលខ្វះសមត្ថភាព ក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់ នៃសកម្មភាពរបស់ខ្លួនដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី។

ដើម្បីក្លាយជាជនក្រោមអាណាព្យាបាលទូទៅពេញច្បាប់ ត្រូវមានលក្ខខណ្ឌ២(ពីរ)យ៉ាងគឺ ការខ្វះស្ថានភាពជានិរន្ត និងការប្រកាសអំពីការចាប់ផ្ដើមពីតុលាការ។

ឧទាហរណ៍៖ ជននៅក្រោមអាណាព្យាបាលទូទៅ គឺជាជនដែលមិនស្គាល់ឈ្មោះខ្លួនឯង គ្រួសារ សាច់ញាតិរបស់ខ្លួន ឬទីកន្លែងដែលខ្លួនបាននឹងកំពុងរស់នៅ ឬជនដែលស្ថិតនៅក្នុងស្ថានភាពជាមនុស្សរុក្ខជាតិជាដើម។

- **ការចាប់ផ្ដើមអាណាព្យាបាលទូទៅ**

ចំពោះជនដែលស្ថិតនៅក្នុងស្ថានភាពជានិរន្តរ៍ ដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យ អំពីលទ្ធភាពតាមផ្លូវច្បាប់របស់ខ្លួនដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតីតុលាការអាចប្រកាសការចាប់ផ្ដើមអាណាព្យាបាលទូទៅបានតាមពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ ញាតិក្នុងដែលស្ថិតក្នុង៤ថ្នាក់ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ហិតូបត្ថម្ភកៈ មេឃុំ ឬ ចៅសង្កាត់នៃលំនៅដ្ឋានរបស់ជននោះ ឬតំណាងអយ្យការ[30]។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលសាមីខ្លួនមិនទាន់ដល់អាយុ១៥(ដប់ប្រាំ)ឆ្នាំនៅពេលដាក់ពាក្យសុំ។

ក្នុងករណីដែលធ្វើការប្រកាសដែលបានកំណត់ក្នុងខាងលើ បើសាមីខ្លួនជាជននៅក្រោមហិតូត្ថម្ភ តុលាការត្រូវលុបចោលការប្រកាសការចាប់ផ្ដើមហិតូត្ថម្ភចំពោះជននោះ[31]។

- **សិទ្ធិលុបចោលសកម្មភាព**

សកម្មភាពរបស់ជននៅក្រោមអាណាព្យាបាលទូទៅ អាចលុបចោលបាន។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះសកម្មភាពដែលទាក់ទងនឹងជីវភាពប្រចាំថ្ងៃ។

សកម្មភាពដែលបានធ្វើឡើង ដោយជននៅក្រោមអាណាព្យាបាលទូទៅ ដោយមានការយល់ព្រមពីអាណាព្យាបាលទូទៅក៏អាចលុបចោលបានដែរ។ ដោយសារតែជននៅក្រោមអាណាព្យាបាលទូទៅជាជនដែលខ្វះសមត្ថភាពខាងឆន្ទៈហេតុនេះហើយ ទោះបីជាអ្នកអាណាព្យាបាលទូទៅបានយល់ព្រមដោយវិនិច្ឆ័យ

[30] មាត្រា២៤ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[31] មាត្រា២៤ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ថាអ្នកនៅក្រោមអាណាព្យាបាលទូទៅនោះមានសមត្ថភាពខាងឆន្ទៈឡើងវិញក៏ដោយ ក៏ប៉ុន្តែអាចបាត់បង់ម្តងទៀតនូវ សមត្ថភាពខាងឆន្ទៈនោះពេលធ្វើសកម្មភាព។

- **ការលុបចោលអាណាព្យាបាលទូទៅ**

បើមូលហេតុដែលបានកំណត់ក្នុងមាត្រា២៤ (ការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ) នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានរលាយ តុលាការត្រូវលុបចោលនូវការប្រកាស ចាប់ផ្តើមអាណាព្យាបាលទូទៅ តាមពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតក្នុង៤ថ្នាក់ អ្នកអាណាព្យាបាល មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬ តំណាងអយ្យការ[32]។

### ១.៣.៣.ជននៅក្រោមហិតូបត្ថម្ភ

- **គោលគំនិត**

ជនស្ថិតនៅក្រោមហិតូបត្ថម្ភ គឺជាជនដែលមានសមត្ថភាពតិចតួចពេកក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនដោយសារមានវិបត្តិនៃបញ្ញាស្មារតី។ ដើម្បីក្លាយជាជននៅក្រោមហិតូបត្ថម្ភពេញច្បាប់ត្រូវមានលក្ខខណ្ឌពីរយ៉ាងគឺ៖ មានសមត្ថភាពតិចតួចពេកក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់របស់ខ្លួនដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី និងការប្រកាសពីតុលាការ។

ឧទាហរណ៍៖ ជនដែលស្ថិតនៅក្រោមហិតូបត្ថម្ភមានដូចជា៖ ជនដែលមានសតិបញ្ញាខ្សោយ មនុស្សចាស់ជរាជាដើម។

ជននៅក្រោមហិតូបត្ថម្ភ មានលក្ខណៈខុសគ្នានឹងជននៅក្រោមអាណាព្យាបាលទូទៅគឺ ជននៅក្រោមហិតូបត្ថម្ភមានស្មារតីតិចតួចក្នុងការយល់ដឹង ក៏ប៉ុន្តែជននៅក្រោមអាណាព្យាបាលទូទៅខ្វះសមត្ថភាពខាងឆន្ទៈជានិរន្តរ៍។

- **ការចាប់ផ្តើមហិតូបត្ថម្ភ**

ចំពោះជនដែលមានសមត្ថភាពតិចតួចពេកក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតីតុលាការអាចប្រកាស ការចាប់ផ្តើមហិតូបត្ថម្ភលើជននោះបាន តាមពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតក្នុង៤ថ្នាក់ អ្នកអាណាព្យាបាល អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាល មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬ តំណាងអយ្យការ។

[32] មាត្រា២៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ក្នុងករណីដែលធ្វើការប្រកាសដែលបានកំណត់ក្នុងមាត្រា២៨ កថាខណ្ឌទី១ ខាងលើនេះ បើសាមីខ្លួនជាជននៅក្រោមអាណាព្យាបាលទូទៅ តុលាការត្រូវលុបចោលការប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅចំពោះជននោះ[33]។

- **សិទ្ធិលុបចោលសកម្មភាព**

លើកលែងតែសកម្មភាពដែលទាក់ទងនឹងជីវភាពប្រចាំថ្ងៃ សកម្មភាពដែលបានធ្វើឡើងដោយជននៅក្រោមហិតូបត្ថម្ភដោយគ្មានការយល់ព្រមពីហិតូបត្ថម្ភកៈ ដូចខាងក្រោមនេះអាចលុបចោលបាន[34]៖

-ការទទួល ឬការប្រើប្រាស់ទុន។

-ការខ្ចីទ្រព្យ ឬការធានា។

-ការធ្វើសកម្មភាពដែលមានគោលបំណងទទួលបាន ឬធ្វើឱ្យបាត់បង់សិទ្ធិដែលទាក់ទងនឹងអចលនវត្ថុ ឬទ្រព្យសម្បត្តិដែលមានសារៈសំខាន់ផ្សេងទៀត។

-ការធ្វើសកម្មភាពបណ្តឹង។

-ការធ្វើប្រទានកម្ម ឬធ្វើកិច្ចសន្យាស្រុះស្រួល ឬកិច្ចសន្យាមជ្ឈត្តកម្ម។

-ការទទួលស្គាល់នូវសន្តតិកម្ម ឬការបោះបង់ចោលនូវសិទ្ធិសន្តតិកម្ម ឬការចែកនូវមរត៌ក។

-ការប្រកែកមិនព្រមទទួលប្រទានកម្ម ឬអច្ច័យទាន ឬការយល់ព្រមទទួលនូវប្រទានកម្ម ឬអច្ច័យទានដែលភ្ជាប់នឹងបន្ទុក។

-ការសាងសង់សំណង់ថ្មី ការសង់ឡើងវិញ ការសង់បន្ថែម ឬការជុសជុលធំ។

-ការធ្វើភតិសន្យា ដែលមានអំឡុងពេលលើសពី៣ឆ្នាំចំពោះដីធ្លី លើសពី២ឆ្នាំចំពោះអាគារ លើសពី៦ខែចំពោះចលនវត្ថុ។

-សកម្មភាពដែលតុលាការបានប្រកាសជាពិសេសថា ចាំបាច់ត្រូវមានការយល់ព្រមពីហិតូបត្ថម្ភកៈតាមពាក្យសុំរបស់ជនដែលអាចសុំតុលាការក្នុងការចាប់ផ្តើមហិតូបត្ថម្ភ។

- **ការលុបចោលហិតូបត្ថម្ភ**

បើមូលហេតុដែលបានកំណត់នៅក្នុងមាត្រា២៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានរលាយ តុលាការត្រូវលុបចោលនូវការប្រកាសចាប់ផ្តើមហិតូបត្ថម្ភតាមពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតក្នុង៤ថ្នាក់

[33] មាត្រា២៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[34] មាត្រា៣០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

អ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកត្រួតពិនិត្យ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ហិតូបត្ថម្ភកៈ អ្នកត្រួតពិនិត្យហិតូបត្ថម្ភកៈ មេឃុំ ឬចៅសង្កាត់នៃលំនោះឋានរបស់ជននោះ ឬតំណាងអយ្យការ[35]។

## ១.៤.ការការពារភាគីម្ខាងទៀត

### ➢ សិទ្ធិដាស់តឿន

កិច្ចសន្យាដែលធ្វើឡើងដោយជនដែលត្រូវបានកម្រិតសមត្ថភាពតែឯង មានសុពលភាពដែរ ប៉ុន្តែអាចលុបចោលបាន ហេតុនេះហើយ ចំពោះភាគីម្ខាងទៀតទំនាក់ទំនងគតិយុត្ត និងមានភាពខុសគ្នាទៅតាមការដែលថា តើភាគីខាងជនដែលត្រូវកម្រិតនូវសមត្ថភាពលុបចោល ឬមិនលុបចោលនូវកិច្ចសន្យានោះ ដូច្នេះនេះ គឺជាស្ថានភាពដែលពុំមានស្ថិរភាពសោះ។ ហេតុនេះហើយ បានជាមាត្រា៣២ នៃក្រមរដ្ឋប្បវេណី បានចែងពីសិទ្ធិដាស់តឿនដល់ភាគីម្ខាងទៀតនៃជនដែលត្រូវកម្រិតនូវសមត្ថភាពដើម្បីធ្វើឱ្យមានការកំណត់ឱ្យបានច្បាស់ពីទំនាក់ទំនងគតិយុត្តនោះឱ្យបានឆាប់រហ័ស ។

យោងតាមមាត្រា ៣២ នៃក្រមរដ្ឋប្បវេណី សិទ្ធិដាស់តឿនមាន ៣ប្រភេទ៖

-ភាគីម្ខាងទៀត អាចធ្វើការដាស់តឿន ចំពោះអ្នកដែលការពារជនដែលត្រូវបានកម្រិតនូវសមត្ថភាពដោយមានរយៈពេល១ខែ សម្រាប់ពិចារណា ដើម្បីធ្វើការផ្តល់ ឬមិនផ្តល់នូវសច្ចានុមតិហើយប្រសិនបើមានចម្លើយទេ ត្រូវចាត់ទុកថាបានផ្តល់សច្ចានុមតិ ។

-ភាគីម្ខាងទៀតអាចធ្វើការដាស់តឿន ឱ្យជននៅក្រោមហិតូបត្ថម្ភទទួលយក សច្ចានុមតិពីហិតូត្ថម្ភក្នុងរយៈពេល១ខែ ដើម្បីធ្វើការផ្តល់ ឬមិនផ្តល់នូវសច្ចានុមតិ ប្រសិនបើមិនមានចម្លើយទេ ត្រូវចាត់ទុកថាជននោះបានលុបចោលសកម្មភាពនោះ ។

-ក្នុងករណីដែលជនដែលត្រូវបានកម្រិតនូវសមត្ថភាពបានក្លាយជាសមត្ថជនវិញ ភាគីម្ខាងទៀតត្រូវដាស់តឿនចំពោះជននោះតែម្តង ដើម្បីធ្វើការផ្តល់ ឬមិនផ្តល់នូវសច្ចានុមតិ ហើយប្រសិនបើមិនមានចម្លើយទេ ត្រូវចាត់ទុកថាបានផ្តល់សច្ចានុមតិ ។

### ➢ ការឆបោករបស់ជនដែលត្រូវបានកម្រិតសមត្ថភាព

ប្រសិនបើជនត្រូវបានកម្រិតសមត្ថភាព បានប្រើប្រាស់មធ្យោបាយបោកប្រាស់ដើម្បីឱ្យគេជឿជាក់ថាខ្លួនជាសមត្ថជន ជននោះមិនអាចលុបចោលសកម្មភាពបានទេ ។ មធ្យោបាយឆបោក ត្រូវបានប្រើដោយទាក់ទងនឹងសមត្ថភាពក្នុងការធ្វើកិច្ចសន្យា ។

[35] មាត្រា៣១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ឧទាហរណ៍៖ អនីតិជនបាននិយាយអះអាងថា ខ្លួនមានអាយុ២០ឆ្នាំហើយ ដោយបានបង្ហាញនូវអត្តសញ្ញាណប័ណ្ណក្លែងក្លាយ នៅពេលដែលធ្វើកិច្ចសន្យា។

## ១.៥ កម្មវត្ថុ

### ១.៥.១.ភាពខុសច្បាប់

យោងតាមមាត្រា ៣៥៤ នៃក្រមរដ្ឋប្បវេណី ទោះបីជាភាគីនៃកិច្ចសន្យា បានធ្វើការបង្ហាញឆន្ទៈដោយគ្មានវិការៈក៏ដោយ ក៏កិច្ចសន្យាត្រូវចាត់ទុកជាមោឃៈ ប្រសិនបើអត្ថន័យនៃកិច្ចសន្យានោះផ្ទុយនឹងបញ្ញត្តិដែលត្រូវអនុវត្តដោយបង្ខំណាមួយ។ បញ្ញត្តិនៃក្រមរដ្ឋប្បវេណីជាធម្មតា គឺជាបញ្ញត្តិដែលមិនអនុញ្ញាតដោយបង្ខំ ហេតុនេះហើយទើបភាគីនៃកិច្ចសន្យាអាចយល់ព្រមពីអ្វីដែលខុសពីបញ្ញត្តិនេះបាន ។

### ១.៥.២.ភាពផ្ទុយនិងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទំលាប់ល្អ

យោងតាមមាត្រា៣៥៤ នៃក្រមរដ្ឋប្បវេណី ទោះបីជាភាគីនៃកិច្ចសន្យា បានធ្វើការបង្ហាញឆន្ទៈដោយគ្មានវិការៈក៏ដោយ ក៏កិច្ចសន្យាត្រូវចាត់ទុកជាមោឃៈប្រសិនបើអត្ថន័យនៃកិច្ចសន្យានោះផ្ទុយ នឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទំលាប់ល្អ ។ ខ្លឹមសារនៃសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទំលាប់ល្អ មិនអាចបញ្ជាក់ឱ្យបានច្បាស់លាស់នៅក្នុងច្បាប់ទេ តែវាត្រូវសម្រេចដោយយុត្តិសាស្ត្រ។

ប្រសិនបើអត្ថន័យនៃកិច្ចសន្យាមានផ្នែកណាមួយដែលផ្ទុយ និងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬ ផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈនិងទំនៀមទំលាប់ល្អ ហើយទោះបីជាទុកផ្នែកផ្សេងទៀត ក៏មិនឱ្យខូចសេចក្តីសង្ឃឹមសមហេតុសមផលរបស់គូភាគីទេនោះ មានតែចំណុចដែលផ្ទុយនិងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទំលាប់ល្អ តែប៉ុណ្ណោះទេដែលត្រូវទុកជាមោឃៈ[36] ។

មោឃៈភាពនៃកិច្ចសន្យាធ្វើឱ្យប៉ះពាល់បុគ្គលជាច្រើនដែលមានផលប្រយោជន៍ ដែលធ្វើសកម្មភាពដោយគិតថា កិច្ចសន្យានោះមានសុពលភាព ដើម្បីកាត់បន្ថយការប៉ះពាល់នៃបញ្ហាមោឃៈភាពឱ្យបានច្រើន វាជាការសមរម្យដែលត្រូវទុកមោឃៈភាពតែផ្នែកដែលផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬ សណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទំនាប់ប៉ុណ្ណោះ ។ មោឃៈភាពនេះត្រូវបានគេហៅថាមោឃៈភាពមួយផ្នែក ។

ទោះបីជាការបង្ហាញឆន្ទៈរបស់ភាគីទាំងពីរត្រូវបានធ្វើដោយគ្មានមូលហេតុនៃមោឃៈភាព ឬ ការលុបចោលក៏ដោយ ក៏កិច្ចសន្យាត្រូវចាត់ទុកជាមោឃៈដែរ ប្រសិនបើអត្ថន័យនៃកិច្ចសន្យាផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬ សណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទំលាប់ល្អ ។ បញ្ញត្តិដែលអនុវត្តដោយបង្ខំ គឺជាបញ្ញត្តិដែលបដិសេធអានុភាពនៃសកម្មភាពដែលផ្ទុយនឹងបញ្ញត្តិនេះ។ បញ្ញត្តិបែបនេះកម្រិតទំហំនៃសេរីភាព

[36] មាត្រា ៣៥៥ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ក្នុងការធ្វើកិច្ចសន្យា ចំពោះចំណុចដែលចែងក្នុងបញ្ញត្តិនោះ។ ហេតុដូច្នេះប្រសិនបើអត្ថន័យនៃកិច្ចសន្យាផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ កិច្ចសន្យានោះត្រូវទុកជាមោឃៈ។

### ១.៥.៣.អលទ្ធភាពតាំងពីដំបូង

ទោះបីជាអត្ថន័យនៃកិច្ចសន្យា មិនអាចសម្រេចបាន តាំងពីពេលដែលបង្កើតកិច្ចសន្យានោះក៏ដោយ ក៏កិច្ចសន្យានោះមិនត្រូវបានចាត់ទុកថាជាមោឃៈ ដោយយកមូលហេតុ អលទ្ធភាពនោះដែរ។ ប៉ុន្តែបញ្ហានេះមិនរារាំងភាគីក្នុងការលុបចោលនូវកិច្ចសន្យា ដោយយកមូលហេតុនៃការភាន់ច្រឡំឡើយ ក្នុងករណីដែលលក្ខខណ្ឌនៃការភាន់ច្រឡំត្រូវបានបំពេញ[37]។

ក្នុងករណីដែលភាគី ម្ខាងគួរតែអាចដឹងថា អត្ថន័យនៃកិច្ចសន្យាមិនអាចសម្រេចតាំងពីដំបូងបាន នាំឱ្យមានការខូចខាតដល់ភាគីម្ខាងទៀតដោយសារការបង្កើតកិច្ចសន្យា ភាគីនោះត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដល់ភាគីម្ខាងទៀត[38]។

អលទ្ធភាពតាំងពីដំបូងមានន័យថា នៅពេលកិច្ចសន្យាត្រូវបានបង្កើតមានភាពច្បាស់លាស់ជាស្ថាពរថា ការអនុវត្តកិច្ចសន្យានេះមិនអាចធ្វើទៅបានទេ។

ឧទាហរណ៍៖ **ក** មានបំណងចង់ចុះកិច្ចសន្យាទិញ-លក់រថយន្តជាមួយនឹង **ខ** តែនៅមុនពេលចុះកិច្ចសន្យាមួយថ្ងៃរថយន្តដែលដែលកម្មវត្ថុនៃការចុះកិច្ចសន្យានោះត្រូវបានចោរលួចយកទៅបាត់។ ក្នុងករណីនេះ **ក** ដែលជាភាគីអ្នកលក់រថយន្តមិនចាំបាច់ទទួលខុសត្រូវពីអលទ្ធភាពក្នុងការអនុវត្តទេ ប៉ុន្តែ **ក** គួរតែដឹងអំពីការលួចរថយន្តនេះ នឹងបានផ្តល់ដំណឹងទៅឱ្យភាគីម្ខាងទៀតនោះមិនចាំបាច់ឱ្យ **ខ** ធ្វើកិច្ចសន្យាដែលគ្មានប្រយោជន៍នោះទេ។

## ១.៦ តម្លៃតបស្នង

តម្លៃតបស្នង[39] គឺជាការចរចារដើម្បីដោះដូរនៅអ្វីដែលមានតម្លៃតាមច្បាប់។ មានន័យថា តម្លៃតបស្នង គឺជាការលះបង់ផលប្រយោជន៍តាមផ្លូវច្បាប់របស់ភាគីនីមួយៗតាមកិច្ចសន្យា។ ដូច្នេះត្រូវតែមានការដូរតែអំណោយមិនមែនជាការចរចារដើម្បីដោះដូរទេ ហើយក៏មិនមែនជាតម្លៃតបស្នងដែរ។ ជាទូទៅវត្ថុខ្លះមានតម្លៃតបស្នងតាមច្បាប់ បើវាតម្រូវអោយភាគីដែលផ្តល់តម្លៃតបស្នងដើម្បី៖

- ធ្វើអ្វីដែលខ្លួនមានកាតព្វកិច្ចតាមច្បាប់និងធ្វើ។
- មិនធ្វើអ្វីដែលខ្លួនមានសិទ្ធិស្របច្បាប់និងធ្វើ។

[37] មាត្រា ៣៥៥ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[38] មាត្រា ៣៥៥ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[39] ឯកសារបណ្តុះបណ្តាលរបស់ ADB មូលដ្ឋានគ្រឹះនៃច្បាប់ពាណិជ្ជកម្ម

ដូចនេះ តម្លៃតបស្នងអាចត្រូវបានដោះដូរក្នុងរូបភាពជាប្រាក់ ទំនិញ សេវាកម្ម ឬជាទ្រព្យផ្សេងៗទៀត។

សរុបសេចក្តីមក ដើម្បីអោយតម្លៃតបស្នងស្របច្បាប់ ភាគីម្ខាងៗនៃកិច្ចសន្យាត្រូវមានការខាតបង់ផលប្រយោជន៍ស្របច្បាប់មួយ ហើយត្រូវទទួលបានផលប្រយោជន៍ស្របច្បាប់មួយវិញ។

ជាទូទៅតុលាការមិនសាកសួរពីភាពសមរម្យនៃតម្លៃតបស្នងទេ ដោយហេតុថាតុលាការមិនចង់ពិនិត្យឱ្យល្អិតល្អន់លើតាវកាលិកតបនោះទេ ពីព្រោះតុលាការមិនចង់រំខានដល់សិទ្ធិរបស់ភាគីម្ខាងថាបានធ្វើកិច្ចសន្យាឆ្លៀតឱកាសដែលភាគីម្ខាងទៀតកំពុងជួបប្រទះការលំបាកខាងផ្នែកសេដ្ឋកិច្ច ឬ ភាពល្ងង់ ឬ ការខ្វះការពិសោធន៍ហើយបានកេងចំណេញ យ៉ាងសន្ធឹកសន្ធាប់ពីកិច្ចសន្យានោះ ភាគីម្ខាងទៀតនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថាការបង្ហាញនោះមានវិការៈ។

នៅពេលចុះកិច្ចសន្យា កាលណាមានភាពខុសគ្នាមិនសមស្របរវាងតម្លៃនៃតាវកាលិក និងតម្លៃ តាវកាលិកតបវិញ ភាគីរងគ្រោះអាចប្តឹងបដិសេធកិច្ចសន្យាបានក្នុងលក្ខណៈដែលខ្លួនពុំដែលមានបំណងធ្វើអំណោយទេនោះ។

តាមរយៈអត្ថបទទាំងពីរខាងលើនេះ អាចបញ្ជាក់យ៉ាងច្បាស់ថា តម្លៃតបស្នង គឺជាធាតុផ្សំមួយដែលធ្វើឱ្យកិច្ចសន្យាមានសុពលភាព។

**ផ្នែកទី២៖ វិការៈក្នុងការបង្ហាញឆន្ទៈ**

ជាទូទៅ កិច្ចសន្យាដែលត្រូវបានបង្កើតឡើងដោយការព្រមព្រៀងរបស់ភាគី មានកម្មវត្ថុស្របច្បាប់ ហើយធ្វើឡើងដោយសមត្ថជន នោះកិច្ចសន្យានឹងមានអានុភាព។ ប៉ុន្តែនៅក្នុងករណីមួយចំនួនកិច្ចសន្យាដែលបានបំពេញគ្រប់លក្ខខណ្ឌខាងលើ នៅតែត្រូវបានគេលុបចោលដោយសារមានវិការៈតាមរូបភាពមួយចំនួន ដូចជា ការភាន់ច្រឡំ ការឆបោក ឬ ការគំរាមកំហែងអំពើកេងយកចំណេញហួសហេតុជាដើម។ សមត្ថភាពដែលមានវិការៈទាំងនេះត្រូវបានគេហៅថា សកម្មភាពដែលអាចលុបចោលបាន។

ក្រមរដ្ឋប្បវេណី ក៏បានបញ្ញត្តអំពីឋបនីយផ្លូវចិត្ត និងការបង្ហាញឆន្ទៈមិនពិតផងដែរ។ នៅក្នុងករណីនៃការបង្ហាញឆន្ទៈមិនពិត និងឋបនីយផ្លូវចិត្ត ការបង្ហាញឆន្ទៈគឺអាចនិយាយបានថាមានវិការៈ ព្រោះវាមិនឆ្លុះបញ្ចាំងពីឆន្ទៈពិតប្រាកដ។ ជាការពិតណាស់ អ្នកបង្ហាញឆន្ទៈរបស់ខ្លួន គឺមានវិការៈ និង ត្រូវបានទុកជាមោឃៈ ព្រោះគាត់បានដឹងថាការបង្ហាញឆន្ទៈមិនអាចលើកឡើងថាការបង្ហាញឆន្ទៈរបស់ខ្លួន គឺមានវិការៈ និងត្រូវបានទុកជាមោឃៈ ព្រោះគាត់បានដឹងថាការបង្ហាញឆន្ទៈរបស់ខ្លួន គឺមិនពិត។

ការបង្ហាញឆន្ទៈរបស់ភាគីទាំងសងខាងត្រូវតែមិនមានវិការៈ។ ការបង្ហាញឆន្ទៈដោយគ្មានវិការៈ គឺជាការបង្ហាញឆន្ទៈដោយគ្មានការភាន់ច្រឡំ គ្មានការឆបោក គ្មានការគម្រាមកំហែង គ្មានការបង្ហាញឆន្ទៈមិនពិត ឬ

គ្មានអំពើឆ្លៀតឱកាសដោយមានគោលបំណងកេងចំណេញហួសហេតុ។ ប្រសិនបើការបង្ហាញឆន្ទៈនោះមានវិការៈ នោះកិច្ចសន្យាមានសុពលភាព តែអាចលុបចោលបាន។ ទន្ទឹមនឹងនេះ នៅក្នុងករណីដែលជននោះបានឃុបឃិតជាមួយភាគីម្ខាងទៀត និង បង្កើតកិច្ចសន្យាមិនពិត នោះពួកគេមិនអាចអះអាងពីសុពលភាពនៃកិច្ចសន្យាបានទេ។ វិការៈនៃការបង្ហាញឆន្ទៈរួមមាន៖

## ២.១.ការភាន់ច្រឡំ

### ២.១.១.គោលគំនិត

ការភាន់ច្រឡំ មានន័យថា នៅក្នុងករណីដែលអ្នកបង្ហាញឆន្ទៈ បានធ្វើការបង្ហាញឆន្ទៈដែលមានលក្ខណៈខុសគ្នាទៅនឹងការបង្ហាញឆន្ទៈពិតរបស់ខ្លួន ហើយគេក៏មិនបានដឹងអំពីភាពខុសគ្នានេះ នៅពេលដែលគេបានធ្វើការបង្ហាញឆន្ទៈឡើយ។

ឧទាហរណ៍៖ **ក** លក់ផ្ទះនៅខេត្តកណ្ដាលទៅឱ្យ **ខ** ប៉ុន្តែ **ខ** បែរជាមានការភាន់ច្រឡំថា **ក** លក់ផ្ទះនៅភ្នំពេញមកឱ្យខ្លួនទៅវិញ។

### ២.១.២.ការភាន់ច្រឡំអំពីចំណុចកិច្ចសន្យា

ក្នុងករណីដែលភាគីមានការភាន់ច្រឡំអំពីចំណុចសំខាន់ៗនៃកិច្ចសន្យា បើភាគីម្ខាងទៀតបានស្ថិតនៅក្នុងស្ថានភាពដែលអាចដឹងអំពីការភាន់ច្រឡំនេះ ភាគីដែលបានភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបានដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ[40]។

ជាការលំបាកក្នុងការកំណត់ចំណុចសំខាន់ៗនៃកិច្ចសន្យា ព្រោះពុំមានច្បាប់ណាមួយចែងមិនបានច្បាស់លាស់អំពីចំណុចសំខាន់នៃកិច្ចសន្យានោះទេ។ វាត្រូវបានសម្រេចដោយការពិចារណាទៅលើខ្លឹមសារនៃកិច្ចសន្យាដែលអាចនិយាយបានថា ប្រសិនបើពួកគាត់ពុំមានការភាន់ច្រឡំនោះទេ គាត់ក៏មិនបង្ហាញឆន្ទៈព្រមព្រៀងដែរ។

លទ្ធភាពនៃការយល់ដឹងរបស់ភាគីម្ខាងទៀត មានសារៈសំខាន់ណាស់ ដើម្បីលុបចោលកិច្ចសន្យាដោយយោងទៅលើការភាន់ច្រឡំ។

ឧទាហរណ៍៖ **ក** មានដីបីកន្លែង ដែលមានទីតាំងទីមួយនៅខេត្តកណ្ដាល ទីតាំងទីពីរនៅខេត្តព្រៃវែង និងទីតាំងទីបីនៅខេត្តកំពង់ស្ពឺ។ **ក** បានយល់ព្រមលក់ទីតាំងទីមួយទៅឱ្យ **ខ** ហើយ **ខ** ព្រមទិញដីនោះដោយគិតថា ដីនោះមានទីតាំងនៅខេត្តព្រៃវែង ដែលជាប់ផ្ទះរបស់ខ្លួន។ ដូចនេះ **ខ** មានការភាន់ច្រឡំ ទៅលើកម្មវត្ថុនៃកិច្ចសន្យាដែលជាចំណុចសំខាន់នៃកិច្ចសន្យា។

[40] មាត្រា៣៤៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

### ២.១.៣.ការភាន់ច្រឡំនៅលើចំណុចសំខាន់នៃកិច្ចសន្យាដែលភាគីយល់ថាសំខាន់

ជាមួយគ្នានេះ បើក្នុងករណីភាគីម្ខាងនៃកិច្ចសន្យាមានការភាន់ច្រឡំអំពីចំណុចសំខាន់ៗ ឬ ចំណុចដែលខ្លួនយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ច បើភាគីម្ខាងទៀតបានស្ថិតនៅក្នុងស្ថានភាពដែលអាចដឹងអំពីភាពសំខាន់នៃចំណុចនេះ និង ការភាន់ច្រឡំរបស់អ្នកបង្ហាញឆន្ទៈនោះ ភាគីដែលបានភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបានដោយហេតុថាការបង្ហាញឆន្ទៈនោះមានវិការៈ[41]។

ចំណុចដែលគូភាគីយល់ឃើញថាសំខាន់នៅក្នុងកិច្ចសន្យានោះ អាចមិនមែនពាក់ព័ន្ធទៅនឹងកម្មវត្ថុចម្បងនៃកិច្ចសន្យា ហើយមិនមែនសំខាន់ទាំងសងខាងនោះទេ គឺវាមានសារៈសំខាន់តែទៅលើភាគីតែម្ខាងប៉ុណ្ណោះ។

ឧទាហរណ៍៖ **ក** ចង់ទិញសៀវភៅដែលនិយាយពីការរកស៊ីជោគជ័យ។ នៅថ្ងៃមួយ **ក** បានទិញសៀវភៅមួយក្បាលមើលពីខាងក្រៅហាក់ដូចជាដែលនិយាយពីភាពរកស៊ីជោគជ័យ ដូចនេះ **ក** ក៏បានសម្រេចចិត្តទិញសៀវភៅនោះមក តែការពិតសៀវភៅនោះមិនមែននិយាយពីការរកស៊ីនោះទេ។ ដូចនេះ **ក** មានការភាន់ច្រឡំទៅលើសៀវភៅដែលនិយាយពីការរកស៊ីជោគជ័យនោះ ដែលគាត់យល់ថាសំខាន់សម្រាប់គាត់។

### ២.១.៤.ការភាន់ច្រឡំដោយភាគីទាំងសងខាង

ប្រសិនបើ ក្នុងករណីដែលភាគីទាំងសងខាងមានការភាន់ច្រឡំអំពីចំណុចសំខាន់ៗនៃកិច្ចសន្យា ឬ ចំណុចនៃកិច្ចសន្យាដែលភាគីទាំងសងខាងយល់ឃើញថាសំខាន់ ឬ ចំណុចដែលភាគីទាំងសងខាងយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា ទោះបីជាភាគីម្ខាងមិនមានលទ្ធភាពអាចដឹងអំពីការភាន់ច្រឡំរបស់ភាគីម្ខាងទៀតក៏ដោយ ក៏ភាគីដែលបានភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបានដែរ ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ [42]។

ភាគីទាំងសងខាងមានការភាន់ច្រឡំដូចនេះភាពចាំបាច់ក្នុងការការពារភាគីម្ខាងទៀត គឺមានកម្រិតទាបដែលខុសពីករណីមានតែ ភាគីម្ខាងមានការភាន់ច្រឡំ។ ដូចនេះ វាមានភាពចាំបាច់ក្នុងការពិចារណាទៅលើលទ្ធភាពក្នុងការយល់ដឹងរបស់ភាគីម្ខាងទៀត។

ឧទាហរណ៍៖ **ក** និង **ខ** បានបង្កើតកិច្ចសន្យាលក់កង់មួយ ដោយពួកគាត់ជឿជាក់ថាជាកង់ថ្មី តែការពិតនោះជាកង់មួយទឹកទៅវិញទេ។ ដូចនេះពួកគាត់មានការភាន់ច្រឡំទាំងសងខាង។

[41] មាត្រា៣៤៦ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[42] មាត្រា៣៤៦ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

### ២.១.៥ អានុភាពនៃការភាន់ច្រឡំ

កិច្ចសន្យាដែលមានការភាន់ច្រឡំ អាចលុបចោលបាន ហើយសកម្មភាពដែលត្រូវបានលុបចោលនោះត្រូវចាត់ទុកជាមោឃៈតាំងពីដំបូង[43]។

### ២.១.៦.ការការពារតតិយជន

យើងអាចកំណត់ចំណាំបានថា ការលុបចោលនូវកិច្ចសន្យាដែលភាន់ច្រឡំ ក្រៅពីភាគីម្ខាងទៀតអាចអះអាងចំពោះតតិយជនបាន ក៏ប៉ុន្តែ ប្រសិនបើតតិយជនជាជនសុចរិត ហើយគ្មានកំហុសអំពីការភាន់ច្រឡំ មិនអាចអះអាងនូវការលុបចោលចំពោះតតិយជននោះបានឡើយ[44] ។

ការការពារតតិយជន គឺមានសារៈសំខាន់ណាស់ដើម្បីការពារដល់ប្រយោជន៍របស់តតិយជន ដែលកើតចេញអំពីការបង្កើតកិច្ចសន្យាដោយមានវិការៈ។

ឧទាហរណ៍៖ **ក** បានលក់កង់ទៅឱ្យ **ខ** បន្ទាប់មក **ខ** ក៏បានលក់កង់ទៅឱ្យ **គ**។ បន្ទាប់មកទៀត **ក** ក៏បានលុបចោលកិច្ចសន្យាជាមួយ **ខ** ដោយហេតុថាមានការភាន់ច្រឡំ។ នៅក្នុងករណីនេះ **គ** ត្រូវបានចាត់ទុកថា បានទិញពី **ខ** ដែលមិនមែនជាកម្មសិទ្ធិ ព្រោះអានុភាពនៃកិច្ចសន្យារវាង **ក** និង **ខ** ត្រូវបានចាត់ទុកជាមោឃៈតាំងពីដំបូង។ **ខ** ត្រូវបង់មូលដ្ឋានតាមផ្លូវច្បាប់ក្នុងការកាន់កាប់កង់នេះ ហើយគាត់ត្រូវប្រគល់កង់នោះមកវិញ។ ប៉ុន្តែវានឹងធ្វើឱ្យប៉ះពាល់ដល់កិច្ចការជំនួញរបស់ **គ** ។ ប្រសិនបើ **គ** គឺជាជនសុចរិត និងគ្មានកំហុស **ក** មិនអាចអះអាងពីអានុភាពនៃការលុបចោលនៃកិច្ចសន្យានោះទេ។

## ២.២ ការឆបោក

### ២.២.១.គោលគំនិត

ការឆបោក មានន័យថា បុគ្គលណាម្នាក់ ឬតតិយជន បានធ្វើឱ្យអ្នកបង្ហាញឆន្ទៈ មានការភាន់ច្រឡំដោយសារមធ្យោបាយឆបោកណាមួយ ហើយអ្នកបង្ហាញឆន្ទៈបានបង្ហាញឆន្ទៈរបស់ខ្លួន ដោយផ្ទុយពីឆន្ទៈពិតប្រាកដរបស់ខ្លួន និងគាត់មិនបានដឹងពីភាពខុសគ្នានោះ នៅពេលដែលគាត់ធ្វើការបង្ហាញឆន្ទៈ។

ការឆបោក មានលក្ខណៈស្រដៀងគ្នាទៅនឹងការភាន់ច្រឡំដែរ ត្រង់ចំណុច ដែលឆន្ទៈពិតប្រាកដ និងការបង្ហាញចេញមកក្រៅមិនត្រូវគ្នា។ ប៉ុន្តែភាពខុសគ្នានេះកើតពិតប្រាកដ និងការបង្ហាញឆន្ទៈចេញមកក្រៅមិនត្រូវគ្នានេះកើតឡើងពីសកម្មភាពឆបោករបស់ភាគីម្ខាងទៀត ឬតតិយជន នៅក្នុងករណីនៃការឆបោក ដែលមានលក្ខណៈខុសគ្នាពីការភាន់ច្រឡំ។

[43] មាត្រា៣៥៨ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[44] មាត្រា៣៤៦ កថាខណ្ឌទី៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

បុគ្គលដែលបានធ្វើការបង្ហាញឆន្ទៈ ដោយសារការឆបោករបស់ភាគីម្ខាងទៀត អាចលុបចោលនូវកិច្ចសន្យាដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ[45]។

ឧទាហរណ៍៖ **អ្នកលក់** បានប្រាប់ **អ្នកទិញ** ថាមានផលិតផលពិសេសមួយដែលនាំចូលមកពីប្រទេសជប៉ុន ប៉ុន្តែផលិតផលនោះ ជាផលិតផលធម្មតាដែលលាយនៅតាមផ្ទះសោះ។ ក្នុងករណីនេះជាការឆបោកដែលប្រព្រឹត្តដោយ **អ្នកលក់** ព្រោះគាត់បានដឹងអំពីប្រភពនៃការផលិតនោះយ៉ាងច្បាស់។

### ២.២.២.ការឆបោករបស់តតិយជន

ប្រសិនបើក្នុងករណីដែលការបង្ហាញឆន្ទៈបានធ្វើឡើងដោយសារតែការឆបោក របស់តតិយជនអ្នកបង្ហាញឆន្ទៈក៏អាចលុបចោលនូវកិច្ចសន្យា ដោយហេតុថាការបង្ហាញឆន្ទៈនោះមានវិការៈ លុះត្រាតែក្នុងករណីដែលភាគីម្ខាងទៀតនៃការបង្ហាញឆន្ទៈនោះបានដឹង ឬ អាចដឹងអំពីការឆបោកនោះ[46]។

ការឆបោកដោយតតិយជន គឺសំដៅទៅលើជន ដែលក្រៅពីភាគីនៃកិច្ចសន្យា បានប្រើមធ្យោបាយឆបោក ដើម្បីធ្វើឱ្យអ្នកបង្ហាញឆន្ទៈមានការភាន់ច្រឡំដោយសារមធ្យោបាយឆបោកនោះ ហើយអ្នកបង្ហាញឆន្ទៈបានបង្ហាញឆន្ទៈរបស់ខ្លួនដោយខុសពីឆន្ទៈពិតប្រាកដរបស់ខ្លួន។

ឧទាហរណ៍៖ **ក** បានប្រាប់ទៅ **ខ** ថា ទីតាំងផ្ទះរបស់ **គ** នឹងមានការអភិវឌ្ឍន៍ដោយមានក្រុមហ៊ុនល្បីមួយនៅក្រៅប្រទេសនឹងមកវិនិយោគ។ គ្រាន់តែលឺ ដូចនេះ **ខ** បានទិញផ្ទះ **ក** ភ្លាមៗ នៅក្នុងករណីនេះដែល **ខ** មានការភាន់ច្រឡំ ដោយសារតែការជឿជាក់លើការឆបោករបស់ **ក** ។ ដូចនេះ **ខ** អាចលុបចោលកិច្ចសន្យាបាន ប្រសិនបើ **គ** បានដឹង ឬអាចដឹងពីការឆបោករបស់ **ក**។

### ២.២.៣. ការការពារតតិយជន

ជាមួយគ្នានេះដែរ ការលុបចោលនូវកិច្ចសន្យាដោយការឆបោក ក្រៅពីភាគីម្ខាងទៀត ក៏អាចធ្វើការអះអាងចំពោះតតិយជនបាន ប៉ុន្តែ ប្រសិនបើតតិយជននោះជាជនសុចរិត ហើយគ្មានកំហុសអំពីការឆបោកមិនអាចអះអាងនូវអានុភាពនៃការលុបចោលចំពោះតតិយជនបានឡើយ[47]។

ឧទាហរណ៍៖ **ក** បានឆបោក **ខ** ឱ្យលក់ទូរស័ព្ទរបស់ខ្លួនក្នុងតម្លៃទាប ហើយ **ក** បានលក់ទូរស័ព្ទនោះ បន្តទៅឱ្យ **គ** ។ បន្ទាប់មក **ខ** ក៏បានដឹងថា **ក** បានឆបោកខ្លួនក៏បានសុំលុបចោលកិច្ចសន្យានោះចោល។

ក្នុងករណីនេះ **ខ** អាចអះអាងពីអានុភាពនៃការលុបចោលចំពោះ **ក** បានដោយយោងទៅលើការឆបោករបស់ **ក** ទើបធ្វើឱ្យ **ខ** បង្ហាញឆន្ទៈក្នុងការលក់ទូរស័ព្ទនេះដែលជាបង្ហាញមានវិការៈ។ ប៉ុន្តែ ប្រសិនបើ **គ** ជាជន

[45] មាត្រា៣៤៧ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[46] មាត្រា៣៤៧ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[47] មាត្រា៣៤៧ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

សុចរិត និងគ្មានកំហុស **ខ** មិនអាចអះអាងពីអានុភាពនៃការលុបចោលនេះចំពោះ **គ** បានទេ។ ដូចនេះ **ខ** មិនអាចទាមទារទូរស័ព្ទពី **គ** ដែលជាជនសុចរិត និងគ្មានកំហុសបានទេ។

## ២.៣ ការគំរាមកំហែង

### ២.៣.១.គោលគំនិត

ការគំរាមកំហែងសំដៅលើករណីដែល អ្នកបង្ហាញឆន្ទៈ បានបង្ហាញឆន្ទៈរបស់ខ្លួន ដែលផ្ទុយនឹងគោលបំណងរបស់ខ្លួន ដោយសារមានការភ័យខ្លាចភាគីម្ខាងទៀត ឬតតិយជន។

បុគ្គលដែលបានបង្ហាញឆន្ទៈដោយសារការគំរាមកំហែងពីសំណាក់ភាគីម្ខាងទៀត ឬ ពីសំណាក់តតិយជន អាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ[48]។

-លក្ខណៈខុសគ្នារបស់ ការភាន់ច្រឡំ ការឆបោក និងការគំរាមកំហែង

- ការភាន់ច្រឡំ៖ អ្នកបង្ហាញឆន្ទៈ បានបង្ហាញឆន្ទៈ ដោយមានការភាន់ច្រឡំ។
- កាឆបោក៖ អ្នកបង្ហាញឆន្ទៈ បានបង្ហាញឆន្ទៈដោយមានការភាន់ច្រឡំ ដែលបង្កឡើងដោយភាគីម្ខាងទៀត ឬតតិយជន។
- ការគំរាមកំហែង៖ អ្នកបានបង្ហាញឆន្ទៈ បានបង្ហាញឆន្ទៈ ដោយគ្មានការភាន់ច្រឡំ ប៉ុន្តែវាផ្ទុយនឹងគោលបំណងរបស់ខ្លួន ដោយសារមានការភ័យខ្លាច ដែលបង្កឡើងដោយភាគីម្ខាងទៀត ឬតតិយជន។

ស្ថានភាពនៃការគៀបសង្កត់ទៅលើឆន្ទៈ ចំណុចនៃការបង្ហាញឆន្ទៈនោះ គឺស្រដៀងគ្នានឹងការរំលោភលើស្ថានភាព និងការកេងយកចំណេញហួសហេតុ។ ប៉ុន្តែ ការរំលោភលើស្ថានភាព និង ការកេងយកចំណេញហួសហេតុ គឺគ្រាន់តែប្រើប្រាស់នូវស្ថានភាពលំបាករបស់អ្នកបង្ហាញឆន្ទៈ ផ្ទុយមកវិញការគំរាមកំហែងគឺខុសគ្នាត្រង់ចំណុចដែលមានការភ័យខ្លាចដោយសារអំពើគំរាមកំហែងរបស់អ្នកគំរាមកំហែង។

ឧទាហរណ៍៖ **ក** ចង់ទិញដីរបស់ **ខ** ប៉ុន្តែ **ខ** ដែលជាម្ចាស់ដីមិនព្រមលក់ដីនោះទៅឱ្យ **ក** ទេ ដោយហេតុថា **ខ** ចង់ទុកដីនេះដើម្បីប្រកបមុខរបរ។ ដោយសារតែ **ក** ពេញចិត្ត និងចង់បានដីនេះពេក ក៏បានគំរាម **ខ** បើមិនព្រមលក់ដីនេះមកឱ្យខ្លួនទេ គាត់នឹងបាញ់សម្លាប់ **ខ** ជាម្ចាស់ដី បន្ទាប់មក **ខ** ដោយមានការភ័យខ្លាចក៏សម្រេចចិត្តលក់ដីទៅឱ្យ **ក** ។

[48] មាត្រា៣៥០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

### ២.៣.២.ការការពារតតិយជន

មិនមានបញ្ញត្តិច្បាប់ សម្រាប់ការពារតតិយជននោះទេ ទោះបីជាជនបានបង្កើតទំនាក់ទំនងកិច្ចសន្យាដោយផ្អែកលើកិច្ចសន្យា ដែលអាចត្រូវបានគេលុបចោលនោះ។ ក្នុងករណីនេះអ្នកបង្ហាញឆន្ទៈ អាចប៉ះពាល់ពីអានុភាពនៃការលុបចោលចំពោះតតិយជនបានទោះបីជាតតិយជននោះគឺជាជនសុចរិតក៏ដោយ។

មូលហេតុនៃមិនមានបញ្ញត្តិសម្រាប់ការពារតតិយជនទាក់ទងនឹងការគំរាមកំហែង គឺថាអ្នកបង្ហាញ ឆន្ទៈបានបង្ហាញឆន្ទៈរបស់ខ្លួនដោយគ្មានការភាន់ច្រឡំ ដែលមានលក្ខណៈខុសពីការភាន់ច្រឡំ ឬការឆបោក ដូច្នេះអ្នកបង្ហាញឆន្ទៈ ត្រូវបានគេការពារច្រើនជាង នៅក្នុងករណីដែរនៃការឆបោក ឬភាន់ច្រឡំ។

## ២.៤.ព័ត៌មានមិនពិត

### ២.៤.១.គោលគំនិត

នៅពេលធ្វើកិច្ចសន្យា បើហេតុដែលបានបង្ហាញដោយភាគីម្ខាងនោះខុសពីការពិត ហើយភាគីម្ខាងទៀតបានបង្ហាញឆន្ទៈដោយជឿជាក់ថា ហេតុទាំងនោះជាការពិត ប៉ុន្តែប្រសិនបើភាគីនោះដឹងថា ហេតុនោះមិនមែនជាការពិត ខ្លួននឹងមិនបង្ហាញឆន្ទៈទេ ភាគីអាចលុបចោលកិច្ចសន្យាបានដោយហេតុថាការបង្ហាញឆន្ទៈនោះមានវិការៈ[49]។

ក្នុងករណីនេះ មិនរារាំងភាគីដែលបានបង្ហាញឆន្ទៈក្នុងការទាមទារសំណងនៃការខូចខាត ពីបុគ្គលដែលបានបង្ហាញការណ៍មិនពិតនោះទេ ក្នុងករណីដែលបុគ្គលនោះមានកំហុស។

ឧទាហរណ៍៖ **ក** ជាអ្នកលក់សម្លៀកបំពាក់ បានប្រាប់ **ខ** ដែលជាភ្ញៀវថាសម្លៀកបំពាក់នេះផលិតអំពីក្រណាត់ល្អប្រណិតដែលផលិតនៅក្នុងប្រទេសថៃ ហើយលក់ក្នុងតម្លៃ១៥០$(មួយរយហុកសិបដុល្លាសហរដ្ឋអាមេរិក) ក្នុងមួយអាវ បន្ទាប់មក **ខ** ក៏សម្រេចចិត្តទិញអាវនោះ តែការពិតអាវនោះ ផលិតពីក្រណាត់ធម្មតាតែប៉ុណ្ណោះ។ ក្នុងករណីនេះ **ខ** អាចលុបចោលកិច្ចសន្យាបានដោយផ្អែកលើព័ត៌មានមិនពិតរបស់ **ក** ព្រោះគាត់មិនបានពិនិត្យក្រណាត់នេះឱ្យបានត្រឹមត្រូវទេ។ ករណីនេះអាចចាត់ទុកថាជាកំហុសរបស់ **ក** ព្រោះគាត់មិនបានពិនិត្យក្រណាត់ឱ្យបានត្រឹមត្រូវ។ ដូចនេះប្រសិនបើ **ខ** ទទួលរងការខូចខាតនោះ **ខ** អាចទាមទារសំណងនៃការខូចខាតពី **ក** បាន។

នៅក្នុងករណីនៃព័ត៌មានមិនពិត គេតម្រូវឱ្យភាគីម្ខាងទៀតមិនបានដឹងហេតុ ដែលគាត់បានលើកឡើងនោះមិនមែនជាការពិត។ ប្រសិនបើគាត់បានដឹងហេតុនោះខុសពីការពិត ត្រូវបានគេទុកជាការឆបោក។

[49] មាត្រា៣៤៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ជាមួយគ្នានេះចំណុចស្តីអំពីការបង្ហាញឆន្ទៈដែលធ្វើឡើងដោយព័ត៌មានមិនពិត គឺមានលក្ខណៈស្រដៀងគ្នាទៅនឹងការឆបោក។ ប៉ុន្តែការឆបោកកើតឡើងតែក្នុងករណីដែលអ្នកផ្តល់ព័ត៌មានមិនពិតមានចេតនាតែប៉ុណ្ណោះ។ ចំណែកព័ត៌មានមិនពិត ទោះបីជាអ្នកបង្ហាញព័ត៌មានមិនពិតនោះគ្មានចេតនា ឬ គ្មានកំហុសក៏ដោយ ក៏កើតមានឡើងដែរ។ មានករណីជាច្រើនដែលព័ត៌មានមិនពិត និង ការឆបោកកើតឡើងទាំងពីរ (០២) ចំពោះករណីបែបនេះ អ្នកបង្ហាញឆន្ទៈអាចលើកយកទាំងពីរ(០២)មកអះអាងបាន។ ចំពោះករណីព័ត៌មានមិនពិតក៏អាចទាមទារសំណងការខូចខាតផងដែរ ដើម្បីលុបចោលដោយផ្អែកតាមព័ត៌មានមិនពិត ពុំចាំបាច់មានកំហុសរបស់អ្នកបង្ហាញព័ត៌មានមិនពិតនោះទេ។ ក្នុងករណីដែលអ្នកបង្ហាញព័ត៌មានមិនពិតមានកំហុស អ្នកបង្ហាញឆន្ទៈអាចទាមទារសំណងការខូចខាតជំនួសការលុបចោល ឬ រួមជាមួយការលលុបចោលក៏បាន[50]។

### ២.៤.២.ការការពារតតិយជន

ការលុបចោលនូវកិច្ចសន្យាដោយព័ត៌មានមិនពិត ក្រៅពីភាគីម្ខាងអាចអះអាងចំពោះតតិយជនបាន។ ប៉ុន្តែ ប្រសិនបើតតិយជនជាជនសុចរិត ហើយគ្មានកំហុសអំពីព័ត៌មាន មិនអាចអះអាងនូវអានុភាពនៃការលុបចោលចំពោះតតិយជននោះបានឡើយ[51]។

## ២.៥.ការរំលោភលើស្ថានភាព

### ២.៥.១.គោលគំនិត

នៅពេលបង្កើតកិច្ចសន្យា បើភាគីម្ខាងនៃកិច្ចសន្យាបានប្រើឋានៈខ្លួនដែលមានអាទិភាពជាងភាគីម្ខាងទៀត ខាងផ្នែកសេដ្ឋកិច្ច ឬ ផ្នែកសង្គម ឬ បានប្រើស្ថានភាពផ្សេងទៀតដែលភាគីម្ខាងទៀត មិនអាចប្រឆាំងតបបានទេ ភាគីម្ខាងទៀតអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈមានវិការៈ[52]។

ការរំលោភបំពានលើស្ថានភាព មានលក្ខណៈស្រដៀងគ្នាទៅនឹង អំពើកេងយកចំណេញហួសហេតុត្រង់ចំណុចដែល ភាគីម្ខាងទៀត បានឆ្លៀតឱកាសមិនត្រឹមត្រូវ នៅពេលមានការលំបាកខាងផ្នែកសេដ្ឋកិច្ច។ ប៉ុន្តែ វាតម្រូវឱ្យភាគីម្ខាងទៀតកេងយកចំណេញយ៉ាងសន្ធឹកសន្ធាប់ពីកិច្ចសន្យា នៅក្នុងករណីនៃអំពើកេងយកចំណេញហួសហេតុ ដែលមានលក្ខណៈខុសគ្នាពីករណីនៃការរំលោភលើស្ថានភាព។

[50] មាត្រា៣៤៨ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[51] មាត្រា៣៤៧ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[52] មាត្រា៣៤៩ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ឧទាហរណ៍៖ **កម្មករ** ម្នាក់ទើបតែទិញចានបុរាណដែលកម្ររកបាន បន្ទាប់មក **ចៅកែ** របស់គាត់បានឃើញចានបុរាណនោះ ហើយក៏ស្រលាញ់ រួចបានប្រាប់ទៅកាន់ **កម្មករ** នោះថា ត្រូវតែលក់ចានបុរាណនោះមកឱ្យខ្លួនក្នុងតម្លៃដើម បើមិនដូច្នេះទេគាត់នឹងបញ្ឈប់ **កម្មករ** នោះពីការងារ។

ចំណុចនៃការប្រើប្រាស់នូវស្ថានភាពលំបាករបស់អ្នកបង្ហាញឆន្ទៈ គឺស្រដៀងគ្នានឹងអំពើកេងចំណេញហួសហេតុ។ ប៉ុន្តែ បើប្រៀបធៀបនឹងកេងចំណេញហួសហេតុ ការរំលោភលើស្ថានភាពមានកម្រិតនៃការគៀបសង្កត់ចំពោះអ្នកបង្ហាញឆន្ទៈខ្លាំងជាងការកេងចំណេញហួសហេតុ។ ម្យ៉ាងទៀតទោះបីជាការរំលោភលើស្ថានភាពមិនទទួលបានចំណេញហួសហេតុក៏ដោយ ក៏អ្នកបង្ហាញឆន្ទៈអាចលុបចោលបានដែរ។

### ២.៥.២.ការការពារតតិយជន

ការលុបចោលកិច្ចសន្យាដោយការរំលោភបំពានលើស្ថានភាពនេះ មិនអាចអះអាងចំពោះ តតិយជនដែលជាជនសុចរិត ហើយគ្មានកំហុសអំពីការរំលោភបំពានលើស្ថានភាពបានឡើយ[53]។

## ២.៦.ការកេងចំណេញហួសហេតុ

### ២.៦.១ គោលគំនិត

ក្នុងករណីភាគីម្ខាងបានធ្វើកិច្ចសន្យាដោយឆ្លៀតឱកាស ដែលភាគីម្ខាងទៀតកំពុងជួបប្រទះការលំបាកខាងផ្នែកសេដ្ឋកិច្ច ឬ ភាពល្ងង់ ឬ ការខ្វះបទពិសោធន៍ ហើយបានកេងចំណេញយ៉ាងសន្ធឹកសន្ធាប់ពីកិច្ចសន្យានោះ ភាគីម្ខាងទៀតនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថាការបង្ហាញ ឆន្ទៈនោះមានវិការៈ[54]។

គោលបំណងក្នុងចំណុចនេះ ចង់ការពារភាគីម្ខាងនៃកិច្ចសន្យា ដូចជាអ្នកប្រើប្រាស់ ពីអ្នកផលិតផលិតផលយ៉ាងច្រើនសន្ធឹកសន្ធាប់ ដែលប៉ុនប៉ងកេងយកចំណេញយ៉ាងសន្ធឹកសន្ធាប់ ដោយឆ្លៀតឱកាសនូវភាពល្ងង់ខ្លៅ ឬខ្វះបទពិសោធន៍របស់អ្នកប្រើប្រាស់។

ឧទាហរណ៍៖ **ក** បានទិញម៉ូតូថ្មីមួយគ្រឿងក្នុងតម្លៃ២០០០$ (ពីរពាន់ដុល្លាសហរដ្ឋអាមេរិក) ប៉ុន្តែប្រពន្ធរបស់ **ក** មានជម្ងឺជាទម្ងន់ដែលធ្វើឱ្យ **ក** ត្រូវការលុយព្យាបាលជម្ងឺ។ ដោយសារឃើញដូច្នេះ **ខ** ចង់ទិញម៉ូតូរបស់ **ក** ក្នុងតម្លៃត្រឹមតែ១០០០$ (មួយពាន់ដុល្លាសហរដ្ឋអាមេរិក) តែប៉ុណ្ណោះ ដោយសារតែ **ក** មិនមានលុយគ្រប់គ្រាន់ក្នុងការព្យាបាលជម្ងឺប្រពន្ធរបស់គាត់ ហើយក៏ត្រូវការលុយជាបន្ទាន់ផងនោះ ក៏បានយល់ព្រមលក់ម៉ូតូទៅឱ្យ **ខ** ក្នុងត្រឹមតែ១០០០$ (មួយពាន់ដុល្លាសហរដ្ឋអាមេរិក)។

[53] មាត្រា៣៤៨ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[54] មាត្រា៣៥១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ជាមួយគ្នានេះ វាស្រដៀងគ្នាដែរនឹងការរំលោភលើស្ថានភាព កម្រិតនៃការគាបសង្កត់លើការបង្ហាញឆន្ទៈនៃអំពើកេងចំណេញហួសហេតុគឺ ទាបជាងការរំលោភលើស្ថានភាព ប៉ុន្តែទោះជាកម្រិតនៃការគៀបសង្កត់លើការបង្ហាញឆន្ទៈនៃអំពើកេងចំណេញហួសហេតុគឺទាបជាងកម្រិតរំលោភលើស្ថានភាពក៏ដោយ ក៏អាចលុបចោលបានដែរ។ ផ្ទុយមកវិញ ក្នុងករណីដែលអ្នកធ្វើអំពើយកចំណេញហួសហេតុបានចំណេញហួសហេតុលុះត្រាតែបានទទួលផលចំណេញហួសហេតុនោះប៉ុណ្ណោះ ទើបអ្នកបង្ហាញឆន្ទៈអាចលុបចោលបាន។

### ២.៦.២ ការការពារតតិយជន

មិនមានបញ្ញត្តិច្បាប់ សម្រាប់ការពារតតិយជននោះទេ ព្រោះនៅក្នុងបញ្ញត្តិនេះសន្មតថា អ្នកបង្ហាញឆន្ទៈ គឺជាសាធារណៈជនដែលប្រើប្រាស់ផលិតផល និងភាគីម្ខាងទៀតជាផលិតករ ដែលផលិតផលក្នុងទ្រង់ទ្រាយធំ។ ដូចនេះវាមិនមានបញ្ញត្តិដើម្បីការពារតតិយជនជនជាងការការពារសាធារណៈជនដែលប្រើប្រាស់ផលិតផលនោះទេ។

## ២.៧.ឋបនីយផ្លូវចិត្ត

### ២.៧.១.គោលគំនិត

បានបង្ហាញនោះ មិនមែនជាឆន្ទៈពិតប្រាកដរបស់ខ្លួនឡើយ ហើយខ្លួននៅតែសម្រេចចិត្តធ្វើការបង្ហាញទៀត។ ឋបនីយផ្លូវចិត្ត គឺជាអ្នកបង្ហាញឆន្ទៈបានដឹងថា ការបង្ហាញឆន្ទៈតាមការជាក់ស្តែងរបស់ខ្លួនមានលក្ខណៈខុសគ្នាទៅនឹងឆន្ទៈពិតប្រាកដរបស់ខ្លួន។ មានន័យថា ភាគីដែលបង្ហាញឆន្ទៈ បានដឹងយ៉ាងពិតប្រាកដថាការបង្ហាញឆន្ទៈដែរ។

ឧទាហរណ៍៖ **ក** បានប្រាប់ទៅ **ខ** ថាគាត់ចង់ទិញដីមួយហិកតារបស់ **ខ** នៅខេត្តបន្ទាយមានជ័យ ក្នុងតម្លៃ ១០០០០$ (មួយម៉ឺនដុល្លាសហរដ្ឋអាមេរិក) តែតាមពិត **ក** មិនចង់ទិញដីរបស់ **ខ** ឡើយ។ ក្នុងករណីនេះ ប្រសិនបើ **ខ** យល់ព្រមលក់ដីទៅឱ្យ **ក** នោះ **ក** នឹងបានបង្កើតកិច្ចសន្យាដែលមានសុពលភាពមួយជាមួយ **ខ** ក៏ត្រូវបង់ប្រាក់ទៅឱ្យ **ខ**។

### ២.៧.២.ការការពារតតិយជន

ប្រសិនបើកិច្ចសន្យាត្រូវបានបង្កើតឡើង ដោយការបង្ហាញឆន្ទៈដែលភាគីដឹងខ្លួនថាខុសឆន្ទៈពិតរបស់ខ្លួនកិច្ចសន្យានោះមិនត្រូវរារាំងនូវអានុភាពឡើយ។ ព្រោះភាគីម្ខាងទៀតមិនបានដឹងថាតើអ្នកបង្ហាញឆន្ទៈបានបង្ហាញឆន្ទៈពិតប្រាកដដែរឬទេ។ ដូចនេះមិនចាំបាច់ការពារអ្នកបង្ហាញឆន្ទៈដោយដឹងថាការបង្ហាញឆន្ទៈនោះមិនមែនជាឆន្ទៈរបស់ខ្លួនពិតប្រាកដឡើយ។

ទោះបីជាមិនមានបញ្ញត្តិច្បាប់ សម្រាប់ការពារតតិយជនក្នុងចំណុចនេះក៏ដោយ ក៏ត្រូវតែការពារតតិយជនដែរ ព្រោះថាកិច្ចសន្យាមានអានុភាពទៅហើយដូចនេះត្រូវតែការពារតតិយជនដែលមានផលប្រយោជន៍ទាក់ទងនឹងកិច្ចសន្យានេះ។

ឧទាហរណ៍៖ **ក** បានប្រាប់ទៅ **ខ** ថា គាត់ចង់ទិញផ្ទះរបស់ **ខ** ដែលមានទីតាំងនៅក្រុងតាខ្មៅ ក្នុងតម្លៃ ១០០០០០$ (ដប់ម៉ឺនដុល្លាសហរដ្ឋអាមេរិក) តែតាមពិតទៅ **ក** មិនចង់ទិញផ្ទះរបស់ **ខ** ឡើយ។ បន្ទាប់មក **ក** ក៏បានទិញផ្ទះនោះ ហើយ **ក** បានលក់ផ្ទះនៅទៅឱ្យ **គ**។ ដូចនេះ **ក** មិនអាចលុបចោល ឬទាមទារផ្ទះពី **គ** បានឡើយ ដោយហេតុថា កិច្ចសន្យារវាង **ក** និង **ខ** គឺជាកិច្ចសន្យាមានសុពលភាព ដូចនេះកិច្ចសន្យាដែល **ក** បានធ្វើជាមួយ **គ** ក៏ជាកិច្ចសន្យាមានសុពលភាពដែរ។

ក្នុងករណីដែល ភាគីម្ខាងទៀតក៏ដឹងថាការបង្ហាញឆន្ទៈនោះខុសនឹងឆន្ទៈពិតរបស់អ្នកបង្ហាញឆន្ទៈដែរ អ្នកបង្ហាញឆន្ទៈនោះអាចបដិសេធការអនុវត្តកិច្ចសន្យានោះបាន។ ក្នុងករណីនេះកិច្ចសន្យាត្រូវបានបង្កើតឡើងដោយមានសុពលភាព ប៉ុន្តែការណ៍ដែលភាគីម្ខាងទៀតបានដឹងថា ការបង្ហាញឆន្ទៈខុសពីឆន្ទៈរបស់អ្នកបង្ហាញនោះត្រូវចាត់ទុកថាជាការតវ៉ា ដូចនេះ អ្នកបង្ហាញឆន្ទៈដែលចង់បដិសេធការអនុវត្តកាតព្វកិច្ចរបស់ខ្លួនចាំបាច់ត្រូវបង្ហាញពីភាពទុច្ចរិតរបស់ភាគីម្ខាងទៀត។

## ២.៨.ការបង្ហាញឆន្ទៈមិនពិត

### ២.៨.១.គោលគំនិត

ការបង្ហាញឆន្ទៈមិនពិត គឺជាការបង្ហាញឆន្ទៈខុសពីការពិត ដែលបានធ្វើឡើងដោយការឃុបឃិតជាមួយភាគីម្ខាងទៀត។

កិច្ចសន្យាដោយផ្អែកលើការបង្ហាញឆន្ទៈមិនពិត ត្រូវបានធ្វើឡើងដោយការឃុបឃិតជាមួយនឹងភាគីម្ខាងទៀតត្រូវចាត់ទុកជាមោឃៈ[55]។

ឧទាហរណ៍៖ **ក** ជំពាក់ប្រាក់ **ខ** ចំនួន១០០០០$ (មួយម៉ឺនដុល្លាសហរដ្ឋអាមេរិក) ហើយ **ខ** មានផ្ទះមួយកន្លែង។ ដោយ **ក** ខ្លាច **ខ** ដាក់ពាក្យបណ្ដឹងទៅតុលាការដោយហេតុថាខ្លួនមិនមានប្រាក់គ្រប់គ្រាន់ក្នុងការសងទៅឱ្យ **ខ** បន្ទាប់មក **ខ** ក៏បានអនុវត្តដោយបង្ខំនូវផ្ទះរបស់ **ក**។ ប៉ុន្តែ **ក** ក៏បានឃុតឃិតគ្នាជាមួយ **គ** ដើម្បីបង្កើតរូបភាពខាងក្រៅដែល **ក** បានលក់ផ្ទះទៅឱ្យ **គ** ហើយ **ក** និង **គ** បានធ្វើលិខិតយថាភូត ហើយ **ក** បានចុះបញ្ជីផ្ទេរផ្ទះនោះទៅឱ្យ **គ**។ ដូចនេះ កិច្ចសន្យានោះត្រូវចាត់ទុកជាមោឃៈ ដូចនេះ **ខ** អាចអនុវត្តដោយបង្ខំលើផ្ទះរបស់ **ក** បាន។

[55] មាត្រា៣៥៣ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ក្នុងករណី បបនីយផ្លូវចិត្ត មានតែអ្នកបង្ហាញឆន្ទៈទេដែលបង្ហាញនូវឆន្ទៈមិនពិតប្រាកដ ប៉ុន្តែនៅក្នុងករណីការបង្ហាញឆន្ទៈមិនពិត មិនត្រឹមតែអ្នកបង្ហាញឆន្ទៈទេ ថែមទាំងភាគីម្ខាងទៀតបានដឹងថាការបង្ហាញឆន្ទៈរបស់ខ្លួនគឺមិនពិត។ ដូចនេះមានន័យថា ភាគីទាំងពីរនៃកិច្ចសន្យាបានបង្ហាញឆន្ទៈមិនពិតដូចគ្នា។

**២.៨.២.ការការពារតតិយជន**

មោឃៈភាពនៃកិច្ចសន្យា ដែលបានកំណត់ក្នុងការបង្ហាញឆន្ទៈមិនពិតនេះមិនអាចអះអាងចំពោះតតិយជនដែលមានទំនាក់ទំនងផលប្រយោជន៍ ដោយយកកិច្ចសន្យាដោយផ្អែកទៅលើការបង្ហាញឆន្ទៈមិនពិតជាមូលដ្ឋានបានឡើយ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលតតិយជននោះជាជនទុច្ចរិត ឬមិនបានដឹងអំពីការបង្ហាញនូវឆន្ទៈមិនពិតដោយមានកំហុសធ្ងន់ធ្ងរ[56]។

[56] មាត្រា៣៥៣ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមការសិក្សាស្រាវជ្រាវយ៉ាងលម្អិតទៅលើកិច្ចសន្យានៅប្រទេសកម្ពុជាមានការវិវត្តន៍យ៉ាងច្រើនតំណាក់កាលបានបង្ហាញឱ្យឃើញថា លក្ខខណ្ឌនៃការបង្កើតកិច្ចសន្យាមិនមែនជាសញ្ញាណថ្មីដែលទើបនឹងកើតមាននៅក្នុងប្រទេសកម្ពុជានោះទេ។ កិច្ចសន្យា គឺត្រូវបានកើតឡើងតាំងពីយូរលង់ណាស់មកហើយ ប៉ុន្តែគ្រាន់តែមិនមានច្បាប់បញ្ញត្តិដូចសម័យបច្ចុប្បន្នតែប៉ុណ្ណោះ។ ជាមួយគ្នានេះ ដោយសារច្បាប់មានការរីកចម្រើនទៅតាមកាលៈទេសៈនៃការអភិវឌ្ឍន៍សង្គម ទើបមានលក្ខខណ្ឌនៃការបង្កើតកិច្ចសន្យាបានចែងនៅក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ដើម្បីឱ្យប្រជាជនមានភាពងាយស្រួលក្នុងការធ្វើកិច្ចសន្យាដែលតម្រូវតាមលក្ខខណ្ឌច្បាប់បានកំណត់ជៀសវាងនូវការលុបចោល ឬមោឃៈភាពនៃកិច្ចសន្យា។ មិនតែប៉ុណ្ណោះកិច្ចសន្យាដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍ប្រទេស និងការអភិវឌ្ឍគ្រប់វិស័យ ព្រមទាំងធានាឱ្យបាននូវភាពសុចរិត និងភាពស្មោះត្រង់របស់ភាគីនៅក្នុងកិច្ចសន្យាផងដែរ។ ជាមួយគ្នានេះ ដើម្បីឱ្យកិច្ចសន្យាមួយដែលមានលក្ខខណ្ឌគ្រប់គ្រាន់ស្របទៅតាមប្បញ្ញត្តិច្បាប់ គឺត្រូវតែគោរពឱ្យបានស្របនឹងគោលការណ៍នៃភាពសុចរិតផ្អែកតាមភាពស្មោះត្រង់ គឺ លក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់នៃកិច្ចសន្យា ដែលជាលក្ខខណ្ឌស្នូលរបស់កិច្ចសន្យា។

សរុបមកដើម្បីឱ្យភាគីនៃកិច្ចសន្យាបានបង្ហាញឆន្ទៈរបស់ពិតរបស់ខ្លួន ចាំបាច់ត្រូវតែមានការយល់ដឹងនឹងស្វែងយល់ឱ្យបានច្បាស់ពីលក្ខខណ្ឌនៃការបង្កើតកិច្ចសន្យា។ លក្ខខណ្ឌនៃការបង្កើតកិច្ចសន្យាមានសារៈសំខាន់ណាស់ ដោយសារកិច្ចសន្យាកើតចេញពីឆន្ទៈពិតប្រាកដរបស់ភាគីដែលមានបំណងក្នុងការបង្កើតកាតព្វកិច្ចសម្រាប់ប្រយោជន៍របស់ខ្លួន និងជៀសវាងកំហុសកើតឡើងដោយចេតនា និងអចេតនាណាមួយបានកើតឡើងក្រោយពីការមិនគោរពទៅលក្ខខណ្ឌនៃការបង្កើតកិច្ចសន្យា ដែលក្រមរដ្ឋប្បវេណីបានបញ្ញត្តិប្រសិនបើកិច្ចសន្យាដែលបានបង្កើតហើយ ឬ/និងកំពុងតែបង្ហាញឆន្ទៈក្នុងការបង្កើតមានវិការៈ អាចជាមូលហេតុនាំឱ្យមានមោឃៈភាព ឬការលុបចោលកិច្ចសន្យានោះបាន។

ជាចុងក្រោយ ឆ្លងកាត់តាមខ្លឹមសារសារណានេះ យើងខ្ញុំសង្ឃឹមថាចូលរួមយ៉ាងសំខាន់ក្នុងវិស័យច្បាប់ជាពិសេសលក្ខខណ្ឌក្នុងការបង្កើតកិច្ចសន្យា។ មួយវិញទៀតយើងខ្ញុំសង្ឃឹមថា សារណាមួយនេះនឹងជួយជាយោបល់ ឬ ជាឯកសារបានផ្អែកតូចចំពោះអ្នកដែលស្រលាញ់និងចង់សិក្សាក្នុងវិស័យច្បាប់ ក៏ដូចជាពលរដ្ឋសាមញ្ញ ដែលមានបំណងចង់ស្វែងរកប្រាក់ចំណេញតាមរយៈការប្រកបជួញដូររបស់ខ្លួនឱ្យស្របតាមច្បាប់ដែលបានកំណត់ គឺសុទ្ធសឹងតែត្រូវការការធ្វើកិច្ចសន្យាជាចាំបាច់។ ជាថ្មីម្តងទៀត ថ្វីត្បិតតែសារណាមួយនេះមិនទាន់មានលក្ខណៈពេញលេញមួយរយភាគរយក៏ពិតមែន យើងខ្ញុំសង្ឃឹមយ៉ាងម៉ុតមាំថា វានឹងជួយជាគំនិតមួយផ្នែកក្នុងការពង្រឹងលើវិស័យច្បាប់ និងយុត្តិធម៌ និងជួយសម្រួលដល់ប្រជាពលរដ្ឋ និងសង្គមជាតិមួយចំណែកផងដែរ។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីយើងខ្ញុំទាំងពីរ បានធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទនេះមក យើងខ្ញុំទទួលបានបទពិសោធន៍ និងចំណេះដឹងថ្មីៗជាច្រើនពាក់ព័ន្ធនឹងលក្ខខណ្ឌនៃបង្កើតកិច្ចសន្យា ជាពិសេសយល់ដឹងពីអត្ថប្រយោជន៍នៃកិច្ចសន្យាផងដែរ។ ទន្ទឹមនឹងនេះការស្រាវជ្រាវរបស់យើងខ្ញុំក៏បានជួបឧបសគ្គមួយចំនួនដូចជាការស្វែងរកឯកសារដែលពាក់ព័ន្ធប្រធានបទ ព្រមទាំងមានភាពស្មុកស្មាញមួយចំនួនផងដែរ ប៉ុន្តែយើងខ្ញុំនៅតែខិតខំប្រមូលឯកសារដែលពាក់ព័ន្ធទាំងឡាយអស់ពីសមត្ថភាពដែលអាចធ្វើទៅរួច ដើម្បីចងក្រងជាសារណានេះឱ្យខានតែបាន។

ដើម្បីជាការឆ្លើយតបទៅនឹងបញ្ហាដែលបានលើកឡើងខាងលើ យើងខ្ញុំទាំងពីរនាក់សូមសំណូមពរដល់អ្នកដែលពាក់ព័ន្ធដូចជា៖

១.**រាជរដ្ឋាភិបាលៈ** ជាពិសេសតាមរយៈក្រសួងយុត្តិធម៌ដែលជាសេនាធិការ បន្តពង្រឹង លើកកម្ពស់ផ្សព្វផ្សាយចំណេះដឹងលើវិស័យច្បាប់ឱ្យបានទូលំទូលាយបន្ថែមទៀត តាមរយៈការដាក់បញ្ចូលនូវកម្មវិធីថ្នាក់ក្រោយឧត្តមសិក្សានូវចំណេះដឹងមូលដ្ឋានផ្នែកច្បាប់ ក៏ដូចជាបង្កើតកម្មវិធីផ្សព្វផ្សាយច្បាប់តាមរយៈការចុះទៅដល់ថ្នាក់មូលដ្ឋានផ្ទាល់ និងតាមរយៈប្រព័ន្ធផ្សព្វផ្សាយនានា ដោយសារតែប្រជាពលរដ្ឋភាគច្រើន ជាពិសេសនៅតំបន់ដាច់ស្រយាលពិតជាមិនសូវបានចាប់អារម្មណ៍ ឬទទួលបាននូវចំណេះដឹងផ្នែកច្បាប់ទេ ខណៈច្បាប់ និងបទបញ្ញត្តិថ្មីៗត្រូវបានតាក់តែង និងប្រកាសឱ្យប្រើជាបន្តបន្ទាប់។

២.**ស្ថាប័នតុលាការៈ** ត្រូវពន្លឿននីតិវិធី និងដោះស្រាយវិវាទដែលប្រជាពលរដ្ឋលោកបានដាក់ពាក្យបណ្ដឹងឱ្យមានសុក្រឹតភាព ឆាប់ រហ័ស និងយុត្តិធម៌។

៣.**មន្ត្រីរាជការ សិស្ស និស្សិតៈ** បុគ្គលទាំងនេះត្រូវបានចាត់ទុកថាជាអ្នកមានចំណេះដឹង និងការយល់ដឹងអំពីច្បាប់ និងព័ត៌មានផ្សេងៗច្បាស់ច្រើនជាងពលរដ្ឋធម្មតា។ ដូចនេះ សិស្ស មន្ត្រីរាជការ និស្សិត គួរតែធ្វើខ្លួនជាគំរូដោយត្រូវគោរពច្បាប់ និងមិនប្រព្រឹត្តអ្វីដែលជាបទល្មើសដែលច្បាប់បានកំណត់ថា ជាបទល្មើស ហើយអ្វីជាពិសេសត្រូវមានស្មារតីចែករំលែកក្នុងនាមជាខ្មែរដូចគ្នា។

៤.**ប្រជាពលរដ្ឋៈ** ប្រជាពលរដ្ឋត្រូវតែចូលរួមអនុវត្តច្បាប់ឱ្យបានខ្ជាប់ខ្ជួន ស្របតាមច្បាប់ជាធរមាន។ ពួកគាត់គួរតែស្វែងយល់ច្បាប់នានាតាមអ្វីដែលអាចធ្វើបាន ព្រោះយើងទាំងអស់គ្នារស់នៅក្នុងសង្គមនីតិរដ្ឋ ការយល់ដឹងពីច្បាប់ គឺជារឿងសំខាន់ក្នុងជីវភាពប្រចាំថ្ងៃ។

## ពន្យល់ពាក្យគន្លឹះ

| ពាក្យគន្លឹះ | អត្ថន័យ | ន័យសាមញ្ញ |
|---|---|---|
| ១.កិច្ចសន្យា | ជាកិរិយាដែលបុគ្គលពីរនាក់ ឬច្រើននាក់ ដែលមានឆន្ទៈត្រូវគ្នាព្រមបង្កើត កែប្រែ ឬរំលត់កាតព្វកិច្ច។ | ការព្រមព្រៀងរវាងមនុស្សពីរនាក់ក្នុងការធ្វើអ្វីមួយ ឬទិញអ្វីមួយ។ |
| ២.សកម្មភាពឯកតោភាគី | ជាសកម្មភាពដែលបង្កើត កែប្រែ ឬរំលត់នូវកាតព្វកិច្ច ដោយបង្ហាញឆន្ទៈនៃការចាត់ចែងទ្រព្យដោយភាគីម្ខាង ឬ ដោយអនុវត្តសិទ្ធិដែលបានទទួលតាមកិច្ចសន្យា ឬ តាមបញ្ញត្តិនៃច្បាប់។ | |
| ៣.សំណើ | ជាការសុំបង្កើតកិច្ចសន្យាដែលបានធ្វើឡើងដោយឆន្ទៈជាមួយនឹងចំណងគតិយុត្តក្នុងករណីដែលមានស្វីការរបស់ភាគីម្ខាងទៀតចំពោះសំណើ។ | ការស្នើសុំធ្វើកិច្ចសន្យា។ |
| ៤. ស្វីការ | ជាការបង្ហាញឆន្ទៈដែលអ្នកទទួលសំណើយល់ព្រមចំពោះសំណើនោះ។ | ការយល់ព្រមទទួលយកសំណើ។ |
| ៥. ស្នើការ | ជាការសម្តែងឆន្ទៈដែលបុគ្គលម្នាក់បញ្ចេញការយល់ព្រមរបស់ខ្លួនចំពោះសំណើដែលបុគ្គល | |

| | | |
|---|---|---|
| | ដទៃបានស្នើមកដើម្បីបង្កើតកិច្ចសន្យា។ | |
| ៦. អនុភាព | ជាផលគតិយុត្តដែលកើតចេញពីលិខិតគតិយុត្ត ដូចជាកិច្ចសន្យាច្បាប់។ | |
| ៧. វិការៈ | ជាការប្រែប្រួលប្រួលចាកពីប្រក្រតី | |
| ៨. តតិយជន | ជាជនទីបី ឬ ជនដែលមិនមានក្នុងទំនាក់ទំនងគតិយុត្ត | |
| ៩. កាតព្វកិច្ច | ជាចំណងតាមផ្លូវច្បាប់ដែលចងបុគ្គលពីរនាក់ដែលឱ្យបុគ្គលម្នាក់ដែលច្បាប់ហៅថា "កូនបំណុល" មានករណីមួយចំនួនទៀតដែលច្បាប់ហៅថា "ម្ចាស់បំណុល"។ | កិច្ចការដែលត្រូវបំពេញដាច់ខាត |
| ១០. អនីតិជន | ជាជនដែលមិនទាន់គ្រប់អាយុតាមច្បាប់កំណត់។ | ជនដែលស្ថិតក្រោម១៨ឆ្នាំ |
| ១១. បុគ្គលភាព | ជាភាពមានលក្ខណៈជាម្ចាស់សិទ្ធិ និងកាតព្វកិច្ច។ | |
| ១២. លិខិតឯកជន | លិខិតទាំងឡាយដែលបង្កើតឡើងដោយបុគ្គលឯកជនដោយមានចុះហត្ថលេខានិងស្នាមម្រាមដៃ។ | |

| | | |
|---|---|---|
| ១៣.លិខិតយថាភូត | លិខិតដែលធ្វើឡើងតាមរូបមន្តមន្ត្រីសាធារណៈ ដែលត្រូវបានអនុញ្ញាតឱ្យប្រតិបត្តិមុខងារនេះ។ | លិខិតទាំងឡាយដែលរៀបចំឡើងដោយសារការី។ |
| ១៤.សកម្មភាព | តាមក្រមរដ្ឋប្បវេណីមានន័យថាការបង្ហាញឆន្ទៈតាមរយៈកិច្ចសន្យា ឬជាឯកតោភាគី | |
| ១៥.សមត្ថភាព | លក្ខណៈសម្បត្តិរបស់បុគ្គលដែលតម្រូវដោយច្បាប់រួមមាន៖<br>-លក្ខណៈសម្បត្តិដែលអាចក្លាយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ច (សមត្ថភាពទទួលសិទ្ធិ)<br>-លក្ខណៈសម្បត្តិដែលអាចយល់ដឹង និងវិនិច្ឆ័យបានអំពីលទ្ធផលតាមផ្លូវច្បាប់នូវសកម្មភាពរបស់ខ្លួន(សមត្ថភាពខាងឆន្ទៈ)។<br>-លក្ខណៈសម្បត្តិដែលអាចធ្វើឱ្យសកម្មភាពរបស់ខ្លួនមានអានុភាពតាមផ្លូវច្បាប់ (សមត្ថភាពក្នុងការធ្វើសកម្មភាព)។ | |
| ១៦. គតិយុត្ត | -តាមគន្លងច្បាប់<br>-ដែលទាក់ទងនឹងច្បាប់ដែលត្រឹមត្រូវតាមច្បាប់។ | |

# ឯកសារយោង

# ឯកសារយោង

## ១.បទប្បញ្ញត្តិច្បាប់

-ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើ ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៧។

## ២.សៀវភៅ និងស្នាដៃអ្នកនិពន្ធ

-សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី ភាគ២ ៖ គន្លីទី៤ រៀបចំដោយគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង ក្រុមការងារជប៉ុនដែលទទួលធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី២០០៩-២០១០។

-សេចក្តីពន្យល់អំពីក្រមរដ្ឋប្បវេណី ភាគ១~៣ រៀបរៀងដោយក្រុមការងារនៃគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ។

-ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១ សមិទ្ធផលគម្រោងអភិវឌ្ឍន៍ច្បាប់ និងតុលាការ។

-នីតិរដ្ឋប្បវេណី (មេរៀនសង្ខេប) រៀបរៀងដោយលោកមេធាវី អ៊ីវ ប៉ូលី។

-បទឧទ្ទេសនាម ស្តីអំពី លក្ខខណ្ឌនៃការបង្កើតកិច្ចសន្យា ដោយ លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត។

# ឧបសម្ព័ន្ធ

# **បញ្ជីឧបសម្ព័ន្ធ**

**ឧបសម្ព័ន្ធទី១ ៖ គំរូកិច្ចសន្យាសំខាន់ៗ**

-កិច្ចសន្យាលក់-ទិញ

-កិច្ចសន្យាប្រទានកម្ម

-កិច្ចសន្យាខ្ចីបរិភោគ

-កិច្ចព្រមព្រៀងជួល

-កិច្ចសន្យាអាណត្តិ

-កិច្ចសន្យាម៉ៅការ

-កិច្ចសន្យាការងារ

-កិច្ចសន្យាក្រុមហ៊ុន

-កិច្ចសន្យាសះជា

**ឧបសម្ព័ន្ធទី២ ៖ កម្រងមាត្រាដកស្រង់ចេញពីក្រមរដ្ឋប្បវេណី**

# ឧបសម្ព័ន្ធទី១ ៖
# គំរូកិច្ចសន្យាសំខាន់ៗ

## ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចសន្យាលក់-ទិញ

កិច្ចសន្យានេះធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃ(  ) ខែ  ឆ្នាំ

**រវាង**

**ភាគី "ក" ៖** ឈ្មោះ  ភេទស្រី អាយុ  ឆ្នាំ សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ  ដែលមានអាសយដ្ឋានបច្ចុប្បន្ន នៅភូមិ  សង្កាត់  ខណ្ឌ  រាជធានីភ្នំពេញ ដែលតទៅនេះ ហៅថា "ភាគីអ្នកលក់" ឬ ភាគី "ក"។

**និង**

**ភាគី "ខ" ៖** ឈ្មោះ  ភេទប្រុស អាយុ  ឆ្នាំ សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ  ដែលមានអាសយដ្ឋានបច្ចុប្បន្ន នៅភូមិ  ឃុំ  ស្រុក  ខេត្ត  ដែលតទៅនេះហៅថា "ភាគីអ្នកទិញ" ឬ ភាគី "ខ"។

**យោង ៖** - លិខិតប្រគល់ និងទទួលប្រាក់កក់ចុះថ្ងៃទី  ខែ  ឆ្នាំ  ។

**ដោយហេតុថា ៖**

ភាគី "ក" និង ភាគី "ខ" បានព្រមព្រៀង និងឯកភាពគ្នាក្នុងការទិញលក់ដីមួយកន្លែងមានទំហំ **២០១១៧.៤១៧ (ពីរម៉ឺនមួយរយដប់ប្រាំពីរក្បៀសបួនរយដប់ប្រាំពីរ) ម៉ែត្រក្រឡា** មានទីតាំងស្ថិតនៅភូមិ  ឃុំ  ស្រុក  ខេត្ត  ។

## ផ្អែកតាមការពិភាក្សាគ្នា ភាគីទាំងពីរ បានព្រមព្រៀងគ្នាដូចខាងក្រោមនេះ៖

**ប្រការ១ ៖ កម្មវត្ថុនៃកិច្ចសន្យា**

១.១. កិច្ចសន្យានេះមានគោលបំណងកំណត់នូវកាតព្វកិច្ចរវាងគូភាគី និងការទូទាត់ប្រាក់ នៃការលក់ទិញដី មួយកន្លែង មានទំហំ **២០១១៧ . ៤១៧ (ពីរម៉ឺនមួយរយដប់ប្រាំពីរ ក្បៀសបួនរយដប់ប្រាំពីរ)** ម៉ែត្រក្រឡា មានទីតាំងស្ថិតនៅភូមិ  ឃុំ  ស្រុក  ខេត្ត  ក្នុងតម្លៃ **១៥** USD (**ដប់ប្រាំដុល្លារសហរដ្ឋអាមេរិក**) ក្នុងមួយម៉ែត្រក្រឡា ដែលមានតម្លៃសរុបចំនួន **៣០២,៦៦១ . ២៥៥** USD (**បីរយពីរពាន់ប្រាំមួយរយហុកសិបមួយ**

**គ្បៀសពីរយហាសិបប្រាំដុល្លារសហរដ្ឋអាមេរិក)** ដោយមានភាគី "ក" ជាភាគីអ្នកលក់ និង ភាគី "ខ" ជាភាគីអ្នកទិញ។

១.២ ក្នុងការទិញលក់ ដី ខាងលើនេះ ភាគី "ក" និង ភាគី "ខ" បានព្រមព្រៀងប្រគល់ជូនភាគី "ខ" ចំនួន **១** USD (**មួយ**) ដុល្លារសហរដ្ឋអាមេរិក ក្នុងមួយម៉ែត្រក្រឡា សរុបជាប្រាក់ចំនួន **២០១១៧.៤១៧ (ពីរម៉ឺនមួយរយដប់ប្រាំពីរ គ្បៀសបួនរយដប់ប្រាំពីរដុល្លារសហរដ្ឋអាមេរិក)** ដើម្បីអោយភាគី "ខ" ទទួលបន្ទុកក្នុងការរ៉ាប់រង នីតិវិធីផ្ទេរកម្មសិទ្ធិ ពីភាគី "ក" ទៅភាគី "ខ" ។ ក្នុងករណីដែលចំណាយលើសពីនេះ ភាគី "ខ" មិនអាចទាមទារបន្ថែមពីភាគី "ក" បានទេ។

**ប្រការ២ ៖ អត្តសញ្ញាណ និងទីតាំងនៃដី**

អត្តសញ្ញាណដី ៖ **២០១១៧.៤១៧ (ពីរម៉ឺនមួយរយដប់ប្រាំពីរគ្បៀសបួនរយប្រាំពីរ)** ម៉ែត្រក្រឡា មានទីតាំងស្ថិតនៅភូ ឃុំ ស្រុក

ខេត្ត

ទីតាំងព្រំប្រទល់៖ - ខាងជើងទល់នឹង

- ខាងត្បូងទល់នឹង
- ខាងកើតទល់នឹង
- ខាងលិចទល់នឹង

**ប្រការ៣ ៖ របៀបទូទាត់ និងលក្ខខណ្ឌនៃការទូទាត់**

បន្ទាប់ពីការបង្វិលប្រាក់ក្នុងប្រការ ១.២ ខាងលើ នោះភាគី "ខ" ត្រូវបង់ប្រាក់ថ្លៃទិញដីសរុបចំនួន **២៨១,៦៤៣.៨៣៨ (ពីររយប៉ែតសិបមួយពាន់ ប្រាំមួយរយសែសិបបី គ្បៀសប្រាំបីរយសាមសិបប្រាំបីដុល្លារសហរដ្ឋអាមេរិក)**។

## ការប្រគល់ប្រាក់ និងការទូទាត់ប្រាក់ នឹងត្រូវធ្វើឡើងទៅតាមដំណាក់កាល ដូចខាងក្រោម៖

**ដំណាក់កាលទី១ ៖** **ភាគី "ខ"** បានបង់ប្រាក់ថ្លៃទិញចំនួន **៧0,000 USD (ប្រាំពីរម៉ឺនដុល្លារអាមេរិក)** គ្រប់ចំនួន ជូនទៅ**ភាគី "ក"** នៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២១។

**ដំណាក់កាលទី២ ៖** **ភាគី "ខ"** យល់ព្រមបង់ប្រាក់ចំនួន **៧0,000 USD (ប្រាំពីរម៉ឺនដុល្លារអាមេរិក)** ជូន**ភាគី "ក"** នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២១ នោះទើប**ភាគី "ខ"** មានសិទ្ធិក្នុងការចាប់ផ្តើមដំណើរការក្នុងការវាស់វែងកំណត់ព្រំ ដី។

**ដំណាក់កាលទី៣ ៖** **ភាគី "ខ"** យល់ព្រមបង់ប្រាក់ជូន**ភាគី "ក"** បង្គ្រប់ចំនួន ១៤១,៦៤៣.៨៣៨ USD (មួយរយសែសិបមួយពាន់ប្រាំមួយរយសែសិបបី គ្បៀសប្រាំបីរយសាមសិបប្រាំបី





**ដុល្លារសហរដ្ឋអាមេរិក**) នៅរយៈពេល ០៧ (ប្រាំពីរ) ថ្ងៃក្រោយពីពេលដែល **ភាគី "ខ"** បានទទួលដំណឹងថាការកាត់ឈ្មោះផ្ទេរកម្មសិទ្ធិទៅឈ្មោះ **ភាគី "ខ"** បានរួចរាល់ជាស្ថាពរនៅអង្គភាពសុរិយោដី ។

## ប្រការ៤ ៖ ភាតព្វកច្ច លក្ខខណ្ឌ និងការពិន័យ

៤.១. ដោយហេតុថាភាគី "ខ" មានអំណាច និងសមត្ថភាពពេញលេញក្នុងការដំណើរការផ្ទេរកម្មសិទ្ធិ ភាគី "ក" និងភាគី "ខ" ព្រមព្រៀងគ្នាប្រគល់តួនាទីក្នុងដំណើរការផ្ទេរកម្មសិទ្ធិជូនដល់ភាគី "ខ" រហូតដល់ចប់ជាស្ថាពរ ដោយមានភាគី "ក" និងមេធាវីតំណាងរបស់ភាគី "ក" ចូលរួមអមក្នុងដំណើរការខាងលើនេះ។ ចំពោះការគ្រប់គ្រងឯកសារច្បាប់ដើម ភាគីទាំងពីរបានព្រមព្រៀង ប្រគល់ជូនមេធាវីតំណាងដោយអាណត្តិរបស់ភាគី "ក" ក្នុងការកាន់កាប់ដើម្បីសហការគ្រប់កិច្ចនីតិវិធីជាមួយតំណាងរបស់ភាគី "ខ"។ ប័ណ្ណដែលត្រូវចេញដោយអង្គភាពសុរិយោដី ដែលជាកម្មវត្ថុនៃការផ្ទេរសិទ្ធិនេះ ត្រូវប្រគល់ជូនមេធាវីតំណាងដោយអាណត្តិរបស់ភាគី "ក"។ នៅពេលដែលភាគី "ខ" ប្រគល់ប្រាក់ដំណាក់កាលទីបីជូនទៅភាគី "ក" រួចរាល់ នោះមេធាវីរបស់ភាគី "ក" ត្រូវប្រគល់ប័ណ្ណជូនទៅភាគី "ខ" នៅពេលដំណាលគ្នានោះ។

៤.២ ភាគី "ក" មិនអាចកែប្រែឈប់លក់អចលនវត្ថុនេះបានទេ ប្រសិនបើភាគី "ខ" អនុវត្តកាតព្វកិច្ចបង់ប្រាក់បានត្រឹមត្រូវ។

៤.៣ ការផ្ទេរកម្មសិទ្ធិនេះត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងយូរ ០៤ (បួន) ខែ ចាប់ពីថ្ងៃភាគី "ខ" បានបង់ប្រាក់ដំណាក់កាលទី២ ជូនទៅភាគី "ក"។

៤.៤ ក្នុងករណីដែល**ភាគី "ខ"** កែប្រែមិនទិញវិញ ឬ មិនបង់ប្រាក់តាមខ្លឹមសារប្រការ៣ នោះប្រាក់ដែលបានបង់រួច ត្រូវបានជាប្រយោជន៍របស់**ភាគី "ក"** ហើយកិច្ចសន្យាត្រូវរលាយដោយស្វ័យប្រវត្តិ ដោយ **ភាគី "ខ"** ត្រូវធ្វើការផ្ទេរកម្មសិទ្ធិត្រឡប់វិញទៅអោយ**ភាគី "ក"** វិញ ។

៤.៥ **ភាគី "ខ"** ត្រូវទទួលខុសត្រូវលើប្រាក់ពន្ធទាំងអស់ដែលកំណត់ដោយរដ្ឋ ត្រូវជាបន្ទុករបស់ភាគីអ្នកទិញទាំងអស់។

៤.៦ ភាគី "ខ" ពុំអាចផ្ទេរសិទ្ធ ដាក់បញ្ចាំ ជួល អាស្រ័យផល ចាត់ចែង ឈូសឆាយ ឬ កាន់កាប់ដីទាំងមូល ឬ ផ្នែកណាមួយនៃអចលនវត្ថុខាងលើបាននោះទេ ប្រសិនបើមិនទាន់បានប្រគល់ប្រាក់គ្រប់ចំនួនទាំងបីដំណាក់កាលជូនទៅភាគី "ក"។

៤.៧ ទោះបីជាការផ្ទេរកម្មសិទ្ធិទៅភាគី "ខ" បានធ្វើឡើងរួចរាល់ជាស្ថាពរក៏ដោយ ក្នុងករណីដែលភាគី "ខ" ពុំបានបង់ប្រាក់ដំណាក់កាលទី៣ គ្រប់ចំនួនជូនទៅភាគី "ក" នោះការផ្ទេរសិទ្ធិនេះត្រូវទុកជាមោឃៈ ហើយភាគី "ក" មានសិទ្ធិក្នុងការផ្ទេរសិទ្ធិលើអចលនវត្ថុខាងលើមកជាកម្មសិទ្ធិរបស់ភាគី "ក" វិញ។





**ប្រការ៥ ៖ ការបញ្ចប់កិច្ចសន្យា**

កិច្ចសន្យានេះចាត់ទុកថាបានបញ្ចប់ដោយ**ស្វ័យប្រវត្តិ** ក្នុងករណីដែលកាតព្វកិច្ច របស់ភាគីទាំងពីរ ត្រូវបានបំពេញចប់សព្វគ្រប់ គឺភាគី "ក" បានទទួលប្រាក់ថ្លៃលក់ដីគ្រប់ចំនួន និងបានបញ្ចប់ការផ្ទេរកម្មសិទ្ធិដីខាងលើមកអោយភាគី "ខ" ហើយភាគី "ខ" គឺទទួលបានការផ្ទេរកម្មសិទ្ធិស្របច្បាប់ និងត្រឹមត្រូវ។

**ប្រការ៦ ៖ ឯកសារតម្កល់ និងភាសាផ្លូវការ**

កិច្ចសន្យានេះធ្វើឡើងជាភាសាខ្មែរ ចំនួន០៤ (បួន) ច្បាប់ដើម សម្រាប់ភាគីនីមួយៗ ម្នាក់មួយច្បាប់ មេធាវីមួយច្បាប់ និងក្រុមហ៊ុនមេធាវីមួយច្បាប់។

**ប្រការ៧៖ អនុភាពអនុវត្ត**

កិច្ចសន្យានេះមានអនុភាពអនុវត្ត ចាប់ពីពេលគូភាគី បានផ្តិតស្នាមមេដៃស្តាំ នៅចំពោះមុខសាក្សីជាកសិណ បន្ទាប់ពីភាគីនីមួយៗ បានអាន បានពិនិត្យយ៉ាងល្អិតល្អន់ និងបានយល់ព្រម គ្រប់ប្រការទាំងអស់នេះ អត្ថបទនៃកិច្ចសន្យាខាងលើ។

រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ

**ភាគី "ខ" អ្នកទិញ** **ភាគី "ក" អ្នកលក់**





**សូមបញ្ជាក់ថា**

គូភាគីពិតជាបាន

ផ្តិតស្នាមម្រាមដៃនៅចំពោះមុខមេធាវីប្រាកដមែន

រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ

**ហត្ថលេខា និងត្រា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**កិច្ចព្រមព្រៀងប្រទានកម្ម**

កិច្ចព្រមព្រៀងនេះធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី........ ខែ.......... ឆ្នាំ.................

**រវាង**

**ភាគី "ក"** ៖ ឈ្មោះ ........................ ភេទ ប្រុស ថ្ងៃ/ខែ/ឆ្នាំកំណើត ២០ កុម្ភៈ ១៩៨៦ កាន់លិខិតឆ្លងដែនសញ្ជាតិខ្មែរ លេខ៖ ............................. ដែលមានអាសយដ្ឋាន បច្ចុប្បន្ននៅ ផ្ទះលេខ......... ផ្លូវ ........... ភូមិ៣ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ ចាប់ពីពេលនេះតទៅ ហៅកាត់ថា ភាគី "ក"។

**និង**

**ភាគី "ខ"** ៖ ឈ្មោះ....................... ភេទ ស្រី ថ្ងៃ/ខែ/ឆ្នាំកំណើត ០៣ មិថុនា ១៩៨២ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ លេខ៖ ......................... ដែលមានអាសយដ្ឋានបច្ចុប្បន្ននៅ ផ្ទះលេខ...... ផ្លូវ.......... ភូមិ៣ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ ចាប់ពីពេលនេះតទៅ ហៅកាត់ថា ភាគី "ខ"។

**យោង** : - សុំបុត្រអាពាហ៍ពិពាហ៍លេខ ............ សៀវភៅអាពាហ៍ពិពាហ៍លេខ ............................ ចុះថ្ងៃទី០៦ ខែមិនា ឆ្នាំ២០១៥។

- អត្តសញ្ញាណប័ណ្ណខ្មែរលេខ ............................. របស់ឈ្មោះ .............
- លិខិតឆ្លងដែនលេខ ............................. របស់ឈ្មោះ ...................
- អត្តសញ្ញាណប័ណ្ណខ្មែរលេខ ..................... របស់ឈ្មោះ ................
- សៀវភៅស្នាក់នៅលេខ ............................. ទំព័រ.......... ចុះថ្ងៃទី០៣ ខែ០២ ឆ្នាំ២០១២
- វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ............................ ទំហំ ៦៤ ម² ទីតាំង ភូមិ៣ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក ក្រុងភ្នំពេញ។
- វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ............................ ទំហំ ៣៥៦ ម² ទីតាំង ភូមិបត្តាជី សង្កាត់ ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្ដាល។
- វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ............................ ទំហំ ៤៦០ ម² ទីតាំង ភូមិបត្តាជី សង្កាត់ ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្ដាល។
- សេចក្ដីចម្លងសំបុត្រកំណើតរបស់ឈ្មោះ................. លេខ........ ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០២។
- សេចក្ដីចម្លងសំបុត្រកំណើតរបស់ឈ្មោះ ............. លេខ ......... ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ ២០០២។

- សេចក្តីចម្លងសំបុត្រកំណើតរបស់ឈ្មោះ .................................. លេខ .......... សៀវភៅកំណើតលេខ ០៣/២០១៦ ឆ្នាំ២០១៦។

- សេចក្តីចម្លងសំបុត្រកំណើតរបស់ឈ្មោះ .................................. លេខ ............ សៀវភៅកំណើតលេខ ០៣/២០១៧ ឆ្នាំ២០១៧។

បុព្វកថា

**ដោយហេតុថា៖** ក្រោយពេលដែលភាគីទាំងពីរ បានរស់នៅក្នុងឋានៈជាសហព័ទ្ធអស់រយៈពេលជាងដប់ឆ្នាំ ភាគីទាំងពីរចាប់ផ្តើមមានមានបំណងប្រគល់ទ្រព្យសម្បត្តិដែលមានចែងនៅក្នុងយោងខាងលើនេះទៅឱ្យកូនៗរបស់យើងខ្ញុំទាំងពីរ។ ភាគីបានពិចារណា និងបានពិភាក្សាគ្នាលើការប្រទានកម្ម ជាមួយគ្នានេះ ភាគីបានឯកភាពគ្នា និងបានព្រមព្រៀងគ្នាដោយស្ម័គ្រចិត្ត គ្មានការបង្ខិតបង្ខំ គោរពតាមការសន្យា និងលក្ខខណ្ឌនៃកិច្ចព្រមព្រៀងប្រទានកម្មនេះ។

**ភាគីទាំងពីរបានព្រមព្រៀងគ្នាចុះកិច្ចសន្យាដែលមានខ្លឹមសារ និងលក្ខខណ្ឌដូចតទៅ៖**

**ប្រការ ១ ៖ ការព្រមព្រៀងប្រទានកម្ម**

ភាគី "ក" និងភាគី "ខ" បានព្រមព្រៀងប្រទានកម្ម ដោយការស្ម័គ្រចិត្ត គ្មានការបង្ខិតបង្ខំ និងស្មារតីល្អ ចាប់ពីពេលដែលបានចុះកិច្ចព្រមព្រៀងប្រទានកម្មនេះតទៅ។

**ប្រការ ២ ៖ ជនដែលត្រូវទទួលបានប្រទានកម្ម**

អ្នកដែលត្រូវទទួលបានប្រទានកម្មដែលជាអំណោយផ្តាច់របស់ភាគី"ក" និងភាគី "ខ" ឲ្យទៅកូន៖

-ទី១ ឈ្មោះ .................................... ភេទស្រី ថ្ងៃ/ខែ/ឆ្នាំកំណើត ២៥ មេសា ២០០០។

-ទី២ ឈ្មោះ ...................................... ភេទស្រី ថ្ងៃ/ខែ/ឆ្នាំកំណើត ២០ មិនា ២០០១។

**ប្រការ ៣ ៖ កម្មវត្ថុនៃប្រធានកម្ម**

ភាគី "ក" និង ភាគី "ខ" បានព្រមព្រៀងគ្នាលើការប្រទានកម្ម ដូចតទៅ៖

- **ផ្ទះ** ទំហំ **៦៤ (ហុកសិបបួន)** ម៉ែត្រក្រឡាការ៉េ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ៖ ............................... ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៤ ត្រូវប្រគល់ឲ្យទៅ កូនទាំងពីរឈ្មោះ: ........................... និងឈ្មោះ: ........................... ។
- **ដី** ទំហំ **៣៥៦ (បីរយហាសិបប្រាំមួយ)** ម៉ែត្រក្រឡាការ៉េ ទីតាំងនៅខេត្តកណ្តាល ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ៖ .................................. ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩ ត្រូវប្រគល់ឲ្យទៅកូនទាំងពីរឈ្មោះ......................... និងឈ្មោះ......................... ។
- **ដី** ទំហំ **៤៦០ (បួនរយហុកសិប)** ម៉ែត្រក្រឡាការ៉េ ទីតាំងនៅខេត្តកណ្តាល ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ៖.................................. ចុះថ្ងៃទី......... ខែ............ ឆ្នាំ............ ត្រូវប្រគល់ឲ្យទៅកូនទាំងពីរឈ្មោះ......................... និងឈ្មោះ......................... ។

**ប្រការ ៥ ៖ ឯកសារតម្កល់ និងភាសាផ្លូវការ**

កិច្ចព្រមព្រៀងនេះធ្វើឡើងជាភាសាខ្មែរ ចំនួន ០៣ (បួន) ច្បាប់ដើម៖

- ភាគី"ក" ចំនួន ០១ ច្បាប់
- ភាគី"ខ" ចំនួន ០១ ច្បាប់
- មេធាវី ០១ ច្បាប់

**ប្រការ ៦ ៖ អានុភាពអនុវត្ត**

កិច្ចព្រមព្រៀងនេះ គូភាគីទុកជាច្បាប់សម្រាប់ដាក់ជូនតុលាការជាភស្តុតាង ដើម្បីអនុវត្តន៍សម្រាប់គូភាគី។ កិច្ចព្រមព្រៀងនេះមានអានុភាពអនុវត្តន៍ ចាប់ពីពេលដែលគូភាគី បានផ្តិតម្រាមដៃស្តាំ នៅចំពោះមុខសាក្សីជាកសិណ បន្ទាប់ពីភាគីនីមួយៗ បានអាន បានពិនិត្យយ៉ាងល្អិតល្អន់ និងបានយល់ព្រម គ្រប់ប្រការទាំងអស់នៃកិច្ចព្រមព្រៀងខាងលើ។

ថ្ងៃ............................... ខែ.................... ព.ស. ..........

រាជធានីភ្នំពេញ, ថ្ងៃទី.......... ខែ......... ឆ្នាំ..............

| | |
|---|---|
| ស្នាមម្រាមដៃ | ស្នាមម្រាមដៃ |
| ភាគី "ក" | ភាគី "ខ" |

សូមបញ្ជាក់ថា

គូរភាគីពិតជាបាន

ផ្តិតស្នាមម្រាមដៃនៅចំពោះមុខមេធាវីប្រាកដមែន។

រាជធានីភ្នំពេញ, ទី.......... ខែ......... ឆ្នាំ..............

**ហត្ថលេខា និងត្រា**

កិច្ចសន្យាខ្ចីបរិភោគ
លេខ

សេចក្តីបន្ថែម ក

# កិច្ចសន្យាខ្ចីបរិភោគ

## ១- ឈ្មោះ និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

(១) កូនបំណុល ឈ្មោះ ភេទ ប្រុស សញ្ជាតិ ខ្មែរ ថ្ងៃខែឆ្នាំកំណើត: ថ្ងៃទី ខែ ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ: ចុះថ្ងៃទី ខែ ឆ្នាំ និង ឈ្មោះ ភេទ ស្រី សញ្ជាតិ ខ្មែរ ថ្ងៃខែឆ្នាំកំណើត: ថ្ងៃទី ខែ ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ: ចុះថ្ងៃទី ខែ ឆ្នាំ មានទីលំនៅស្ថិតនៅ: ផ្ទះលេខ ផ្លូវលេខ ភូមិ សង្កាត់ ខណ្ឌ ព្រះរាជាណាចក្រកម្ពុជា (តទៅ ហៅថាភាគី "ក") ។

(២) ជា បាន ចុះបញ្ជីក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដែលមានលេខ ចុះថ្ងៃទី ខែ ឆ្នាំ មានទីស្នាក់ការស្ថិតនៅអគារលេខ ជាន់ក្រោម មហាវិថី ក្រុមទី ភូមិ សង្កាត់ ខណ្ឌ ( ) ព្រះរាជាណាចក្រកម្ពុជា តំណាងដោយឈ្មោះ ភេទស្រី សញ្ជាតិខ្មែរ ថ្ងៃខែឆ្នាំកំណើត ថ្ងៃទី ខែ ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ចុះថ្ងៃទី ខែ ឆ្នាំ (តទៅហៅថា ភាគី "ខ")។

## ២- កិច្ចសន្យាខ្ចីបរិភោគ (សិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែករួម)

កូនបំណុល ឈ្មោះ ភេទ ប្រុស សញ្ជាតិ ខ្មែរ ថ្ងៃខែឆ្នាំកំណើត: ថ្ងៃទី ខែ ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ: ចុះថ្ងៃទី ខែ ឆ្នាំ ភេទ ស្រី សញ្ជាតិ ខ្មែរ ថ្ងៃខែឆ្នាំកំណើត: ថ្ងៃទី ខែ ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ: ចុះថ្ងៃទី ខែ ឆ្នាំ មានទីលំនៅស្ថិតនៅ: ផ្ទះលេខ ផ្លូវលេខ ភូមិ សង្កាត់ ខណ្ឌ ព្រះរាជាណាចក្រកម្ពុជា

(១) ចំនួនប្រាក់ដើម )

(ឥណទានមានកាលកំណត់ទី១ ចំនួន: ដុល្លារអាមេរិក ឥណទានវិបារូបន៍ទី១ ចំនួន: ដុល្លារអាមេរិក ឥណទានវិបារូបន៍ទី២ ចំនួន: ដុល្លារអាមេរិក ឥណទានសំរាប់ទុនបង្វិលទី១ ចំនួន: ដុល្លារអាមេរិក ឥណទានសំរាប់ទុនបង្វិលទី២ ចំនួន: ដុល្លារអាមេរិក ឥណទានសំរាប់ទុនបង្វិលទី៣ ចំនួន: ដុល្លារអាមេរិក ឥណទានមានកាលកំណត់ទី៣ ចំនួន: ដុល្លារអាមេរិក និងឥណទានមានកាលកំណត់ទី ៤ ចំនួន: ដុល្លារអាមេរិក)

(២) អត្រាការប្រាក់ ក្នុងមួយឆ្នាំ។

(៣) សំណងការខូចខាត ... ក្នុងមួយឆ្នាំ នៃប្រាក់ដែលនៅជំពាក់ដូចមានចែងក្នុងលិខិតផ្តល់សំណើឥណទាន ចុះថ្ងៃទី ខែ ឆ្នាំ ចុះថ្ងៃទី ខែ ឆ្នាំ ចុះថ្ងៃទី ខែ ឆ្នាំ ចុះថ្ងៃទី ខែ ឆ្នាំ ចុះថ្ងៃទី ខែ ឆ្នាំ ចុះថ្ងៃទី ខែ ឆ្នាំ និង ចុះថ្ងៃទី ខែ ឆ្នាំ ។

(៤) គូភាគីបានព្រមព្រៀងគ្នាកំណត់លក្ខខណ្ឌពិសេសផ្សេងទៀត ដូចមានចែងក្នុងឧបសម្ព័ន្ធ ក នៃកិច្ចសន្យាខ្ចីបរិភោគនេះ ។

ភាគី "ក" និង ភាគី "ខ" បានព្រមព្រៀងគ្នាបង្កើតកិច្ចសន្យាខ្ចីបរិភោគ ដែលមានចែងនៅក្នុងចំណុចទី ២ខាងលើ ។ ភាគី "ក" និង ភាគី "ខ" បានព្រមព្រៀងគ្នាបង្កើត ហ៊ីប៉ូតែក្ស ម លើសិទ្ធិនៃចំណុច ៣ ដើម្បីធានាសិទ្ធិលើបំណុលដែលមានចែងក្នុងចំណុចទី ២ ខាងលើ ។

**៣- អត្តសញ្ញាណអចលនវត្ថុ ឬសិទ្ធិដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក្ស ម:**

**៣.១ ទ្រព្យធានាទី១**

(១) ទីតាំងអចលនវត្ថុ: ក្បាលដីលេខ ភូមិ សង្កាត់ ខណ្ឌ ព្រះរាជាណាចក្រកម្ពុជា។

(២) លេខក្បាលដី:

(៣) វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ: ចុះថ្ងៃទី ខែ ឆ្នាំ ។

**៣.២ ទ្រព្យធានាទី២**

(១) ទីតាំងអចលនវត្ថុ: ផ្ទះលេខ ផ្លូវលេខ ក្រុមលេខ ភូមិ សង្កាត់ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

(២) លេខក្បាលដី:

(៣) លិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លីលេខ៖ :ថ្ងៃទី ខែ ឆ្នាំ ។

**៣.៣ ទ្រព្យធានាទី៣**

(១) ទីតាំងអចលនវត្ថុ: ក្បាលដីលេខ ភូមិ សង្កាត់ ខណ្ឌ ព្រះរាជាណាចក្រកម្ពុជា។

(២) លេខក្បាលដី:

(៣) វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ: ចុះថ្ងៃទី ខែ ឆ្នាំ ។

**៤- ខសន្យាផ្សេងទៀត (ប្រសិនបើមាន)**

គូភាគីបានព្រមព្រៀងគ្នាលើ ខសន្យាផ្សេងៗទៀត ដូចមានចែងក្នុងឧបសម្ព័ន្ធ ខ នៃកិច្ចសន្យានេះ ។

ធ្វើឡើងជា ០៥ ច្បាប់ នៅថ្ងៃ ... /កេច ខែ ... ឆ្នាំ ... ព.ស័ក ព.ស.
រាជធានីភ្នំពេញ ថ្ងៃទី.. .........ខែ... ...ឆ្នាំ

**បានអានសេចក្តីនៃលិខិតនេះឲ្យគូភាគីស្តាប់ចំពោះមុខសាក្សី**

ឈ្មោះ.....................អាយុ..............ឆ្នាំទីលំនៅសង្កាត់...........................ខណ្ឌ....................រាជធានីភ្នំពេញ។
ឈ្មោះ.....................អាយុ..............ឆ្នាំទីលំនៅសង្កាត់...........................ខណ្ឌ....................រាជធានីភ្នំពេញ។

ស្នាមមេដៃស្តាំ

ភាគី "ក"

ភាគី "ខ"

បានឃើញ និងបញ្ជាក់ថា

ភាគី "ក" និងភាគី "ខ" បានផ្តិតមេដៃស្តាំចំពោះមុខមេធាវីជាសាក្សី

....................

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចព្រមព្រៀងជូនផ្ទះបន្ត

*កិច្ចព្រមព្រៀងជូនផ្ទះនេះ ត្រូវបានធ្វើឡើងនៅថ្ងៃទី ខែ ឆ្នាំ*
*យោង: កិច្ចព្រមព្រៀងជូនផ្ទះ ធ្វើឡើងនៅថ្ងៃទី ខែ ឆ្នាំ*

**ភាគីម្ចាស់ផ្ទះ** ៖ លោក សញ្ជាតិខ្មែរ កើតនៅឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណលេខ: មានអាសយដ្ឋានផ្ទះលេខ ផ្លូវ សង្កាត់ ខណ្ឌ **(ចាប់ពីពេលនេះតទៅ ហៅថា "ភាគី "ក"")។**

**ភាគីអ្នកជូល** ៖ លោកស្រី សញ្ជាតិខ្មែរ កើតនៅឆ្នាំ១៩៨១ កាន់អត្តសញ្ញាណប័ណ្ណលេខ: ចុះថ្ងៃទី ខែ ឆ្នាំ មានទីលំនៅផ្ទះលេខ ផ្លូវ សង្កាត់ ខណ្ឌ **(ចាប់ពីពេលនេះតទៅ ហៅថា "ភាគី "ខ"")។**

**ភាគី "ក" និង ភាគី "ខ" អាចហៅដាច់ដោយឡែកពីគ្នាថា "ភាគី" និងអាចហៅរួមគ្នាថា "គូភាគី" ។**

**<u>បុព្វកថា</u>**

**<u>ដោយហេតុថា៖</u>** ភាគី "ក" គឺជាម្ចាស់កម្មសិទ្ធិករស្របច្បាប់នៃផ្ទះលេខ ផ្លូវ ស្ថិតនៅក្នុង ដែលមានទីតាំងស្ថិតផ្លូវ សង្កាត់ ខណ្ឌ (ចាប់ពីពេលនេះតទៅ ហៅថា "**អចលនវត្ថុ**") ។

**<u>ដោយហេតុថា៖</u>** ភាគី "ខ" មានបំណងជួលពីភាគី "ក" ហើយភាគី "ក" យល់ព្រមជួលអោយភាគី "ខ" នូវអចលនវត្ថុខាងលើនេះដោយអនុលោមតាមខ្លឹមសារ និងលក្ខខណ្ឌទាំងឡាយដែលមានចែងក្នុងកិច្ចព្រម ព្រៀងនេះ ។
**ហេតុដូច្នេះ គូភាគីបានពិភាក្សាគ្នាដោយស្ម័គ្រចិត្ត និងព្រមព្រៀងគ្នាដូចខាងក្រោម៖**

**ប្រការ ១: គោលបំណងនៃការជួល**

១.១. ភាគី "ក" យល់ព្រមជួលឲ្យទៅភាគី "ខ" ហើយភាគី "ខ" យល់ព្រមជួលពីភាគី "ក" នូវអចលនវត្ថុដូចមានចែងលំអិតក្នុងបុព្វកថាខាងលើក្នុងគោលបំណង "ស្នាក់នៅ" ។

១.២. រាល់ទង្វើណាមួយដែលផ្ទុយនឹងកម្មវត្ថុ ឬគោលបំណង ដូចមានចែងក្នុងប្រការនេះ ភាគី "ខ" ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅភាគី"ក" ដើម្បីស្នើសុំការយល់ព្រមជាមុន ហើយការស្នើសុំនេះត្រូវមានការផ្តិតមេដៃពីគូភាគីទាំងសងខាង។ ទោះក្នុងហេតុផលណាមួយក៏ដោយភាគី"ខ" មិនអាចយកអចលនវត្ថុនេះទៅធ្វើអាជីវកម្មតាមរូបភាពណាមួយដែលផ្ទុយនឹងច្បាប់ និងបទបញ្ញត្តិទាំងឡាយនៃព្រះរាជាណាចក្រកម្ពុជាឡើយ។ ក្នុងករណីបំពានខ្លឹមសារនេះ ភាគី "ខ" ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ដោយខ្លួនឯងផ្ទាល់ និងធានាមិនឲ្យមានការពាក់ព័ន្ធដល់ភាគី "ក" ឡើយ។

ប្រការ ២: រយៈពេលជួល

២.១ កិច្ចព្រមព្រៀងនេះមានរយៈពេល៣៦ខែ ស្មើនឹង ៣ឆ្នាំ (សាមសិបប្រាំមួយខែ ស្មើនឹងបីឆ្នាំ) រាប់គិតចាប់ពីថ្ងៃទី០១ ខែ កុម្ភៈ ឆ្នាំ២០២១ (កាលបរិច្ឆេទចាប់ផ្តើម) ដល់ថ្ងៃទី៣១ ខែ មករា ឆ្នាំ២០២៤ (កាលបរិច្ឆេទបញ្ចប់) (ហៅថា "រយៈពេលជួល") ។

២.២ រយៈពេលជួលនេះអាចនឹងបន្តជាថ្មី តាមការព្រមព្រៀងរវាងគូភាគី ដូចមានចែងលំអិតក្នុង ប្រការ ៩.១ និង ៩.២ នៃកិច្ចព្រមព្រៀងនេះ ។

ប្រការ ៣: ថ្លៃឈ្នួល

ភាគី "ខ" ត្រូវទូទាត់ថ្លៃឈ្នួលអចលនវត្ថុនេះ ទៅឲ្យភាគី "ក" តាមចំនួន និងលក្ខខណ្ឌបង់ប្រាក់ខាងក្រោម៖

៣.១. ចំនួន ១៦៥០ ដុល្លារ (មួយពាន់ប្រាំមួយរយហាសិបដុល្លារសហរដ្ឋអាមេរិកគត់) ក្នុងមួយខែសម្រាប់រយៈពេល ១២ខែ (ហៅថា "ថ្លៃឈ្នួល") គិតចាប់ពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២១ ដល់ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២២ និង ចំនួន ១៨១៥ ដុល្លា (មួយពាន់ប្រាំបីរយដប់ប្រាំដុល្លារសហរដ្ឋអាមេរិកគត់) ក្នុងមួយខែសម្រាប់រយៈពេល២៤ ខែ (ហៅថា "ថ្លៃឈ្នួល") គិតចាប់ពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២ ដល់ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៤ ។

៣.២. ភាគី "ខ" ត្រូវធ្វើការបង់ថ្លៃឈ្នួលអោយបានទៀងទាត់នៅរៀងរាល់ ចន្លោះថ្ងៃទី០១ ដល់ថ្ងៃទី ០៥ នៃខែប្រតិទិននីមួយៗ ជាប្រាក់សុទ្ធ ឬ តាមរយៈការវេរប្រាក់ចូលក្នុងគណនីធនាគាររបស់ភាគី "ក" ដែលកំណត់ដោយភាគី "ក" ដូចខាងក្រោម៖

គណនីឈ្មោះ

គណនីលេខ

ធនាគារឈ្មោះ [illegible]

ក្នុងករណីមានការយឺតយ៉ាវខុសពីការកំណត់នេះ ភាគី "ខ" ត្រូវគិតប្រាក់ពិន័យជូនភាគី "ក" តាមអត្រា ៥% (ប្រាំភាគរយ) ក្នុងមួយថ្ងៃនៃចំនួនថ្លៃឈ្នួលដែលត្រូវបង់នោះ ហើយការយឺតយ៉ាវនេះមិនអាចមានរយៈពេលលើសពី០២ខែជាប់ៗគ្នាបានទេ។ ក្នុងករណីលើស ភាគី "ក" មានសិទ្ធិរំលាយកិច្ចព្រមព្រៀងនេះ និងទាមទារនូវថ្លៃឈ្នួលដែលមិនទាន់បង់ និងការខូចខាតផ្សេងៗដែលបានកើត និងដែល អាចកើតចេញពីការខកខាននេះ រួមទាំងស្នើឲ្យភាគី "ខ" បញ្ឈប់ការប្រើប្រាស់ទីតាំងជួល និង រើសម្ភារៈបរិក្ខាចេញក្នុងរយៈពេលយ៉ាងយូរ ០៧(ប្រាំពីរ)ថ្ងៃ។

៣.៣. **ប្រាក់កក់**

ភាគី "ខ" ត្រូវបង់ប្រាក់កក់ធានានៃការជួល ជូនភាគី "ក" តាមចំនួន និងលក្ខខណ្ឌដូចខាងក្រោម:







ប្រាក់កក់ចំនួន ៤៥០០ ដុល្លារ (បួនពាន់ប្រាំរយដុល្លារសហរដ្ឋអាមេរិកគត់) (ហៅថា "ប្រាក់កក់") ស្មើនឹងថ្លៃធានានៃការជួលផ្ទះ នៃកិច្ចព្រមព្រៀងនេះ។ ប្រាក់កក់នេះនឹងត្រូវប្រគល់ជូនភាគី "ខ" វិញក្រោយពេលក្រោយពេលបញ្ចប់កិច្ចព្រមព្រៀងនេះ ក្នុងករណីដូចខាងក្រោម ៖

ក. ភាគី "ខ" មិនបានបំពានលក្ខខណ្ឌណាមួយក្នុងកិច្ចព្រមព្រៀងនេះ។

ខ. បន្ទាប់ពីធ្វើការទូទាត់ថ្លៃទឹក អគ្គិសនី ប្រមូលសំរាមអនាម័យ ទូរទស្សន៍ខ្សែកាប អ៊ីនធើណេត សេវាថែទាំប្រចាំឆ្នាំ និងពន្ធផ្សេងៗទៀតដែលអាចនឹងមានក្នុងរយៈពេលជួល ហើយដែលជាបន្ទុករបស់ ភាគី "ខ" ហើយ ភាគី "ខ" បានរើចេញពីទីតាំងអចលនវត្ថុជួលនេះជាស្ថាពរ។ ប្រាក់កក់ចំនួន ៤៥០០ ដុល្លារ (បួនពាន់ប្រាំរយដុល្លារសហរដ្ឋអាមេរិកគត់) នេះអាចប្រើប្រាស់សំរាប់ការទូទាត់ថ្លៃជួសជុល ផ្ទះដែលខូចខាតដែលបង្កដោយភាគី "ខ" ហើយភាគី "ក" និងប្រគល់ជូនទៅភាគី"ខ" វិញនូវទឹកប្រាក់ដែលនៅសល់បន្ទាប់ពីភាគី"ខ" បានបំពេញកាតព្វកិច្ចរបស់ខ្លួនរួចរាល់។

**ប្រការ ៤: ថ្លៃចំណាយផ្សេងៗ**

ភាគី "ខ" យល់ព្រមទទួលបន្ទុកបង់ថ្លៃប្រើប្រាស់ទឹក អគ្គិសនី ប្រមូលសំរាមអនាម័យ ទូរទស្សន៍ខ្សែកាប អ៊ីនធើណេត សេវាថែទាំប្រចាំឆ្នាំ និង ចំណាយផ្សេងៗទៀត ដែលតម្រូវដោយ ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ឬ សមត្ថកិច្ច និងក្រុមហ៊ុនផ្តល់សេវាកម្មទាក់ទងនឹងការប្រើប្រាស់ ជួសជួល និងការកែលំអផ្ទះជួល ចាប់ពីថ្ងៃទទួលអចលនវត្ថុនេះ រហូតដល់ ពេលបញ្ចប់កិច្ចព្រមព្រៀងនេះ ។

**ប្រការ ៥: ពន្ធដារ និងអាករ**

ភាគី "ក" យល់ព្រម បង់ពន្ធអចលនទ្រព្យប្រចាំឆ្នាំ ចំពោះអចលនវត្ថុនេះតាមការកំណត់របស់ច្បាប់។

**ប្រការ ៦: ការចូលទៅកាន់ទីតាំងអចលនវត្ថុ**

៦.១: ក្នុងរយៈពេលជួលនេះ ភាគី "ក" មានសិទ្ធិចូលទៅកាន់ទីតាំងជួល ឬ ទីតាំងអចលនវត្ថុនេះ ដើម្បីពិនិត្យអំពីប្រក្រតីភាពនៃការកាន់កាប់ ប្រើប្រាស់ និងជួសជុលកែលំអរផ្សេងៗរបស់ភាគី "ខ" ។

៦.២. ភាគី "ក" ត្រូវជូនដំណឹងដល់ភាគី "ខ" ចំនួន ១ ម៉ោង មុនពេលចូលពិនិត្យទីតាំងអចលនវត្ថុ។

៦.៣. ភាគី "ខ" ឬ សាច់ញាតិរបស់ភាគី "ខ" ត្រូវសហការផ្តល់លទ្ធភាពឲ្យភាគី "ក" បានចូលពិនិត្យទីតាំងជួល ឬទីតាំងអចលនវត្ថុ តាមការស្នើសុំពីភាគី "ក" ។

**ប្រការ ៧: ការធានាអះអាង និងការទទួលខុសត្រូវរបស់ភាគី "ខ"**

៧.១. ប្រើប្រាស់ទីតាំងជួលអោយសមស្របតាមគោលបំណងនៃកិច្ចព្រមព្រៀងនេះ។ ក្នុងករណីរូបភាពណាក៏ដោយ មិនត្រូវប្រកបអាជីវកម្មណាមួយដែលខុសច្បាប់នៅលើទីតាំងជួលនេះឡើយ។ ភាគី "ខ" ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ រាល់សកម្មភាពខុសច្បាប់ទាំងឡាយ ប្រសិនបើមាន ។







៧.២. សុំការអនុញ្ញាតិជាលាយលក្ខណ៍អក្សរពី ភាគី "ក" និងអាជ្ញាធរពាក់ព័ន្ធ ចំពោះការសាងសង់ថ្មី ឬ ការកែលំអរ បន្ថែមទៅលើអចលនវត្ថុនេះ ភាគី"ខ" ត្រូវទទួលខុសត្រូវទាំងស្រុងចំពោះ ចំណាយទាំងឡាយក្នុងការសាងសង់នេះ។ ក្នុងករណីមិនមានការអនុញ្ញាតពី ភាគី "ក" និងអាជ្ញាធរពាក់ព័ន្ធ ភាគី "ខ" មិនអាចធ្វើ ការសាងសង់អ្វីទាំងអស់។ បើភាគី "ខ" មិនអនុវត្ត តាមប្រការនេះ ភាគី "ខ" ត្រូវទទួល ខុសត្រូវចំពោះ មុខច្បាប់ និងថ្លៃរុះរើសំណង់ដែលគ្មានការអនុញ្ញាត ព្រមទាំងការខូចខាតផ្សេងៗទៀត ដែលមាន ។

៧.៣. ថែរក្សាទីតាំងជួលនេះអោយបានល្អ និងទទួលខុសត្រូវផ្ទាល់ខ្លួន រាល់គ្រោះថ្នាក់ណាមួយដែលអាចនឹងកើតឡើង ឬការបង្កគ្រោះថ្នាក់ជាយថាហេតុ ដល់អ្នកដទៃ ឬ អ្នកជិតខាងរបស់ខ្លួន ដែលកើតឡើងពីការធ្វេសប្រហែសរបស់ខ្លួនក្នុងរយៈពេលជួសជុល និងរយៈពេលជួលនៃកិច្ចព្រមព្រៀងនេះ ហើយធានាថាខ្លួននឹងទទួលខុសត្រូវចេញមុខដោះស្រាយ គ្រប់ហេតុការណ៍ដែល នឹងកើតឡើងជាយថាហេតុ ដោយមិនអោយពាក់ព័ន្ធនឹងភាគី "ក" ឡើយ ។

៧.៤. ត្រូវប្រគល់នូវរាល់សម្ភារៈដែលបានចុះក្នុងឧបសម្ព័ន្ធ "១" ក្នុងលក្ខណៈនៅល្អ លើកលែងតែមានការសឹករិចរិល និងខូចខាតបាក់បែកដោយធម្មជាតិ ឬ ខ្ទេចខ្ទាំ ។ ភាគី "ខ" ត្រូវសំអាតអចលនវត្ថុ និងសម្ភារៈដែលបានចុះក្នុងឧបសម្ព័ន្ធ "១" មុនពេលបញ្ចប់ ឬ បញ្ចប់កិច្ចព្រមព្រៀងនេះ។

៧.៥. គោរពតាមច្បាប់ និងបទប្បញ្ញត្តិផ្នែកបរិស្ថាន សុខភាព អនាម័យ សន្តិសុខ និងសុវត្ថិភាព ដែលមានជាធរមាន។

៧.៦. មិនត្រូវជួលបន្តអចលនវត្ថុនេះបន្តទៅអោយតតិយជន ឬ អ្នកផ្សេងដោយមិនមានការយល់ព្រមពីភាគី "ក" ជាដាច់ខាត។

**ប្រការ ៨: ការធានាអះអាង និងការទទួលខុសត្រូវរបស់ភាគី "ក"**

៨.១. ខ្លួនគឺជាកម្មសិទ្ធិករស្របច្បាប់នៃអចលនវត្ថុដែលជួលអោយភាគី"ខ" នេះ និងធានាអះអាងថាខ្លួន មានសិទ្ធិគ្រប់គ្រាន់តាមផ្លូវច្បាប់ក្នុងការចុះហត្ថលេខា ឬ ផ្តិតមេដៃអនុវត្តកិច្ចព្រមព្រៀងនេះ ។

៨.២. ក្នុងរយៈពេលជួលនៃកិច្ចព្រមព្រៀងនេះ ភាគី "ក" មិនអាចលក់អចលនវត្ថុនេះ ទៅអោយតតិយជន ឬអ្នកផ្សេងបានទេ ។ ក្នុងករណីភាគី "ក" មានបំណងចង់លក់អចលនវត្ថុនេះទៅអោយតតិយជន ឬ អ្នកផ្សេង ភាគី "ក" ត្រូវបង់ប្រាក់កក់ឲ្យភាគី "ខ" ដូចដែលមានចែងក្នុង ប្រការ៣ ចំណុច ៣.៣ នៃកិច្ចព្រមព្រៀងនេះ ។

**ប្រការ ៩: ការបញ្ចប់ និងការបន្តជួល**

៩.១. កិច្ចព្រមព្រៀងនេះ នឹងត្រូវបញ្ចប់នៅកាលបរិច្ឆេទដូចមានចែងក្នុង ប្រការ ២ ចំនុច ២.១ និង ២.២ ខាងលើ នៃកិច្ចព្រមព្រៀងនេះ លើកលែងតែមានការបន្តការជួល ។ ប្រសិនបើភាគី "ខ" មានបំណងបន្តកិច្ចព្រមព្រៀងនេះ ត្រូវជូនដំណឹងទៅភាគី "ក" អំពីបំណងបន្ត និងលក្ខខណ្ឌបន្តអោយបាន ០២(ពីរ)ខែ

មុនកាលបរិច្ឆេទបញ្ចប់នៃកិច្ចព្រមព្រៀងនេះ ។ ភាគី "ក" ត្រូវឆ្លើយតបនូវបំណងជួល ឬ មិនជួល បន្តក្នុងរយៈពេល ០១ (មួយ)ខែ គិតចាប់ពីថ្ងៃបានទទួលបានលិខិតជូនដំណឹងជាលាយលក្ខអក្សរពីភាគី "ខ" ។

៩.២. ពេលបញ្ចប់រយៈពេលជួល ភាគី "ខ" ត្រូវរុះរើចេញរាល់សម្ភារៈ ឧបករណ៍ដែលតាំងភ្ជាប់នឹងអចលនវត្ថុ និងសំអាតអចលនវត្ថុ(ផ្ទះ) នេះ អោយរួចរាល់ជាស្ថាពរ ក្នុងរយៈពេល ០៧ (ប្រាំពីរ)ថ្ងៃ ឬ មុនកាលបរិច្ឆេទបញ្ចប់កិច្ចព្រមព្រៀងនេះ ។

៩.៣. កិច្ចព្រមព្រៀងនេះ អាចត្រូវបានរំលាយមុនកាលបរិច្ឆេទបញ្ចប់ខាងលើដោយភាគី "ក" ហើយប្រាក់កក់ធានាជួល នឹងត្រូវទុកជារបស់ភាគី "ក" ក្នុងករណីមានកំហុសរបស់ភាគី "ខ" ដូចខាងក្រោម ៖

(i) ភាគី "ខ" មិនបានបង់ប្រាក់ឈ្នួលតាមពេលកំណត់រយៈពេល ០២ (ពីរ) ខែជាប់គ្នា ។

(ii) ភាគី "ខ" បានបំពានលក្ខខណ្ឌធ្ងន់ធ្ងរនៃកិច្ចព្រមព្រៀងនេះ ។

៩.៤. លើកលែងតែករណីដែលបានរៀបរាប់ខាងលើពីប្រការ ៩.២ ដល់ ៩.៣ កិច្ចព្រមព្រៀងនេះមិនអាចត្រូវបានបញ្ចប់មុនកាលបរិច្ឆេទ ដោយគ្មានការព្រមព្រៀងជាលាយលក្ខណ៍អក្សររវាងគូភាគីនៃកិច្ចព្រមព្រៀងនេះបានឡើយ ។

៩.៥. នៅពេលបញ្ចប់កិច្ចព្រមព្រៀងនេះ ឬ កិច្ចព្រមព្រៀងនេះត្រូវបានបញ្ចប់មុនកាលកំណត់ ភាគី "ខ" ត្រូវរើយកចេញនូវសម្ភារៈបរិក្ខា ដែលមិនភ្ជាប់នឹងអគារ ដែលមានសម្រាប់ប្រើប្រាស់ក្នុងរយៈពេល ជួលដែលជារបស់ខ្លួន ។ ក្នុងករណី ភាគី "ខ" មិនបានរើយកចេញក្នុងរយៈពេល ៥(ប្រាំ) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទបញ្ចប់កិច្ចព្រមព្រៀង មានន័យថា ភាគី "ខ" យល់ព្រមបោះបង់ចោលសម្ភារៈ ទាំងនេះ ហើយភាគី "ក" មានសិទ្ធិពេញលេញក្នុងការចាត់ចែងសម្ភារៈបរិក្ខារទាំងនោះ ។

**ប្រការ ១០: បញ្ញត្តិផ្សេងៗ**

**១០.១. ដំណោះស្រាយវិវាទ**

ប្រសិនបើមានវិវាទណាមួយកើតមានឡើង ឬ ពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងនេះ ចំពោះការបកស្រាយការអនុវត្ត កិច្ចព្រមព្រៀងនេះ ឬ ចំពោះសិទ្ធិ ករណីកិច្ច ឬ ការទទួលខុសត្រូវរបស់ភាគីណាមួយ ឬ ចំពោះបញ្ហាផ្សេងទៀតដែល កើតមានឡើង ឬ មានទំនាក់ទំនងនឹងកិច្ចព្រមព្រៀងនេះ គូភាគីត្រូវ សហការគ្នាដោះស្រាយវិវាទដោយសន្តិវិធី ។ បន្ទាប់ពីរយៈពេល ០៤(បួន)សប្តាហ៍ ក្រោយពីបានទទួលការជូនដំណឹងពីវិវាទ ប្រសិនបើគូភាគីមិនអាចដោះស្រាយវិវាទបានទេនោះ ភាគីណាមួយ អាចដាក់ពាក្យបណ្តឹងទៅតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា ។

**១០.២. កិច្ចព្រមព្រៀងទាំងមូល**

កិច្ចព្រមព្រៀងនេះ រាប់បញ្ចូលការព្រមព្រៀងទាំងមូលរបស់គូភាគី ហើយមិនអាចធ្វើការកែប្រែបានឡើយនៅ







ក្នុងករណីលើកលែងតែត្រូវបានធ្វើឡើងជាលាយលក្ខអក្សរ និងចុះហត្ថលេខាទទួលស្គាល់ដោយភាគីក្នុងកិច្ចព្រមស្គាល់ដោយគូភាគី ក្នុងកិច្ចព្រមព្រៀងនេះ ។

**១០.៣. ទាយាទ និងអនុប្បទានិក**

កិច្ចព្រមព្រៀងនេះ ចងភ្ជាប់កាតព្វកិច្ចចំពោះ ទាយាទ អនុប្បទានិក និង សន្តតិជន ក្នុងផលប្រយោជន៍របស់ភាគី "ក" និង ភាគី "ខ" ។

**១០.៤. ភាសា និងការតម្កល់កិច្ចព្រមព្រៀង**

កិច្ចព្រមព្រៀងនេះ ត្រូវគ្រប់គ្រងដោយ ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងធ្វើឡើងជាភាសាខ្មែរ ចំនួន ០៣(បី)ច្បាប់

- ភាគី ក រក្សាទុក ០១(មួយ) ច្បាប់
- ភាគី ខ រក្សាទុក ០១(មួយ) ច្បាប់
- មេធាវី នៃក្រុមហ៊ុន ទុក ០១(មួយ) ច្បាប់។

ដើម្បីជាសក្ខីកម្ម គូភាគីយល់ព្រមផ្តិតស្នាមមេដៃស្តាំរបស់ខ្លួន ដើម្បីទទួលអនុវត្តតាមរាល់ខ្លឹមសារ និង លក្ខខណ្ឌទាំងឡាយដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះ នៅចំពោះមុខសាក្សី ។

ស្នាមមេដៃស្តាំ ភាគី "ក" | ស្នាមមេដៃស្តាំ ភាគី "ខ"





សូមបញ្ជាក់ថា
គូភាគីពិតជាបាន
ផ្តិតស្នាមមេដៃស្តាំនៅចំពោះមុខមេធាវីប្រាកដមែន
រាជធានីភ្នំពេញ, ថ្ងៃទី ខែ... ឆ្នាំ
ហត្ថលេខា និងត្រា

## ឧបសម្ព័ន្ធ "ក"

- សាឡុងឈើ ១ឈុត
- ម៉ាស៊ីនត្រជាក់ និង តេឡេបញ្ជា ៩ ឈុត
- ទូរតាំងភ្ជាប់នឹងជញ្ជាំង១គ្រឿង
- ទូរខោអាវភ្ជាប់ជញ្ជាំង១
- ទូរចង្ក្រានបាយ១



៤

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ

ខ្ញុំបាទ ភេទប្រុស ជនជាតិខ្មែរ សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខៈ មានទីលំនៅបច្ចុប្បន្ន ក្រុមទី ភូមិ ឃុំ ស្រុក ខេត្ត ។

## សូមប្រគល់សិទ្ធិជូន

លោកមេធាវី អត្តលេខៈ ជាសមាជិកមេធាវីនៃ មានការិយាល័យស្ថិតនៅអាគារលេខ ១ផ្លូវលេខ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ដើម្បីធ្វើជាមេធាវីតំណាងដោយអាណត្តិឲ្យខ្ញុំបាទនៅក្នុងសំណុំរឿងរដ្ឋប្បវេណីលេខៈ......... ចុះថ្ងៃទី.២០.... ខែ......... ឆ្នាំ២០១១... របស់តុលាការកំពូល។

*បញ្ជាក់៖ រាល់ការចំណាយលើការបង់ពន្ធ ឬ ការចំណាយផ្សេងៗ ពាក់ព័ន្ធទៅនឹងរឿងក្ដី ជាបន្ទុករបស់អ្នកប្រគល់សិទ្ធិ។ ក្នុងករណីអ្នកប្រគល់សិទ្ធិមិនបានគោរពកាតព្វកិច្ចនេះ យើងខ្ញុំមិនទទួលខុសត្រូវនូវរាល់ការខាតបង់ផលប្រយោជន៍នានាដោយខ្លួនឯង។*

លោក មេធាវី ដែលបានទទួលសិទ្ធិធ្វើជាមេធាវីតំណាងដោយអាណត្តិ មានសិទ្ធិអំណាចធ្វើជំនួសនូវរាល់ បណ្ដឹងដែលពាក់ព័ន្ធក្នុងរឿងក្ដី និងធ្វើនូវរាល់សកម្មភាពដែលស្របទៅនឹងស្មារតី នៃក្រមនីតិវិធីរដ្ឋប្បវេណី ចាប់ពីថ្ងៃ ដែលខ្ញុំបាទបានផ្ដិតម្រាមដៃនេះតទៅ។

ធ្វើនៅ..... ......,ថ្ងៃទី ខែ ឆ្នាំ

ស្នាមម្រាមដៃ

**បានឃើញ និងយល់ព្រម**

ថ្ងៃ......... ខែ......... ឆ្នាំ......... ព.ស.........

រាជធានីភ្នំពេញ,ថ្ងៃទី...... ខែ...... ឆ្នាំ២០១២

មេធាវី ហត្ថលេខា និងត្រា

AVOCAT

KINGDOM OF

INTERNATIONAL
ក្រុមហ៊ុនមេធាវី ជីជី អន្តរជាតិ
GG International Law Firm

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

## កិច្ចព្រមព្រៀងម៉ៅការសាងសង់ និងរៀបឥដ្ឋ

កិច្ចព្រមព្រៀងនេះធ្វើឡើងនៅរាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២០

**រវាង**

**ភាគី "ក"** ៖ ដែលតំណាងដោយលោកមេធាវី មាន អាសយដ្ឋាននៅផ្ទះលេខ ពេ ភូមិ សង្កាត់ ក្រុង ខេត្ត ជាម្ចាស់ អចលនវត្ថុ ដែលតទៅនេះហៅថាម្ចាស់សំណង់ ឬ **ភាគី "ក"** ។

**និង**

**ភាគី "ខ"** ៖ ឈ្មោះ ភេទប្រុស ថ្ងៃខែឆ្នាំកំណើត សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណ ប័ណ្ណលេខ: ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៥ ដែលមានអាសយដ្ឋានស្ថិតនៅ ភូមិពេង ឃុំ ស្រុក ខេត្ត ដែលចាប់ពីពេលនេះតទៅហៅថា អ្នកទទួល ម៉ៅការសាងសង់ និងរៀបឥដ្ឋ ឬ **ភាគី "ខ"** ។

**កម្មវត្ថុ ៖**

ដោយហេតុថា ភាគី "ក" បានព្រមព្រៀងប្រគល់ប្រាក់ចំនួន <u>USD ៥៤០០ (ប្រាំពាន់បួនរយហាសិបដុល្លារអាមេរិក)</u> ទៅ ភាគី "ខ" រយៈពេលបំពេញការងារមួយចប់ម៉ៅការសាងសង់ និងរៀបឥដ្ឋ ។

ដោយហេតុថា ភាគី "ខ" ទទួលម៉ៅការសាងសង់ និងរៀបឥដ្ឋ បានព្រមព្រៀង ទទួលប្រាក់ចំនួន <u>USD ៥៤០០ (ប្រាំពាន់បួនរយហាសិបដុល្លារអាមេរិក)</u> ពី ភាគី "ក" ជាថ្លៃឈ្នួលម៉ៅការសាងសង់ ដោយកំណត់យករយៈពេលយ៉ាងយូរបំផុត ០២ ខែ ធ្វើចប់ជាស្ថាពរ ១០០% ជូន ភាគី "ក" ។

**ភាគីទាំងពីរបានព្រមព្រៀងគ្នាចុះកិច្ចព្រមព្រៀងដែលមានខ្លឹមសារនិងលក្ខខណ្ឌដូចខាងក្រោម៖**

**ប្រការ១៖ កម្មវត្ថុ**

ភាគី "ក" មានបំណងចង់សាងសង់ និងរៀបឥដ្ឋអាគារជាន់ទី២ នៃ ដែលមាន អាស័យដ្ឋាន ផ្ទះលេខ ០ ផ្លូវលេខ សង្កាត់ ខណ្ឌ ប រាជធានី ក្នុងតម្លៃម៉ៅ


GG International Law Office
Registered under the Bar Association of the Kingdom of Cambodia
# 224D Street 20, Prek Talong Village, Sangkat Chak Angre Kroam, Khan Mean Chey, Phnom Penh, Cambodia
Phone: +855 93 333 626 . E-mail: official@ggi.law . web: www.ggi.law

ការសរុប ៥៤០០០$ (ប្រាំពាន់បួនរយដុល្លារអាមេរិក) ហើយ ភាគី "ខ" យល់ព្រមទទួលម៉ៅការសាងសង់ និងរៀបឥដ្ឋ ដោយគោរព និងអនុវត្តតាមកិច្ចព្រមព្រៀងនេះ។

**ប្រការ២៖ ការទទួលខុសត្រូវរបស់ភាគី "ខ" និងបច្ចេកទេសក្នុងការសាងសង់**

ភាគី "ខ" យល់ព្រមជាមួយ ភាគី "ក" ក្នុងការទទួលម៉ៅការសាងសង់ និងរៀបឥដ្ឋ តាមកម្មវត្ថុខាងលើ ដែលត្រូវមានលក្ខខណ្ឌបច្ចេកទេសដូចខាងក្រោម៖

១. រៀបឥដ្ឋ ១០ ទំហំសរុប ២៥០.៧៥ ម៉ែត្រការ៉េ

២. រៀបឥដ្ឋ ចេញជាបន្ទប់ ៣ ធំៗ និងបន្ទប់ទឹក ៣ ដោយត្រូវរៀបឥដ្ឋ

៣. ការងារបន្ទប់ទឹក ជាងត្រូវរៀបចំចំនួនពីរបន្ទប់ គឺរៀបចំប្រព័ន្ធទឹក នឹងរៀបឥដ្ឋបាត ហើយសម្ភារៈបន្ទប់ទឹក ភាគី "ក" ជាអ្នកទិញអោយ បូករួមនឹងស៊ីម៉ង់ មិនលើសពីប្រាំបាវ

៤. បូកជញ្ជាំងនៅគ្រប់កន្លែងដែលរៀបឥដ្ឋ បូកត្រូវប្រើស៊ីម៉ង់ ខេស៊ីមិន បូក និងសី ត្រូវស្មើសាច់ល្អមិនមានទឹករលក

៥. វាយប្រអប់ជណ្ដើរដែលមានស្រាប់ និងកែសម្រួលប្រអប់ទ្វារ ប៉ុន្តែមិនបូកបង្កាន់ដៃ

៦. រៀបចំបូកជ្រុងសសរ ជ្រុងធ្នឹម ទាំងអស់ដែលមាន

៧. ដឹកកម្ទេចថ្មចេញ និងសម្អាតទីតាំងក្រោយពេលសាងសង់រួច

៨. បូកវែចង្ក្រានបាយនឹងរៀបឥដ្ឋអាគារការិយាល័យ

ភាគី "ខ" ត្រូវទទួលខុសត្រូវ និងគ្រប់គ្រងកម្មករស្នាក់នៅ

ភាគី "ខ" មានកាតព្វកិច្ចថែរក្សាលើការគ្រប់គ្រងសម្ភារៈសំណង់ទាំងអស់ដោយខ្លួនឯង

ភាគី "ខ" ត្រូវធានាថាបច្ចេកទេសសាងសង់ដែលបានចែងក្នុងកិច្ចព្រមព្រៀងនេះត្រូវបានគោរព។ ក្នុងករណី ដែលភាគី "ក" រកឃើញថាភាគី "ខ" បានសាងសង់ដោយប្រើប្រាស់សម្ភារៈ និងបច្ចេកទេសសាងសង់ខុសពីក្នុងកិច្ចព្រមព្រៀងនេះ នោះភាគី "ខ" ត្រូវផ្លាស់ប្តូរសម្ភារៈ ឬបច្ចេកទេសនោះភ្លាមអោយបានត្រឹមត្រូវតាមការសន្យា បើមិនដូចនោះទេ ភាគី "ខ" ត្រូវសងប្រាក់ ១ គុណនឹង ២ នៃប្រាក់ដែលខ្លួនបានទទួលរួចពីភាគី "ក" ហើយ ភាគី "ក" មានសិទ្ធិបញ្ឈប់ការសាងសង់ និងរំលាយកិច្ចព្រមព្រៀងនេះភ្លាម។

ក្នុងករណីការសាងសង់មានលក្ខណៈខុសបច្ចេកទេស ភាគី "ខ" ត្រូវទទួលខុសត្រូវទាំងស្រុងនូវការខូចខាតនានាដែលកើតចេញពីកំហុសរបស់ខ្លួន (ឧទាហរណ៍ ករណីស្រុត ប្រេះ អាគារ ឬបាក់រលំជាដើម)។ ប៉ុន្តែក្នុងករណី ស្រុតអាគារ ឬបាក់រលំ ដោយសារកំហុសគ្រឹះជាន់ផ្ទាល់ដី នោះមិនមែនជាកំហុសរបស់ភាគី "ខ" ឡើយ ។

**ប្រការ៣៖ រយៈពេលធ្វើ**

ភាគី "ខ" ត្រូវបំពេញការងារដែលទទួលម៉ៅការសាងសង់ឲ្យរួចរាល់ជាស្ថាពរ ១០០% ក្នុងរយៈពេលកំណត់យ៉ាងយូរបំផុត ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២០ ។



GG International Law Office
Registered under the Bar Association of the Kingdom of Cambodia
# 224D Street 20, Prek Talong Village, Sangkat Chak Angre Kroam, Khan Mean Chey, Phnom Penh, Cambodia
Phone: +855 93 333 626 . E-mail: official.@gil.law . web: www.gil.law

**ប្រការ៥៖ ដំណាក់កាលនៃការបង់ប្រាក់ម៉ៅការសាងសង់ និងរៀបឥដ្ឋ**

គូភាគី បានព្រមព្រៀងគ្នាក្នុងការបង់ប្រាក់ថ្លៃម៉ៅការសាងសង់ និងរៀបឥដ្ឋ ជា៣ ដំណាក់កាលដូចខាងក្រោម៖

ដំណាក់កាលទី១: ភាគី "ក" ត្រូវបង់ចំនួន ២០០០ USD (ពីរពាន់ដុល្លារអាមេរិក) ជាប្រាក់កក់ទៅអោយភាគី "ខ" នៅពេលគូភាគីចុះកិច្ចសន្យានេះ ។

ដំណាក់កាលទី២: ភាគី "ក" ត្រូវបង់ចំនួន ១៤០០ USD (មួយពាន់បួនរយដុល្លារអាមេរិក) ទៅអោយភាគី "ខ" នៅពេលសាងសង់អាគារបានហាសិបភាគរយ នៃការងារម៉ៅការសាងសង់ ។

ដំណាក់កាលទី៣: ភាគី "ក" ត្រូវបង់ចំនួន ២០០០ USD (ពីរពាន់ដុល្លារអាមេរិក) ទៅអោយភាគី "ខ" នៅពេលសាងសង់បានរួចរាល់មួយភាគរយ និងស្របតាមលក្ខខណ្ឌបច្ចេកទេសនានាដែលគូភាគីបានព្រមព្រៀងគ្នា។

**ប្រការ៦៖ ការងារបន្ថែម**

គូភាគី បានព្រមព្រៀងគ្នាថាការងារបន្ថែម ភាគី "ក" ត្រូវបន្ថែមអោយភាគី "ខ" ចំនួន ៦៣៨ USD (ប្រាំមួយរយសាមសិបប្រាំបីដុល្លាអាមេរិក) ។ ការងារនេះភាគី "ខ" គិតលើសេវាការងាររៀបឥដ្ឋលើបន្ទប់ទឹក មួយទៀត និងការងារបន្ថែមផ្សេងៗ។

**ប្រការ៧៖ ឯកសារតម្កល់ និងភាសាផ្លូវការ**

កិច្ចសន្យានេះធ្វើឡើងជាភាសាខ្មែរ ចំនួន០២ (ពីរ) ច្បាប់ដើម សម្រាប់ភាគីនីមួយៗម្នាក់មួយច្បាប់ ។ ដោយមួយច្បាប់ដើមរក្សាទុកនៅភាគី "ក" មួយច្បាប់ដើម, រក្សាទុកនៅភាគី "ខ" មួយច្បាប់ដើម ។

**ប្រការ៨៖ អនុភាពអនុវត្ត**

កិច្ចសន្យានេះមានអនុភាពអនុវត្ត ចាប់ពីពេលគូភាគី បានផ្តិតម្រាមដៃស្តាំ នៅចំពោះមុខសាក្សីជាកសិណ បន្ទាប់ពីភាគីនីមួយៗ បានអាន បានពិនិត្យយ៉ាងល្អិតល្អន់ និងបានយល់ព្រម គ្រប់ប្រការទាំងអស់នេះអត្ថបទនៃកិច្ចសន្យាខាងលើ។

រាជធានីភ្នំពេញថ្ងៃទី ១ ខែ .. ឆ្នាំ ១

**ស្នាមម្រាមដៃស្តាំ**

**ភាគី "ក"** **ភាគី "ខ"**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**<u>កិច្ចសន្យាការងារ</u>**

កិច្ចសន្យាការងារនេះធ្វើឡើងរវាងសហគ្រាស/គ្រឹះស្ថាន/ក្រុមហ៊ុន.......................................................... ហៅថាភាគី "ក" និង.......................................................................................... ភេទ................ ហៅថាភាគី "ខ"

ដោយហេតុថា: -ភាគី "ខ" បានដាក់ពាក្យស្នើសុំធ្វើការនៅក្នុងសហគ្រាស/គ្រឹះស្ថាន ក្រុមហ៊ុន របស់ភាគី "ក"

-ហើយភាគី "ក" ក៏យល់ព្រមទទួលយកភាគី "ខ" ឲ្យចូលបម្រើការងារដោយមានការអនុញ្ញាតឲ្យប្រើប្រាស់ហត្ថពលកម្មបរទេស ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-និងយោងទៅតាមលក្ខខណ្ឌការងារមួយចំនួន នៃច្បាប់ស្តីពីការងារ ដូចខាងក្រោម៖

**១.គោលបំណង:** កិច្ចសន្យាការងារនេះ ត្រូវបានធ្វើឡើងដោយមានការយល់ព្រមទាំងទ្វេភាគី គឺ ភាគី "ក" និងភាគី "ខ" ។ ខ្លឹមសារនៃកិច្ចសន្យាការងារនេះ ចែងអំពីលក្ខខណ្ឌការងារមួយចំនួន ស្របតាមច្បាប់ស្តីពីការងារ នៃព្រះរាជាណាចក្រកម្ពុជា ។

**២.មុខងារ:** នៅក្នុងកិច្ចសន្យាការងារនេះ ភាគី "ខ" មានមុខងារ និងតួនាទី ជា.......................................................... ហើយប្រសិនបើមានការផ្លាស់ប្តូរមុខងារនេះ វាអាស្រ័យទៅតាមការយល់ព្រម ទាំងទ្វេភាគី គឺ ភាគី "ក" និងភាគី "ខ" ។

**៣.ទីកន្លែងធ្វើការ:** សហគ្រាស/គ្រឹះស្ថាន/ក្រុមហ៊ុន មានទីតាំងស្ថិតនៅ ផ្លូវ.............ភូមិ.................សង្កាត់.................... ខណ្ឌ....................... រាជធានីភ្នំពេញ ។ ភាគី "ក" មិនត្រូវចាត់បញ្ជូនភាគី "ខ" អោយទៅធ្វើការនៅកន្លែងដែលមានគ្រោះថ្នាក់ដល់អាយុជីវិតដោយគ្មានការយល់ព្រមពីភាគី "ខ" ឡើយ ។

**៤.ថិរវេលានៃកិច្ចសន្យាការងារ:** ដោយយោងតាមច្បាប់ស្តីពីការងារ កិច្ចសន្យាការងារនេះមានរយៈពេលមិនលើស ពីរឆ្នាំ (២ឆ្នាំ) ដោយគិតចាប់ពី ថ្ងៃទី.........ខែ.....................ឆ្នាំ........... រហូតដល់ ថ្ងៃទី..........ខែ.....................ឆ្នាំ...........។

**៥.ប្រាក់ឈ្នួល:** ភាគី "ក" ត្រូវបើកប្រាក់បៀវត្សរ៍អោយភាគី "ខ" តាមកាលបរិច្ឆេទដែលបានកំណត់ មិនត្រូវយកមូលហេតុផ្សេងដើម្បីធ្វើការពន្យារពេលនៃការបើកប្រាក់បៀវត្សរ៍ ឬមិនបើកអោយនោះឡើយ។ ភាគី "ខ" ទទួលបានប្រាក់បៀវត្សរ៍ចំនួន........... ......................................(......................$)ក្នុងមួយខែ ហើយការតម្លើងប្រាក់បៀវត្សរ៍ វាអាស្រ័យទៅតាមសមត្ថភាពបំពេញការងាររបស់ ភាគី "ខ" និងអាស្រ័យទៅតាមសេចក្តីសម្រេចរបស់ ភាគី "ក" ផងដែរ ។

**៦.ម៉ោងការងារ:** ថិរវេលាធ្វើការពេញលេញនៃកម្មករនិយោជិតទាំងពីរភេទមិនត្រូវលើសពី ប្រាំបីម៉ោងក្នុងមួយថ្ងៃ ឬសែសិបប្រាំបីម៉ោង ក្នុងមួយសប្តាហ៍ ។ ចំពោះម៉ោងការងារ ឬការឈប់សម្រាកផ្សេងៗ ត្រូវគោរពតាមវិធាននានា ដែលមានចែងនៅក្នុងច្បាប់ ស្តីពី ការងារ និង ច្បាប់ ផ្សេងៗទៀតរបស់ព្រះរាជាណាចក្រកម្ពុជា ។

**៧.ភារកិច្ច:** ភាគី "ខ" ត្រូវគោរពការដឹកនាំ និងការចាត់ចែងរបស់ភាគី "ក" អនុវត្តឲ្យបានល្អ តាមបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស/គ្រឹះស្ថាន/ក្រុមហ៊ុន គោរពច្បាប់ស្តីពីការងារ គោរពតាមទំនៀមទំលាប់ប្រពៃណីដ៏ល្អរបស់ប្រជាជនមូលដ្ឋាន និងមិនចូលរួមរាល់សកម្មភាពរបស់អង្គការនយោបាយណាមួយឡើយ ។ ភាគី "ខ" ត្រូវគោរព និងធ្វើតាមការណែនាំរបស់ភាគី "ក" ក្នុងការបំពេញឯកសារមួយចំនួនដើម្បីស្នើសុំធ្វើ ឬពន្យាសៀវភៅការងារ និងប័ណ្ណការងារជនបរទេស ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ភាគី "ខ" មិនត្រូវនិយាយ ឬលាតត្រដាង ការសម្ងាត់ណាមួយនៅ ព្រះរាជាណាចក្រកម្ពុជា ។

ភាគី "ក" ធានាជម្រុញឲ្យ ភាគី "ខ" ធ្វើ ឬពន្យារសៀវភៅការងារ និងប័ណ្ណការងារជនបរទេស ជារៀងរាល់ឆ្នាំ ។ ភាគី "ក" មានសិទ្ធិបញ្ឈប់ ភាគី "ខ" ក្នុងករណី ភាគី "ខ" មិនគោរពកិច្ចសន្យាការងារនេះ មិនគោរពតាមច្បាប់ស្តីពីការងារ និងច្បាប់ចូលជាធរមានដទៃទៀត នៃព្រះរាជាណាចក្រកម្ពុជា ។

**៨.ការឈប់សម្រាក:** ភាគី "ក" និងភាគី "ខ" ត្រូវតែគោរពតាម ការឈប់សម្រាកប្រចាំសប្តាហ៍ សម្រាកថ្ងៃបុណ្យ សម្រាកប្រចាំឆ្នាំ និងការឈប់សម្រាកពិសេសរបស់ច្បាប់ស្តីពីការងារ នៃព្រះរាជាណាចក្រកម្ពុជា ។ ហើយថែមពីលើនេះ ភាគី "ខ" មានសិទ្ធិឈប់សម្រាកព្យាបាលជម្ងឺ ដោយមិនត្រូវបានកាត់ប្រាក់បៀវត្សរ៍ ដែលមានការបញ្ជាក់ពីគ្រូពេទ្យបញ្ជាក់យ៉ាងត្រឹមត្រូវនោះទេ។

ក្នុងករណីជម្ងឺ ទាមទារការព្យាបាលយូរអង្វែង ភាគី "ក" មានសិទ្ធិបញ្ឈប់ ភាគី "ខ" ពីការងារ ហើយផ្តល់សំបុត្រយន្តហោះត្រឡប់ទៅប្រទេសដើមវិញ ។

**៩.ការបញ្ចប់កិច្ចសន្យាការងារដោយភាគី "ក":** ការរំលាយកិច្ចសន្យាការងារដោយឆន្ទៈរបស់ ភាគី "ក" តែឯកឯង ត្រូវបើកសិទ្ធិឲ្យ ភាគី "ខ" ទទួលជម្ងឺចិត្ត ដែលមានចំនួនយ៉ាងតិចស្មើនិងប្រាក់ឈ្នួលដែល ភាគី "ខ" ត្រូវបានទទួលដល់ពេលចប់កិច្ចសន្យាការងារ ។

**១០.ការបញ្ចប់កិច្ចសន្យាការងារដោយភាគី "ខ":** ការរំលាយកិច្ចសន្យាការងារដោយឆន្ទៈរបស់ ភាគី "ខ" តែឯកឯង ត្រូវបើកសិទ្ធិឲ្យ ភាគី "ក" ទទួលជម្ងឺចិត្តស្មើនឹងការខូចខាតរបស់ខ្លួនដែលបានផ្តល់ឲ្យ ភាគី "ខ" ។

**១១.ដំណោះស្រាយជម្លោះ:** រាល់លក្ខ័ណ្ឌការងារផ្សេងៗទៀត ដែលមិនបានបញ្ជាក់ច្បាស់លាស់នៅក្នុងកិច្ចសន្យាការងារនេះ ត្រូវគ្រប់គ្រងដោយបទបញ្ជាផ្ទៃក្នុងរបស់ សហគ្រាស/គ្រឹះស្ថាន/ក្រុមហ៊ុន ច្បាប់ស្តីពីការងារ និងច្បាប់ផ្សេងៗទៀត នៃព្រះរាជាណាចក្រកម្ពុជា ។ រាល់ទំនាស់ដែលកើតមានឡើងដល់ភាគីទាំងពីរ ត្រូវបញ្ជូនទៅដោះស្រាយ នៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។ ក្នុងករណីមិនអាចដោះស្រាយបាន ត្រូវបញ្ជូនទៅតុលាការ ដើម្បីធ្វើការកាត់សេចក្តីតាមច្បាប់ជាធរមាន ។

**១២.សេចក្តីបញ្ចប់:** កិច្ចសន្យាការងារនេះអាចបញ្ចប់ ឬបន្តបានល្គឹកណាតែមានការយល់ព្រមទាំងទ្វេរភាគី ។ ភាគី "ក" ត្រូវជូនដំណឹងទៅ ភាគី "ខ" មុនដប់ប្រាំថ្ងៃ (១៥ថ្ងៃ) ដើម្បីធ្វើការបញ្ចប់ ឬបន្តឡើងវិញនៃកិច្ចសន្យាការងារនេះ ។ នេះជាកិច្ចសន្យាការងារតែមួយគត់ដែលភាគីទាំងពីរត្រូវគោរព ហើយយល់ព្រមបដិសេធចោលនូវកិច្ចព្រមព្រៀងដោយផ្ទាល់មាត់ ឬជាលាយល័ក្ខអក្សរណាដែលមានពីមុន ។ ភាគីនីមួយៗ ត្រូវបានផ្តល់ជូននូវកិច្ចសន្យាការងារនេះ ម្នាក់មួយច្បាប់ ដើម្បីរក្សាទុកជាឯកសារសម្រាប់អនុវត្ត ។

កិច្ចសន្យាការងារនេះមានប្រសិទ្ធិភាព ចាប់ពីថ្ងៃ ចុះហត្ថលេខា នេះតទៅ ។

| | |
|---|---|
| ហត្ថលេខា និងត្រារបស់ម្ចាស់ ឬនាយក សហគ្រាស/គ្រឹះស្ថាន/ក្រុមហ៊ុន<br>ដោយភាគី "ក" ........................................ | ហត្ថលេខា<br>ដោយភាគី "ខ"................................................ |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## កិច្ចព្រមព្រៀងផ្ទៃក្នុង

*កិច្ចព្រមព្រៀងនេះ ត្រូវបានធ្វើឡើងនៅថ្ងៃទី......... ខែ......... ឆ្នាំ ២០២.....*

**រវាង**

ឈ្មោះ ......................... ភេទ ....... ថ្ងៃខែឆ្នាំកំណើត ........................... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ........................ ចុះថ្ងៃទី ........................ មានអាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ ..... ផ្លូវ ........ ភូមិ ........... សង្កាត់ ...................... ខណ្ឌ ................. រាជធានីភ្នំពេញ។ ចាប់ពីពេលនេះតទៅហៅថា "**ភាគី ក**" ទូរស័ព្ទលេខ ........................................ ។

**និង**

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ ............................ ភេទ ...... ថ្ងៃខែឆ្នាំកំណើត ............................ កាន់អត្តសញ្ញាណប័ណ្ណខ្មែរលេខ ......................... ចុះថ្ងៃទី ......................... មានអាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ ..... ផ្លូវ ........ ភូមិ ........... សង្កាត់ ...................... ខណ្ឌ ................. រាជធានីភ្នំពេញ។ ចាប់ពីពេលនេះតទៅហៅថា "**ភាគី ខ**" ទូរស័ព្ទលេខ ......................................... ។

*"ភាគី ក" និង "ភាគី ខ"* ដែលចាប់ពីពេលនេះតទៅហៅកាត់ថា ភាគីទាំងពីរ។

***កិច្ចព្រមព្រៀងផ្ទៃក្នុង*** ដែលចាប់ពីពេលនេះតទៅហៅកាត់ថា ភាគីទាំងពីរ។

***ភាគីទាំងពីរបានព្រមព្រៀងគ្នាដូចតទៅ ឬប្រកាសថា៖***

**ដោយហេតុថា** "**ភាគី ក**" មានបំណងក្នុងការបង្កើតក្រុមហ៊ុនមួយ ដែលមានឈ្មោះថា ..................... ...................................... ជាក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត ដែលចាប់ពីពេលនេះតទៅហៅកាត់ថា ក្រុមហ៊ុន ដើម្បីវិនិយោគលើវិស័យ.....................................និង ..................... នៅក្នុងប្រទេសកម្ពុជា។

**ដោយហេតុថា** អនុលោមតាមច្បាប់ភូមិបាល នៃព្រះរាជាណាចក្រកម្ពុជា នីតិបុគ្គលដែលមានសញ្ជាតិខ្មែរ អាចក្លាយជាកម្មសិទ្ធិករលើដីធ្លី នៅព្រះរាជាណាចក្រកម្ពុជា ហេតុនេះ "**ភាគី ខ**" ដែលជារូបវន្តបុគ្គលសញ្ជាតិខ្មែរ បានយល់ព្រមឈរឈ្មោះជាតំណាងឱ្យភាគហ៊ុនរបស់ "**ភាគី ក**" ចំនួន ៥១ ភាគរយនៃដើមទុនសរុប ក្នុងគោលបំណងធ្វើឱ្យ ............... ............................ បានទទួលសញ្ជាតិខ្មែរ និងមានសិទ្ធិពេញលេញតាមផ្លូវច្បាប់

ដើម្បីក្លាយជាកម្មករលើអចលនទ្រព្យ នៅព្រះរាជាណាចក្រកម្ពុជា។ ហេតុនេះ ភាគីទាំងពីរនៃកិច្ចព្រមព្រៀងនេះ បានយល់ព្រមអនុវត្តតាមលក្ខខណ្ឌដូចខាងក្រោម៖

**ប្រការ ១. អំពីដើមទុន**

"**ភាគី ក**" យល់ព្រមវិនិយោគនូវដើមទុនទាំងអស់របស់ខ្លួន ក្នុងការបង្កើតក្រុមហ៊ុន ........................................ មានទីស្នាក់ការចុះបញ្ជីស្ថិតនៅផ្ទះលេខ ........ ផ្លូវលេខ .......... សង្កាត់ ...................... ខណ្ឌ ............................ រាជធានីភ្នំពេញ ដោយឱ្យ "**ភាគី ខ**" ធ្វើជាអ្នកតំណាងលើភាគហ៊ុនរបស់ខ្លួន ក្នុងការចុះបញ្ជីភាគហ៊ុនចំនួន ៥១ ភាគរយ នៃដើមទុនចុះបញ្ជីសរុបចំនួន ...................................... (....................................) រៀល និង "**ភាគី ក**" ដែលជាម្ចាស់ដើមទុនសរុបទាំងអស់ ចុះបញ្ជីភាគហ៊ុនចំនួន ៤៩ ភាគរយ នៃដើមទុនចុះបញ្ជីសរុបចំនួន ............................. (........................................) រៀល ក្នុងគោលបំណងធ្វើឱ្យក្រុមហ៊ុន ................................................ បានទទួលសញ្ញាតិខ្មែរ ដោយស្របច្បាប់និងមានសិទ្ធិពេញលេញក្នុងការកាន់កាប់អចលនទ្រព្យ នៅប្រទេសកម្ពុជា។

**ប្រការ ២. ការបែងចែកភាគលាភ**

ដើម្បីជាការផ្ដល់នូវតម្លៃតបស្នងទៅវិញទៅមក ភាគីទាំងពីរបានព្រមព្រៀងគ្នា ធ្វើការបែងចែកភាគលាភរបស់ក្រុមហ៊ុន តាមគោលការណ៍ដូចតទៅ៖

១- ប្រាក់ចំណេញដែលបានកមកពីការអភិវឌ្ឍន៍អចលនទ្រព្យ ឬលក់អចលនទ្រព្យ "**ភាគី ក**" នឹងទទួលបាន .......... ភាគរយ "**ភាគី ខ**" នឹងទទួលបាន ......... ភាគរយ។

២- ប្រាក់ចំណេញដែលបានមកពីវិស័យកសិកម្ម "**ភាគ ក**" និងទទួលបាន ......... ភាគរយ "**ភាគី ខ**" នឹងទទួលបាន ......... ភាគរយ។

៣- ប្រាក់កម្រៃជើងសារ ដែលបានមកពីការណែនាំអតិថិជនឱ្យទិញអចលនទ្រព្យ "**ភាគី ក**" នឹងទទួលបាន ...... ភាគរយ "**ភាគី ខ**" នឹងទទួលបាន ....... ភាគរយ។ ដោយឡែក គម្រោងអភិវឌ្ឍន៍ផ្សេងៗក្រៅពីចំណុចខាងលើ ភាគីទាំងពីរបានព្រមព្រៀងគ្នាបែងចែកភាគលាភ ដោយអនុលោមទៅតាមភាគរយនៃការដាក់ដើមទុនរបស់ភាគីទាំងពីរ តាមការឯកភាពរវាងភាគីទាំងពីរ ទើបធ្វើការបែងចែកប្រាក់ចំណេញ។ ការបែងចែកភាគលាភនេះ នឹងត្រូវបានធ្វើឡើងបន្ទាប់ពីការចំណាយរបស់ក្រុមហ៊ុនរួចរាល់ ។

**ប្រការ ៣. អំពីអ្នកតំណាងក្រុមហ៊ុន**

"**ភាគី ខ**" បានយល់ព្រមក្នុងការធ្វើជាអ្នកតំណាងម្ចាស់ភាគហ៊ុន "**ភាគី ក**" ដើម្បីចុះបញ្ជីភាគហ៊ុនចំនួន ៥១ ភាគរយ នៃដើមទុនចុះបញ្ជីសរុប ក្នុងការបង្កើតក្រុមហ៊ុន ................

.......................................... ដោយសន្យាថា ខ្លួននឹងមិនរារាំងការគ្រប់គ្រងក្រុមហ៊ុន ឬការទាមទារទូរកម្រៃ ឬផលប្រយោជន៍បន្ថែមណាមួយពីការធ្វើជាអ្នកតំណាងឱ្យ **"ភាគី ក"** ឡើយលើកលែងតែការបែងចែកភាគលាភដែលមានក្នុងប្រការ ២ ខាងលើ នៃកិច្ចព្រមព្រៀងនេះ។

**ប្រការ៤. អំពីសិទ្ធិ**

សិទ្ធិគ្រប់គ្រងចាត់ចែង សិទ្ធិធ្វើសេចក្ដីសម្រេចចិត្ត សិទ្ធិធ្វើជាអ្នកតំណាងក្រុមហ៊ុន សិទ្ធិក្នុងការចុះហត្ថលេខាលើឯកសារក្រុមហ៊ុន និងរាល់សិទ្ធិទាក់ទងនឹងប្រតិបត្តិការក្រុមហ៊ុន គឺជាសិទ្ធិផ្តាច់មុខរបស់ **"ភាគី ក"** ។

**ប្រការ ៥. ការចំណាយ**

រាល់ការចំណាយផ្សេងៗ ដើម្បីប្រតិបត្តិការអាជីវកម្មរបស់ក្រុមហ៊ុន គឺជាបន្ទុករបស់ក្រុមហ៊ុន ...............................................................................។

**ប្រការ ៦. អំពីឯកសារ**

រាល់ឯកសារផ្ទេរសិទ្ធិកាន់កាប់ វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឯកសារពាក់ព័ន្ធនិងដីធ្លី ឬទ្រព្យសម្បត្តិក្រុមហ៊ុន និងឯកសារពាក់ព័ន្ធនិងក្រុមហ៊ុនច្បាប់ដើមទាំងអស់ **"ភាគី ក"** ជាអ្នករក្សាទុក។

**ប្រការ ៧. ភារកិច្ច**

**"ភាគី ខ"** ទទួលស្គាល់ថា ខ្លួនគ្រាន់តែជាអ្នកតំណាងឱ្យ **"ភាគី ក"** តែប៉ុណ្ណោះ ដោយខ្លួនគ្មានសិទ្ធិចូលកាន់កាប់ ប្រើប្រាស់ អាស្រ័យនៅ បញ្ចាំ ជួល លក់ ដូរ ផ្ទេរសិទ្ធិ ធ្វើអំណោយធ្វើមតកសាសន៍ ផ្ទេរភាគហ៊ុន ឬធ្វើសកម្មភាពណាមួយ ដែលជាហេតុធ្វើឱ្យបាត់បង់ផលប្រយោជន៍ **"ភាគី ក"** ឡើយ។ សិទ្ធិទាំងនេះ គឺជាសិទ្ធិផ្តាច់មុខរបស់ **"ភាគី ក"** ។ រាល់ការផ្ទេរសិទ្ធិកាន់កាប់ ការលក់ ការជួល ការបញ្ចាំ ការដូរ ការធ្វើអំណោយ ការធ្វើមតកសាសន៍ ឬការផ្ទេរភាគហ៊ុន មិនអាចធ្វើបានទេ លុះត្រាតែមានការព្រមព្រៀងជាលាយលក្ខអក្សរពី **"ភាគី ក"** បើពុំដូច្នោះទេ **"ភាគី ខ"** ត្រូវសងការខូចខាតទាំងអស់ ដែលអាចកើតឡើងដោយហេតុ និងទទួលខុសត្រូវចំពោះមុខច្បាប់។

**ប្រការ ៨. សហការគារទៀម**

**"ភាគី ខ"** យល់ព្រមចូលរួមសហការជាមួយ **"ភាគី ក"** និងតតិយជន ក្នុងការរៀបចំឯកសារដើម្បីផ្ទេរសិទ្ធិកាន់កាប់ ឬផ្ទេរសិទ្ធិដីធ្លី ឬការផ្ទេរភាគហ៊ុន ដែលមានការទទួលស្គាល់ពីអាជ្ញាធរមានសមត្ថកិច្ច ដោយការចំណាយផ្សេងៗ គឺជាបន្ទុករបស់ក្រុមហ៊ុន។

**ប្រការ ៩. សិទ្ធិកាន់កាប់ និងស្នើសុំ**

រាល់ការស្នើសុំពី "**ភាគី ក**" ឱ្យមានការផ្ទេរសិទ្ធិកាន់កាប់ ការលក់ ដូរ បញ្ចាំ ជួល ផ្ទេរសិទ្ធិ ធ្វើអំណោយ ធ្វើមតកសាសន៍ ផ្ទេរភាគហ៊ុន ឬធ្វើសកម្មភាពផ្សេងៗទាក់ទង និងធនធាន ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន និងភាគហ៊ុនខាងលើ "**ភាគី ខ**" មិនអាចជំទាស់បានឡើយ និងត្រូវចូលរួមសហការផ្តិតមេដៃ ឬចុះហត្ថលេខាលើឯកសារចាំបាច់ផ្សេងៗ ដោយគ្មានលក្ខខណ្ឌ និងឆាប់រហ័ស។ បើពុំដូច្នោះទេ "**ភាគី ខ**" ត្រូវសងការខូចខាតទាំងអស់ដែលអាចកើតឡើងជាយថាហេតុ និងទទួលខុសត្រូវចំពោះមុខច្បាប់។

**ប្រការ ១០. លក្ខខណ្ឌច្បាប់បញ្ញត្តិ**

ភាគីទាំងពីរបានព្រមព្រៀងគ្នាថា ប្រសិនបើនាពេលអនាគត់ ច្បាប់ ឬបញ្ញត្តិ**ណាមួយនៃ**ប្រទេសកម្ពុជា បានផ្តល់សិទ្ធិដល់ជនបរទេស ឬក្រុមហ៊ុនដោយពុំចាំបាច់**មានសញ្ជាតិខ្មែរ**អាចក្លាយជាកម្មសិទ្ធិលើអចលនវត្ថុ "**ភាគី ខ**" យល់ព្រមធ្វើការផ្ទេរ**ភាគហ៊ុនដូចមានចែក**ក្នុងប្រការ ១ ខាងលើ មកឱ្យ "**ភាគី ក**" វិញ ដោយគ្មានលក្ខខណ្ឌ **និងឆាប់រហ័ស។**

**ប្រការ ១១. សិទ្ធិ និងកាតព្វកិច្ច**

រាល់សិទ្ធិ និងកាតព្វកិច្ច ដែលកើតឡើងតាមរយៈកិច្ចព្រមព្រៀងនេះ ពុំមានអានុភាពភ្ជាប់កាតព្វកិច្ចដល់សហព័ទ្ធ និងសន្តតិជនរបស់ "**ភាគី ខ**" ឡើយ។ ក្នុងករណីដែល "**ភាគី ខ**" បាត់បង់សមត្ថភាពតាមផ្លូវច្បាប់ សហព័ទ្ធ និងសន្តតិជនរបស់ "**ភាគី ខ**" មិនអាចទាមទារប្រាក់ចំណេញ ឬការកាន់កាប់ភាគហ៊ុនបន្ត ឬអត្ថប្រយោជន៍ណាមួយពីក្រុមហ៊ុនបានឡើយ ។

**ប្រការ ១២. អំពីលក្ខខណ្ឌ**

គ្មានការព្រមព្រៀងណាមួយ ឬការកែប្រែលក្ខខណ្ឌ **ដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះ** ត្រូវបានយកមកអនុវត្តបន្ថែមឡើយ ដរាបណាការព្រមព្រៀងនេះ ពុំបានធ្វើឡើងជាលាយលក្ខណ៍អក្សរ ដោយមានការចុះហត្ថលេខា ឬផ្តិតមេដៃស្តាំ យល់ព្រមដោយភាគីទាំងពីរ។

**ប្រការ ១៣- ការដោះស្រាយវិវាទ និងច្បាប់គ្រប់គ្រង**

- ករណីមានវិវាទកើតឡើងចេញពីកិច្ចព្រមព្រៀងនេះ បណ្តាភាគីត្រូវដោះស្រាយគ្នាប្រកបដោយស្មារតីយោគយល់គ្នា។
- រាល់ការដោះស្រាយវិវាទផ្ទៃក្នុងលើគម្រោងគឺ **ភាគី** "**ក**" ជាអ្នកមានសម្លេងឧត្តមានុភាពក្នុងការសម្រេចលើបញ្ហាដែលកើតមានឡើង។
- ប្រសិនបើសមាជិកភាគហ៊ុនណាម្នាក់មិនទទួលខុសត្រូវក្នុងការងារដែលក្រុមហ៊ុនបានដាក់ឲ្យធ្វើនោះ **ភាគី** "**ក**" មានសិទ្ធិសម្រេចរំលាយកិច្ចព្រមព្រៀងចូលទុនវិនិយោគចំពោះសមាជិកភាគហ៊ុនរូបនោះដោយឆន្ទានុសិទ្ធិ។

- ករណីការដោះស្រាយពុំអាចសះជា ភាគីដែលទទួលរងការខាតបង់ប្រយោជន៍មានសិទ្ធិប្តឹងតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។
- បណ្តាភាគីត្រូវអនុវត្តកាតព្វកិច្ច ដូចបានចែងខាងលើឲ្យបានត្រឹមត្រូវ ករណីភាគីណាមួយមិនអនុវត្តកាតព្វកិច្ចដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងខាងលើ ភាគីនោះត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។
- ករណីមានវិវាទកើតឡើង ភាគីដែលរំលោភបំពានលើកិច្ចព្រមព្រៀងនេះ **ជាអ្នកទទួល**បន្ទុកលើការចំណាយផ្សេងៗ។

**ប្រការ ១៤- សុពលភាពនៃកិច្ចព្រមព្រៀង**

កិច្ចព្រមព្រៀងនេះធ្វើឡើងដោយពិតប្រាកដ និងដោយសេរីពុំមាន**ការបង្ខិតបង្ខំពីភាគី**ណាមួយ ឬតតិយជនណាមួយឡើយ។ កិច្ចព្រមព្រៀងនេះភាគី**ទាំងពីរបានអាននិងយល់**ពល់ខ្លឹមសារនៃកិច្ចព្រមព្រៀងនេះ។

**ប្រការ ១៥. ភាសាប្រើប្រាស់**

កិច្ចព្រមព្រៀងនេះធ្វើឡើងជាភាសាខ្មែរមានចំនួន ........ ច្បាប់ដើម និងភាសាអង់គ្លេសមានចំនួន ........ ច្បាប់ដើម ដែលមានតម្លៃគតិយុត្តដូចគ្នា។ កិច្ចព្រមព្រៀងនេះ មានសុពលភាពអនុវត្តចាប់ពីថ្ងៃផ្តិតមេដៃនេះតទៅ និងត្រូវបានរក្សាទុកដោយ

- **"ភាគី ក"** ០១ ច្បាប់ដើម ជាភាសាខ្មែរ និង ០១ ច្បាប់ដើមជាភាសាអង់គ្លេស
- **"ភាគី ខ"** ០១ ច្បាប់ដើម ជាភាសាខ្មែរ និង ០១ ច្បាប់ដើមជាភាសាអង់គ្លេស និង
- រក្សាទុកនៅការិយាល័យមេធាវី ចំនួន ០១ ច្បាប់ដើម ជាភាសាខ្មែរ និង ០១ ច្បាប់ដើមជាភាសាអង់គ្លេស។

កិច្ចសន្យានេះមានសុពលភាពចាប់ពីថ្ងៃភាគីទាំងពីរបានផ្តិតមេដៃនេះតទៅ។

ថ្ងៃ........................ ខែ .............. ឆ្នាំ ........ ព.ស ២៥៦.....

រាជធានីភ្នំពេញ ថ្ងៃទី ...... ខែ ......... ឆ្នាំ ២០២.....

**ស្នាមមេដៃ**

**"ភាគី ខ"** **"ភាគី ក"**

**បានឃើញ និង បញ្ជាក់ថា**
**គូភាគីទាំងពីរពិតជាបានចុះហត្ថលេខា**
**ចំពោះមុខយើងមេធាវីពិតប្រាកដមែន។**

រាជធានីភ្នំពេញ ថ្ងៃទី ........ ខែ ............. ឆ្នាំ ២០២....

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## កិច្ចព្រមព្រៀងសះជា

យោងតាមពាក្យស្នើសុំដោះស្រាយរបស់ឈ្មោះ ............ភេទ [illegible] អាយុ [illegible] ឆ្នាំ និងឈ្មោះ ............ ភេទ [illegible] អាយុ [illegible] ឆ្នាំ កាលថ្ងៃទី 29 ខែ 04 ឆ្នាំ២០[illegible]

នៅប៉ុស្តិ៍នគរបាលរដ្ឋបាលសង្កាត់ប៉ោយប៉ែត ឆ្នាំពីរពាន់ [illegible] ខែ [illegible]

វេលាម៉ោង 15 [illegible] ។

លិខិតព្រមព្រៀងនេះធ្វើឡើង ចំពោះគូភាគីដែលមានឈ្មោះ :

ក/ ភាគីដើមបណ្តឹងឈ្មោះ ............ភេទ [illegible] អាយុ [illegible] ឆ្នាំ ជនជាតិ [illegible] រស់នៅភូមិ [illegible] សង្កាត់ [illegible] ក្រុង [illegible] ខេត្ត [illegible] ។

ខ/ ភាគីចុងបណ្តឹងឈ្មោះ ............ភេទ [illegible] អាយុ [illegible] ឆ្នាំ ជនជាតិ [illegible] រស់នៅភូមិ [illegible] សង្កាត់ [illegible] ក្រុង [illegible] ខេត្ត [illegible]

គូភាគីទាំងពីរបានព្រមព្រៀងគ្នា និងចុះកិច្ចសន្យាខាងក្រោមៈ

ភាគីដើមបណ្តឹងបានសំណូមពរសុំធ្វើការដោះស្រាយ ដោយសុំអោយភាគីចុងបណ្តឹង [illegible] ដើម្បីបញ្ចប់រឿងហេតុ កាលពីថ្ងៃទី [illegible] ខែ 04 ឆ្នាំ២០[illegible]

ភាគីចុងបណ្តឹងបានព្រមព្រៀង [illegible] ឲ្យទៅភាគីដើមបណ្តឹង ដែលបានព្រមព្រៀង ។

ក្នុងការព្រមព្រៀងគ្នាភាគីទាំងពីរសូមចុះកិច្ចសន្យាដូចខាងក្រោមៈ

១- មិនប្តឹងតវ៉ា បណ្តឹងរឿងហេតុនេះឡើងវិញឡើយ ។

២- មិនមានការជុំគួននឹងគ្នា

៣- មិនបង្កសកម្មភាពល្មើសច្បាប់

៤- បញ្ចប់រឿងហេតុចាប់ពីថ្ងៃនេះតទៅ

ក្រោយថ្ងៃក្រោយក្បត់កិច្ចសន្យាខាងលើ និងការព្រមព្រៀង យើងខ្ញុំជាអ្នកក្បត់កិច្ចសន្យាសូមទទួលទោសតាមច្បាប់ ។

លិខិតព្រមព្រៀងនេះបានចប់សព្វគ្រប់ នៅវេលាម៉ោង 15 40 នាទី នាថ្ងៃ ខែ ឆ្នាំដដែល ហើយបានអានសារឡើងវិញអោយស្តាប់ និងយល់ព្រមផ្តិតមេដៃកំណាំ ។

ស្នាមមេដៃភាគីដើមបណ្តឹង | សាក្សី | ស្នាមមេដៃភាគីចុងបណ្តឹង

[redacted] | [redacted] | [redacted]

# ឧបសម្ព័ន្ធទី២

# កម្រងមាត្រា ដកស្រង់

# ចេញពីក្រមរដ្ឋប្បវេណី

# គន្ថីទី ២

# បុគ្គល

## ជំពូកទី ១

## រូបវន្តបុគ្គល

### ផ្នែកទី ១

### សមត្ថភាពទទួលសិទ្ធិ

**មាត្រា ៦.–** គោលការណ៍សមភាពនៃសមត្ថភាពទទួលសិទ្ធិ

រូបវន្តបុគ្គលគ្រប់រូប មានលក្ខណសម្បត្តិអាចក្លាយជាប្រធាននៃសិទ្ធិ និង កាតព្វកិច្ចបាន ។

**មាត្រា ៧.–** ការកម្រិតក្នុងការទទួលសិទ្ធិចំពោះជនបរទេស

ជនជាតិបរទេស មិនអាចទទួលបាន ឬ កាន់កាប់នូវសិទ្ធិមួយចំនួនដែលត្រូវបានកំណត់ឡើយ ក្នុងករណីដែលមានបញ្ញត្តិផ្សេងនៅក្នុងច្បាប់ជាតិ ឬ សន្ធិសញ្ញា ឬ អនុសញ្ញាអន្តរជាតិ ។

**មាត្រា ៨.–** ពេលចាប់ផ្តើម និង បញ្ចប់សមត្ថភាពទទួលសិទ្ធិ

រូបវន្តបុគ្គលម្នាក់ៗ មានសមត្ថភាពទទួលសិទ្ធិនៅពេលចាប់កំណើត ហើយបាត់បង់អស់នូវសមត្ថភាពទទួលសិទ្ធិនេះ នៅពេលទទួលមរណភាព ។

## ផ្នែកទី ៣
## សមត្ថភាពខាងឆន្ទៈ

**មាត្រា ១៤.–** ការខ្វះសមត្ថភាពខាងឆន្ទៈ

សកម្មភាពដែលភាគីបានធ្វើនៅក្នុងស្ថានភាពដែលខ្លួនមិនអាចយល់ដឹង និងវិនិច្ឆ័យបាន អំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន អាចលុបចោលបាន ។

**មាត្រា ១៥.–** និយមន័យនៃសកម្មភាព

ពាក្យ "សកម្មភាព" ដែលត្រូវបានប្រើនៅក្នុងផ្នែកទី ៣ (សមត្ថភាពខាងឆន្ទៈ) ផ្នែកទី ៤ (សមត្ថភាពក្នុងការធ្វើសកម្មភាព) និង ផ្នែកទី ៦ (ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់បុគ្គលដែលអវត្តមាន និង ការប្រកាសអំពីការបាត់ខ្លួន) នៃជំពូកទី ១ នេះ សំដៅទៅលើកិច្ចសន្យា និង សកម្មភាពឯកតោភាគី ។

## ផ្នែកទី ៤
## សមត្ថភាពក្នុងការធ្វើសកម្មភាព

**មាត្រា ១៦.–** អត្ថន័យនៃជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព

ជនដែលត្រូវបានកម្រិតសមត្ថភាព សំដៅទៅលើអនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ និង ជននៅក្រោមហិតូបត្ថម្ភ ។

## កថាភាគទី ១
## អនីតិជន

**មាត្រា ១៧.–** អត្ថន័យនៃអនីតិជន

អនីតិជន សំដៅទៅលើជនដែលមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ។

**មាត្រា ១៨.–** សិទ្ធិលុបចោលសកម្មភាព

សកម្មភាពដែលអនីតិជនបានធ្វើដោយមិនបានទទួលការយល់ព្រមពីអ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន អាចលុបចោលបាន ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវអនុវត្តឡើយ ចំពោះសកម្មភាពដែលទទួលសិទ្ធិ ឬ ឱ្យរួចផុតពីកាតព្វកិច្ច ឬ សកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ ។

**មាត្រា ១៩.–** ការចាត់ចែងទ្រព្យសម្បត្តិដែលអ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនអនុញ្ញាតឱ្យចាត់ចែង

អនីតិជនអាចចាត់ចែងទ្រព្យសម្បត្តិដែលអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនបានអនុញ្ញាតឱ្យចាត់ចែង ដោយកំណត់គោលបំណង ក្នុងទំហំនៃគោលបំណងនេះបាន ។ ម្យ៉ាងទៀត អនីតិជនក៏អាចចាត់ចែងទ្រព្យសម្បត្តិដែលអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនបានអនុញ្ញាតឱ្យចាត់ចែងដោយមិនបានកំណត់គោលបំណងបានដែរ ។

**មាត្រា ២០.–** អនីតិជនដែលត្រូវបានអនុញ្ញាតឱ្យប្រកបអាជីវកម្ម

១-អនីតិជនដែលបានទទួលការអនុញ្ញាតឱ្យប្រកបអាជីវកម្មមួយប្រភេទ ឬ ច្រើនប្រភេទ ពីអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវមានសមត្ថភាពដូចនីតិជន ចំពោះមុខជំនួញនោះ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើបានដឹងច្បាស់ថា អនីតិជននោះមិនអាចបំពេញកិច្ចការអាជីវកម្មនោះបាន អ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនអាចលុបចោល ឬ កម្រិតនូវការអនុញ្ញាតនៃការប្រកបអាជីវកម្មនោះបាន ។

**មាត្រា ២១.–** ល័ក្ខខ័ណ្ឌនៃអត្តាធីនភាព

១-ក្នុងករណីដែលអនីតិជនដែលបានដល់អាយុ ១៦ (ដប់ប្រាំមួយ) ឆ្នាំ ទ្រទ្រង់ជីវភាពខ្លួនឯងដោយឯករាជ្យ តុលាការអាចប្រកាសនូវអត្តាធីនភាពរបស់អ្នកនោះបាន

តាមពាក្យសុំរបស់អនីតិជននោះ ប្រសិនបើតុលាការយល់ឃើញថា អត្តាធីនភាពស្របនឹងផលប្រយោជន៍របស់អនីតិជននោះ ។ ក្នុងករណីនេះ តុលាការត្រូវសួរយោបល់ពីអ្នកមានសិទ្ធិអំណាចមេបា ។

២-អនីតិជនដែលបានរៀបអាពាហ៍ពិពាហ៍ហើយ ត្រូវទទួលអត្តាធីនភាព ដោយមិនចាំបាច់មានការប្រកាសពីតុលាការទេ ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ទោះបីភាគីលែងលះគ្នាក៏ដោយ ក៏អានុភាពនៃអត្តាធីនភាព មិនត្រូវរលត់ឡើយ ។

**មាត្រា ២២.–** អានុភាពនៃអត្តាធីនភាព

អនីតិជនដែលទទួលអត្តាធីនភាព ត្រូវបានចាត់ទុកថា បានដល់នីតិភាព ។

**មាត្រា ២៣.–** កិច្ចសន្យាការងាររបស់អនីតិជន

១-ទោះបីជាមានបញ្ញត្តិនៃមាត្រា ១០៥៣ (ការគ្រប់គ្រងទ្រព្យសម្បត្តិ និង ការតំណាង) និង មាត្រា ១០៨០ (ការគ្រប់គ្រងទ្រព្យសម្បត្តិ និង ការតំណាង) នៃក្រមនេះក៏ដោយ ក៏អ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន មិនអាចធ្វើកិច្ចសន្យាការងារជំនួសអនីតិជនបានដែរ ។

២-កិច្ចសន្យាដែលផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនមានអានុភាពចំពោះសាមីអនីតិជនឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវអនុវត្តឡើយ ចំពោះករណីដែលសាមីអនីតិជនផ្តល់សច្ចានុមតិលើកិច្ចសន្យានោះ ។

៣-ក្នុងករណីដែលយល់ឃើញថា កិច្ចសន្យាការងាររបស់អនីតិជនអាចធ្វើឱ្យខូចផលប្រយោជន៍ដល់អនីតិជននោះ អ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬ ស្ថាប័នរដ្ឋបាល អាចរំលាយកិច្ចសន្យានោះ ឆ្ពោះទៅអនាគតបាន ។

## កថាភាគទី ២
## ជននៅក្រោមអាណាព្យាបាលទូទៅ

**មាត្រា ២៤.–** ការប្រកាសការចាប់ផ្ដើមអាណាព្យាបាលទូទៅ

១-ចំពោះជនដែលស្ថិតនៅក្នុងស្ថានភាពជានិរន្តរ៍ដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី តុលាការអាចប្រកាសការចាប់ផ្ដើមអាណាព្យាបាលទូទៅបាន តាមពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតនៅក្នុង ៤ (បួន) ថ្នាក់ អ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ហិតូបត្ថម្ភកៈ មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬ តំណាងអយ្យការ ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលសាមីខ្លួនមិនទាន់ដល់អាយុ ១៥ (ដប់ប្រាំ) ឆ្នាំនៅពេលដែលមានពាក្យសុំ ។

២-ក្នុងករណីដែលធ្វើការប្រកាសដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើសាមីខ្លួនជាជននៅក្រោមហិតូបត្ថម្ភ តុលាការត្រូវលុបចោលការប្រកាសការចាប់ផ្ដើមហិតូបត្ថម្ភចំពោះជននោះ ។

**មាត្រា ២៥.–** អត្ថន័យនៃជននៅក្រោមអាណាព្យាបាលទូទៅ និង ការជ្រើសតាំងអ្នកអាណាព្យាបាលទូទៅ

ជនដែលបានទទួលការប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅ ត្រូវហៅថា ជននៅក្រោមអាណាព្យាបាលទូទៅ ហើយត្រូវស្ថិតនៅក្រោមអ្នកអាណាព្យាបាលទូទៅ ។

**មាត្រា ២៦.–** សិទ្ធិលុបចោលសកម្មភាព

សកម្មភាពរបស់ជននៅក្រោមអាណាព្យាបាលទូទៅ អាចលុបចោលបាន ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវអនុវត្តឡើយ ចំពោះសកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ ។

**មាត្រា ២៧.–** ការលុបចោលការប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅ

បើមូលហេតុដែលបានកំណត់នៅក្នុងមាត្រា ២៤ (ការប្រកាសការចាប់ផ្ដើមអាណាព្យាបាលទូទៅ) នៃក្រមនេះ បានរលាយ តុលាការត្រូវលុបចោលនូវការប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅ តាមពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតនៅក្នុង ៤ (បួន) ថ្នាក់ អ្នកអាណាព្យាបាល អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាល មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬ តំណាងអយ្យការ ។

## កថាភាគទី ៣

## ជននៅក្រោមហិតូបត្ថម្ភ

**មាត្រា ២៨.–** ការប្រកាសការចាប់ផ្ដើមហិតូបត្ថម្ភ

១-ចំពោះជនដែលមានសមត្ថភាពតិចតួចពេកក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី តុលាការអាចប្រកាសការចាប់ផ្ដើមហិតូបត្ថម្ភលើជននោះបាន តាមពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតនៅក្នុង ៤ (បួន) ថ្នាក់ អ្នកអាណាព្យាបាល អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាល មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬ តំណាងអយ្យការ ។

២-ក្នុងករណីដែលធ្វើការប្រកាសដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើសាមីខ្លួនជាជននៅក្រោមអាណាព្យាបាលទូទៅ តុលាការត្រូវលុបចោលការប្រកាសការចាប់ផ្ដើមអាណាព្យាបាលទូទៅចំពោះជននោះ ។

**មាត្រា ២៩.–** អត្ថន័យនៃជននៅក្រោមហិតូបត្ថម្ភ និង ការជ្រើសតាំងហិតូបត្ថម្ភកៈ

ជនដែលបានទទួលការប្រកាសចាប់ផ្ដើមហិតូបត្ថម្ភ ត្រូវហៅថា ជននៅក្រោមហិតូបត្ថម្ភ ហើយត្រូវស្ថិតនៅក្រោមការថែរក្សាដោយហិតូបត្ថម្ភកៈ ។

**មាត្រា ៣០.–** សិទ្ធិលុបចោលសកម្មភាព

លើកលែងតែសកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ សកម្មភាពដែល

បានធ្វើឡើងដោយជននៅក្រោមហិត្ថបត្ថម្ភ ដោយគ្មានការយល់ព្រមពីហិត្ថបត្ថម្ភកៈដូចខាងក្រោមនេះ អាចលុបចោលបាន ៖

ក-ការទទួល ឬ ការប្រើប្រាស់ទុន ។

ខ-ការខ្ចីទ្រព្យ ឬ ការធានា ។

គ-ការធ្វើសកម្មភាពដែលមានគោលបំណងទទួលបាន ឬ ធ្វើឱ្យបាត់បង់សិទ្ធិដែលទាក់ទងនឹងអចលនវត្ថុ ឬ ទ្រព្យសម្បត្តិដែលមានសារៈសំខាន់ផ្សេងទៀត ។

ឃ-ការធ្វើសកម្មភាពបណ្តឹង ។

ង-ការធ្វើប្រទានកម្ម ឬ ធ្វើកិច្ចសន្យាស្រុះស្រួល ឬ កិច្ចសន្យាមជ្ឈត្តកម្ម ។

ច-ការទទួលស្គាល់នូវសន្តតិកម្ម ឬ ការបោះបង់ចោលនូវសិទ្ធិសន្តតិកម្ម ឬ ការបែងចែកនូវមត៌ក ។

ឆ-ការប្រកែកមិនទទួលប្រទានកម្មឬអច្ច័យទាន ឬ ការយល់ព្រមទទួលនូវប្រទានកម្មឬអច្ច័យទានដែលភ្ជាប់នឹងបន្ទុក ។

ជ-ការសាងសង់សំណង់ថ្មី ការសង់ឡើងវិញ ការសង់បន្ថែម ឬ ការជួសជុលធំ ។

ឈ-ការធ្វើភតិសន្យា ដែលមានអំឡុងពេលលើសពី ៣ (បី) ឆ្នាំ ចំពោះដីធ្លី លើសពី ២ (ពីរ) ឆ្នាំ ចំពោះអាគារ លើសពី ៦ (ប្រាំមួយ) ខែ ចំពោះចលនវត្ថុ ។

ញ-សកម្មភាពដែលតុលាការបានប្រកាសជាពិសេសថា ចាំបាច់ត្រូវមានការយល់ព្រមពីហិត្ថបត្ថម្ភកៈ តាមពាក្យសុំរបស់ជនដែលបានរៀបរាប់នៅក្នុងមាត្រា ២៨ (ការប្រកាសការចាប់ផ្តើមហិត្ថបត្ថម្ភ) នៃក្រមនេះ ឬ ហិត្ថបត្ថម្ភកៈ ឬ អ្នកត្រួតពិនិត្យហិត្ថបត្ថម្ភកៈ ។

**មាត្រា ៣១.–** ការលុបចោលការប្រកាសចាប់ផ្តើមហិត្ថបត្ថម្ភ

បើមូលហេតុដែលបានកំណត់នៅក្នុងមាត្រា ២៨ (ការប្រកាសការចាប់ផ្តើមហិត្ថបត្ថម្ភ) នៃក្រមនេះ បានរលាយ តុលាការត្រូវលុបចោលនូវការប្រកាសចាប់ផ្តើមហិត្ថបត្ថម្ភ តាមពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតនៅក្នុង ៤ (បួន) ថ្នាក់ អ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន

ហិតូបត្ថម្ភកៈ អ្នកត្រួតពិនិត្យហិតូបត្ថម្ភកៈ មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬ តំណាងអយ្យការ ។

## កថាភាគទី ៤

## ការការពារភាគីម្ខាងទៀតនៃជនដែលត្រូវបានកម្រិតសមត្ថភាព

**មាត្រា ៣២.–** សិទ្ធិដាស់តឿន

១-ភាគីម្ខាងទៀតនៃជនដែលត្រូវបានកម្រិតសមត្ថភាព អាចដាស់តឿនឱ្យជននោះឆ្លើយថាផ្តល់ ឬ មិនផ្តល់សច្ចានុមតិ លើសកម្មភាពដែលជននោះអាចលុបចោលបាន ក្នុងអំឡុងពេលលើសពី ១ (មួយ) ខែ ក្រោយពេលជននោះបានក្លាយជាសមត្ថជនវិញ ។ ប្រសិនបើជនដែលត្រូវបានកម្រិតសមត្ថភាពដែលបានក្លាយជាសមត្ថជនវិញនោះ មិនឆ្លើយតបក្នុងអំឡុងពេលដែលបានកំណត់ទេ ត្រូវចាត់ទុកថា ជននោះផ្តល់សច្ចានុមតិលើសកម្មភាពនោះ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តផងដែរ ចំពោះករណីដែលភាគីម្ខាងទៀតបានដាស់តឿន ដូចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើទៅអ្នកមានសិទ្ធិអំណាចមេបា អ្នកអាណាព្យាបាល ឬ ហិតូបត្ថម្ភកៈ អំពីសកម្មភាពដែលស្ថិតនៅក្នុងទំហំនៃសិទ្ធិរបស់ខ្លួន នៅពេលដែលជនដែលត្រូវបានកម្រិតសមត្ថភាព មិនទាន់ក្លាយជាសមត្ថជន តែអ្នកមានសិទ្ធិអំណាចមេបា អ្នកអាណាព្យាបាល ឬ ហិតូបត្ថម្ភកៈ មិនឆ្លើយតប ក្នុងអំឡុងពេលដែលបានកំណត់ទេ ។

៣-ភាគីម្ខាងទៀតអាចដាស់តឿនឱ្យជននៅក្រោមហិតូបត្ថម្ភទទួលយកសច្ចានុមតិពីហិតូបត្ថម្ភកៈ ក្នុងអំឡុងពេលដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។ ប្រសិនបើជននៅក្រោមហិតូបត្ថម្ភ មិនបានជូនដំណឹងថា ខ្លួនបានទទួលសច្ចានុមតិក្នុងអំឡុងពេលនោះទេ ត្រូវចាត់ទុកថា ជននោះបានលុបចោលសកម្មភាពនោះ ។

**មាត្រា ៣១១.–** និយមន័យនៃកិច្ចសន្យា

កិច្ចសន្យាគឺជាកិរិយាដែលបុគ្គលពីរនាក់ ឬ ច្រើននាក់មានឆន្ទៈត្រូវគ្នាព្រមបង្កើត កែប្រែ ឬរំលត់នូវកាតព្វកិច្ច ។

**មាត្រា ៣១២.–** និយមន័យនៃសកម្មភាពឯកតោភាគី

១-សកម្មភាពឯកតោភាគី គឺជាសកម្មភាពដែលបង្កើត កែប្រែ ឬ រំលត់នូវកាតព្វកិច្ច ដោយបង្ហាញឆន្ទៈនៃការចាត់ចែងទ្រព្យដោយភាគីម្ខាង ឬ ដោយអនុវត្តសិទ្ធិដែលបានទទួលតាមកិច្ចសន្យា ឬ តាមបញ្ញត្តិនៃច្បាប់ ។

២-បញ្ញត្តិនៃផ្នែកទី ២ (វិការៈក្នុងការបង្ហាញឆន្ទៈ និង សុពលភាពនៃកិច្ចសន្យា) និង ផ្នែកទី ៤ (ការតំណាង) នៃជំពូកទី ២ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសកម្មភាពឯកតោភាគី ។

## ផ្នែកទី ២
## ប្រភេទ និង បែបយ៉ាងនៃកាតព្វកិច្ច

**មាត្រា ៣១៣.–** ប្រភេទនៃកាតព្វកិច្ច

ក្រៅពីគោលបំណងផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិកាន់កាប់លើវត្ថុ ឬ ប្រាក់ កាតព្វកិច្ចអាចមានគោលបំណងធ្វើ ឬ មិនធ្វើសកម្មភាពណាមួយ ។

**មាត្រា ៣១៤.–** កាតព្វកិច្ចប្រគល់វត្ថុដែលបានកំណត់ជាក់លាក់

ចំពោះកាតព្វកិច្ចប្រគល់វត្ថុដែលបានកំណត់ជាក់លាក់អ្វីមួយ កូនបំណុលមានករណីយកិច្ចថែរក្សាវត្ថុនោះ ដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដ៏ល្អ រហូតដល់ពេលប្រគល់វត្ថុនោះ ។

**មាត្រា ៣១៥.–** កាតព្វកិច្ចដែលបានកំណត់ប្រភេទនៃវត្ថុ

១-ក្នុងករណីដែលកម្មវត្ថុនៃកាតព្វកិច្ចត្រូវបានកំណត់ដោយប្រភេទនៃវត្ថុ ប្រសិនបើកម្មវត្ថុដែលត្រូវផ្តល់ មានគុណភាពច្រើនយ៉ាង កូនបំណុលមានករណីយកិច្ចផ្តល់នូវវត្ថុដែលមានគុណភាពដូចដែលគូភាគីបានកំណត់ ។ ក្នុងករណីដែលគូភាគីមិនកំណត់គុណភាពទេ កូនបំណុលមានករណីយកិច្ចផ្តល់នូវវត្ថុដែលមានគុណភាពមធ្យម ។

២-ចំពោះកាតព្វកិច្ចដែលបានកំណត់ប្រភេទ ក្រោយពេលដែលកូនបំណុលបានកំណត់កម្មវត្ថុដែលត្រូវផ្តល់ច្បាស់លាស់ និង ដែលបានបញ្ចប់សកម្មភាពចាំបាច់ដើម្បីផ្តល់នូវកម្មវត្ថុដែលបានកំណត់ហើយនោះ កូនបំណុលមានករណីយកិច្ចផ្តល់នូវវត្ថុនោះតែប៉ុណ្ណោះ ។

**មាត្រា ៣១៦.–** កាតព្វកិច្ចជាប្រាក់

១-ក្នុងករណីដែលកម្មវត្ថុនៃកាតព្វកិច្ចជាប្រាក់ កូនបំណុលអាចសងជារូបិយវត្ថុផ្សេងៗ តាមការជ្រើសរើសរបស់ខ្លួនបាន ។ ប៉ុន្តែ ម្ចាស់បំណុល និង កូនបំណុលអាចកំណត់ការសងជារូបិយវត្ថុពិសេសបានដែរ ។

២-ក្នុងករណីដែលរូបិយវត្ថុពិសេសដែលបានកំណត់ជាកម្មវត្ថុនៃកាតព្វកិច្ច លែងជារូបិយវត្ថុស្របច្បាប់នៅពេលអនុវត្តកាតព្វកិច្ច កូនបំណុលអាចសងជារូបិយវត្ថុណាមួយផ្សេងទៀតបាន ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលការផ្តល់នូវរូបិយវត្ថុបរទេស ត្រូវបានកំណត់ជាកម្មវត្ថុនៃកាតព្វកិច្ច ។

**មាត្រា ៣១៧.–** កាតព្វកិច្ចជារូបិយវត្ថុបរទេស

១-ក្នុងករណីដែលបានកំណត់ចំនួននៃកាតព្វកិច្ចជារូបិយវត្ថុបរទេស កូនបំណុល អាចសងជារូបិយវត្ថុនៃព្រះរាជាណាចក្រកម្ពុជា ដោយគិតទៅតាមអត្រាប្តូររូបិយប័ណ្ណបរទេស នៅកន្លែងដែលត្រូវអនុវត្តកាតព្វកិច្ចនោះនៅពេលកំណត់អនុវត្ត ។ ប៉ុន្តែ ប្រសិនបើមានការសន្យាពិសេសផ្សេងពីបញ្ញត្តិនេះ រវាងម្ចាស់បំណុល និង កូនបំណុល ត្រូវអនុវត្តទៅតាមការសន្យាពិសេសនោះ ។

២-ក្នុងករណីដែលកូនបំណុលដែលមានការយឺតយ៉ាវក្នុងការអនុវត្ត សងជារូបិយវត្ថុនៃព្រះរាជាណាចក្រកម្ពុជា ម្ចាស់បំណុលអាចទាមទារឱ្យកូនបំណុលសង ដោយគិតទៅតាមអត្រាប្តូររូបិយប័ណ្ណបរទេសនៅពេលកំណត់អនុវត្ត ឬ នៅពេលដែលកូនបំណុលសងបាន ។ ប៉ុន្តែ ប្រសិនបើមានការសន្យាពិសេសផ្សេងពីបញ្ញត្តិនេះ រវាងម្ចាស់បំណុល និង កូនបំណុល ត្រូវអនុវត្តទៅតាមការសន្យាពិសេសនោះ ។

**មាត្រា ៣១៨.–** អត្រាការប្រាក់ដែលកំណត់ដោយច្បាប់

ចំពោះកាតព្វកិច្ចដែលត្រូវបង្កើតការប្រាក់ ក្នុងករណីដែលគ្មានការកំណត់ផ្សេងទេ ត្រូវគិតអត្រាការប្រាក់ ចំនួន ៥ ភាគរយ (ប្រាំភាគរយ) ក្នុងមួយឆ្នាំ ។

**មាត្រា ៣១៩.–** ការប្រាក់សមាស

ក្នុងករណីដែលមានការយឺតយ៉ាវមិនបានសងការប្រាក់ សម្រាប់រយៈពេលចាប់ពី ១ (មួយ) ឆ្នាំ ឡើងទៅ ហើយទោះបីជាម្ចាស់បំណុលបានដាស់តឿនឱ្យសងយ៉ាងណាក៏ដោយ ក៏កូនបំណុលមិនព្រមសងការប្រាក់នោះ ម្ចាស់បំណុលអាចបូកការប្រាក់បញ្ចូលទៅក្នុងប្រាក់ដើមបាន ។

**មាត្រា ៣២០.–** កាតព្វកិច្ចអនិយ័ត

ក្នុងករណីដែលកម្មវត្ថុនៃកាតព្វកិច្ច ត្រូវបានកំណត់ដោយការជ្រើសរើសក្នុងចំណោមការផ្តល់ច្រើនប្រភេទ កូនបំណុលត្រូវមានសិទ្ធិជ្រើសរើស ។ ប៉ុន្តែ ភាគីនៃកិច្ចសន្យាអាចឱ្យសិទ្ធិជ្រើសរើសនោះទៅម្ចាស់បំណុល ឬ តតិយជន តាមការកំណត់ផ្សេងបាន ។

**មាត្រា ៣២១.–** ការអនុវត្តសិទ្ធិជ្រើសរើស

១-សិទ្ធិជ្រើសរើសត្រូវបានអនុវត្តដោយការជូនដំណឹងទៅភាគីម្ខាងទៀត ។ ក្នុងករណីដែលកូនបំណុលមានសិទ្ធិជ្រើសរើស ការផ្តល់នូវកម្មវត្ថុដែលកូនបំណុលបានជ្រើសរើស ត្រូវចាត់ទុកថា បានអនុវត្តនូវសិទ្ធិជ្រើសរើសនោះ ។ ក្នុងករណីដែលតតិយជនមានសិទ្ធិជ្រើសរើស សិទ្ធិនេះត្រូវបានអនុវត្តដោយការជូនដំណឹងទៅឱ្យកូនបំណុល និង ម្ចាស់បំណុល ។

២-ការជ្រើសរើស ត្រូវមានអានុភាពប្រតិសកម្ម ចាប់តាំងពីពេលដែលកាតព្វកិច្ចបានកើតឡើង ។

**មាត្រា ៣២២.–** ការផ្ទេរសិទ្ធិជ្រើសរើស

១-ក្នុងករណីដែលកាតព្វកិច្ចដល់ពេលកំណត់សង ទោះបីជាកូនបំណុល ឬ ម្ចាស់បំណុលដែលមានសិទ្ធិជ្រើសរើស បានទទួលការដាស់តឿនឱ្យអនុវត្តសិទ្ធិនេះ ក្នុងអំឡុងពេលសមរម្យដែលភាគីម្ខាងទៀតបានកំណត់ក៏ដោយ តែមិនបានជ្រើសរើសក្នុងអំឡុងពេលនោះ សិទ្ធិជ្រើសរើសត្រូវផ្ទេរទៅភាគីម្ខាងទៀត ។

២-ក្នុងករណីដែលតតិយជនមានសិទ្ធិជ្រើសរើស ទោះបីជាតតិយជននោះបានទទួលការដាស់តឿនឱ្យអនុវត្តសិទ្ធិនេះក្នុងអំឡុងពេលសមរម្យដែលកូនបំណុល ឬ ម្ចាស់បំណុលបានកំណត់ក៏ដោយ តែមិនបានជ្រើសរើសក្នុងអំឡុងពេលនោះ សិទ្ធិជ្រើសរើសនោះត្រូវផ្ទេរទៅកូនបំណុលវិញ ។

**មាត្រា ៣២៣.–** ការកំណត់កាតព្វកិច្ចអនិយ័តដោយអលទ្ធភាព

១-ប្រសិនបើការផ្តល់តាវកាលិកណាមួយក្នុងចំណោមតាវកាលិកច្រើនដែលអាចជាកម្មវត្ថុនៃកាតព្វកិច្ចអនិយ័ត មិនអាចប្រព្រឹត្តទៅបានចាប់តាំងពីពេលបង្កើត ឬ ក្រោយពេលបង្កើតកិច្ចសន្យា ដោយគ្មានកំហុសរបស់ភាគី កម្មវត្ថុនៃកាតព្វកិច្ចត្រូវតែជាតាវកាលិកដែលនៅសល់ ។ បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៣២១ (ការអនុវត្តសិទ្ធិជ្រើសរើស) ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីនេះ ។

២-ប្រសិនបើភាគីដែលមានសិទ្ធិជ្រើសរើស មានកំហុសចំពោះអលទ្ធភាពនៃការ

ផ្តល់តាវកាលិក សិទ្ធិជ្រើសរើសត្រូវផ្ទេរទៅភាគីម្ខាងទៀត ។

៣-ប្រសិនបើកូនបំណុលដែលគ្មានសិទ្ធិជ្រើសរើស មានកំហុសចំពោះអលទ្ធភាពនៃការផ្តល់តាវកាលិក អ្នកដែលមានសិទ្ធិជ្រើសរើសអាចជ្រើសរើសតាវកាលិកដែលមិនអាចប្រព្រឹត្តទៅបាននោះ និង អាចទាមទារសំណងនៃការខូចខាត ចំពោះកូនបំណុលនោះបាន ។

៤-ប្រសិនបើម្ចាស់បំណុលដែលគ្មានសិទ្ធិជ្រើសរើស មានកំហុសចំពោះអលទ្ធភាពនៃការផ្តល់តាវកាលិក កូនបំណុលដែលមានសិទ្ធិជ្រើសរើសអាចជ្រើសរើសតាវកាលិកដែលមិនអាចប្រព្រឹត្តទៅបាននោះ និង អាចរួចផុតពីកាតព្វកិច្ចបាន ។

**មាត្រា ៣២៤.–** សិទ្ធិលើបំណុល និង កាតព្វកិច្ចដែលមានភាគីច្រើននាក់

១-ក្នុងករណីដែលមានម្ចាស់បំណុលច្រើននាក់ ចំពោះកាតព្វកិច្ចមួយ ប្រសិនបើគ្មានការបង្ហាញឆន្ទៈផ្សេង ម្ចាស់បំណុលម្នាក់ៗ មានសិទ្ធិ ដោយមានភាគស្មើគ្នា ។

២-ក្នុងករណីដែលការអនុវត្តកាតព្វកិច្ច មិនអាចបែងចែកបាន តាមលក្ខណៈនៃកាតព្វកិច្ចនេះ ឬ ដោយការបង្ហាញឆន្ទៈរបស់ភាគី ប្រសិនបើមានម្ចាស់បំណុលច្រើននាក់ ម្ចាស់បំណុលម្នាក់ៗអាចទាមទារឱ្យអនុវត្ត សម្រាប់ម្ចាស់បំណុលទាំងអស់ ហើយកូនបំណុលអាចអនុវត្តចំពោះម្ចាស់បំណុលម្នាក់ៗ សម្រាប់ម្ចាស់បំណុលទាំងអស់បាន ។

៣-ចំពោះកាតព្វកិច្ចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ សកម្មភាពរបស់ម្ចាស់បំណុលអវិភាគីយ៍ណាម្នាក់ ឬ ហេតុដែលបានកើតឡើងចំពោះម្ចាស់បំណុលអវិភាគីយ៍ណាម្នាក់ មិនត្រូវមានអានុភាពចំពោះម្ចាស់បំណុលអវិភាគីយ៍ផ្សេងទៀតឡើយ ។ ក្នុងករណីដែលកូនបំណុលធ្វើនវកម្មជាមួយម្ចាស់បំណុលអវិភាគីយ៍ណាម្នាក់ ឬ ទទួលការលើកលែងពីម្ចាស់បំណុលអវិភាគីយ៍ណាម្នាក់ ប្រសិនបើកូនបំណុលនោះអនុវត្តកាតព្វកិច្ចទាំងអស់ ឬ មួយភាគ ដោយផ្អែកលើការទាមទាររបស់ម្ចាស់បំណុលអវិភាគីយ៍ផ្សេងទៀត កូនបំណុលអាចទាមទារឱ្យសងមកវិញនូវផលប្រយោជន៍ដែលម្ចាស់បំណុលអវិភាគីយ៍ម្នាក់នោះត្រូវទទួល ប្រសិនបើម្ចាស់បំណុលអវិភាគីយ៍នោះមិនបានបាត់បង់សិទ្ធិរបស់ខ្លួន ។

៤-ចំពោះកាតព្វកិច្ចដោយសាមគ្គីភាព និង ករណីផ្សេងទៀតដែលមានកូនបំណុលច្រើននាក់ ត្រូវអនុលោមតាមបញ្ញត្តិចាប់ពីមាត្រា ៩២១ (អត្ថន័យនៃកាតព្វកិច្ចដោយសាមគ្គីភាព) ដល់មាត្រា ៩៣៧ (កាតព្វកិច្ចអវិភាគីយ៍ និង កាតព្វកិច្ចដែលមានលក្ខណៈប្រហាក់ប្រហែលនឹងកាតព្វកិច្ចដោយសាមគ្គីភាព និង កាតព្វកិច្ចវិភាគីយ៍) ។

## ផ្នែកទី ៣
## លក្ខខណ្ឌ កំណត់ពេល និង អំឡុងពេល

### កថាភាគទី ១
### លក្ខខណ្ឌ

**មាត្រា ៣២៥.–** អត្ថន័យនៃលក្ខខណ្ឌ

១-ភាគីនៃកិច្ចសន្យា អាចដាក់លក្ខខណ្ឌលើការបង្កើត ឬ ការរលត់អានុភាពនៃកិច្ចសន្យានោះ ។ ចំពោះសកម្មភាពឯកតោភាគី ភាគីនោះអាចដាក់លក្ខខណ្ឌបាន លុះត្រាតែមិននាំឱ្យមានការខូចខាតដោយមិនត្រឹមត្រូវដល់ភាគីម្ខាងទៀត ។

២-លក្ខខណ្ឌគឺជាព្រឹត្តិការណ៍ដែលកើតឡើងនាពេលអនាគតហើយដែលមិនទៀងទាត់ ។

៣-ក្នុងករណីដែលដាក់លក្ខខណ្ឌបង្អង់លើកាតព្វកិច្ច ឬ សិទ្ធិដែលកើតឡើងដោយកិច្ចសន្យា ឬ សកម្មភាពឯកតោភាគី អានុភាពនៃកាតព្វកិច្ច ឬ សិទ្ធិនោះ ត្រូវកើតឡើងចាប់តាំងពីពេលដែលលក្ខខណ្ឌបង្អង់នោះត្រូវបានបំពេញ ។ ក្នុងករណីដែលដាក់លក្ខខណ្ឌរំលាយកាតព្វកិច្ច ឬ សិទ្ធិដែលកើតឡើងដោយកិច្ចសន្យា ឬ សកម្មភាពឯកតោភាគី អានុភាពនៃកាតព្វកិច្ច ឬ សិទ្ធិនោះត្រូវរលត់នៅពេលដែលលក្ខខណ្ឌរំលាយនោះត្រូវបានបំពេញ ។

**មាត្រា ៣២៦.–** ការចាត់ចែងសិទ្ធិដែលភ្ជាប់ជាមួយនឹងលក្ខខណ្ឌ

សិទ្ធិដែលភ្ជាប់ជាមួយនឹងលក្ខខណ្ឌ អាចក្លាយជាកម្មវត្ថុនៃសន្តតិកម្ម ឬ ការចាត់

ចែង ឬ ប្រាតិភោគបាន ។ រីឯកាតព្វកិច្ចដែលភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌត្រូវបានបន្តដោយយោងទៅតាមបញ្ញត្តិនៃសន្តតិកម្ម និង បញ្ញត្តិផ្សេងទៀត ។

**មាត្រា ៣២៧.–** ការបំពានសិទ្ធិដែលភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌ

១-ក្នុងករណីដែលមិនទាន់ច្បាស់ថា ល័ក្ខខ័ណ្ឌត្រូវបានបំពេញ ឬ មិនទាន់បានបំពេញ ភាគីនីមួយៗនៃកាតព្វកិច្ចដែលភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌនោះ មិនអាចបំពានផលប្រយោជន៍របស់ភាគីម្ខាងទៀតដែលនឹងកើតឡើងដោយសារល័ក្ខខ័ណ្ឌនោះ ត្រូវបានបំពេញឡើយ ។

២-ក្នុងករណីដែលតតិយជនបានបំពានផលប្រយោជន៍ដែលបានកំណត់នៅកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើអំពើនេះជាអំពើអនីត្យានុកូល តតិយជននោះត្រូវទទួលខុសត្រូវក្នុងការសងការខូចខាត ។

**មាត្រា ៣២៨.–** ការចាត់ទុកថាល័ក្ខខ័ណ្ឌត្រូវបានបំពេញ

ប្រសិនបើភាគីដែលនឹងទទួលការខូចផលប្រយោជន៍ដោយសារល័ក្ខខ័ណ្ឌត្រូវបានបំពេញ ហើយភាគីនោះបានរារាំងមិនឱ្យល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញដោយចេតនា ភាគីម្ខាងទៀតអាចចាត់ទុកថា ល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញរួចហើយ ។

## កថាភាគទី ២
## ការកំណត់ពេល

**មាត្រា ៣២៩.–** អត្ថន័យនៃការកំណត់ពេល

១-ក្នុងករណីដែលមានកំណត់ពេលចាប់ផ្តើម ចំពោះអានុភាពនៃកិច្ចសន្យា អានុភាពនោះមិនត្រូវកើតឡើង រហូតដល់ពេលកំណត់នោះមកដល់ ។ ក្នុងករណីដែលមានកំណត់ពេលចាប់ផ្តើម ចំពោះការអនុវត្តកិច្ចសន្យា ម្ចាស់បំណុលមិនអាចទាមទារឱ្យកូនបំណុលអនុវត្តកាតព្វកិច្ច មុនពេលកំណត់នោះបានឡើយ ។

២-ក្នុងករណីដែលមានកំណត់ពេលចប់ ចំពោះអានុភាពនៃកិច្ចសន្យា អានុភាព

នោះត្រូវរលត់នៅពេលកំណត់នោះមកដល់ ។

៣-ចំពោះសកម្មភាពឯកតោភាគី ភាគីអាចកំណត់ពេលចាប់ផ្ដើមក្នុងន័យនៃកថាខណ្ឌទី ១ ឬ ពេលចប់ក្នុងន័យនៃកថាខណ្ឌទី ២ ខាងលើនេះបាន លុះត្រាតែមិននាំឱ្យមានការខូចខាតដោយមិនត្រឹមត្រូវដល់ភាគីម្ខាងទៀត ។

**មាត្រា ៣៣០.–** ប្រយោជន៍នៃការកំណត់ពេល

១-ការកំណត់ពេល ត្រូវបានសន្មតថា បានជាប្រយោជន៍របស់កូនបំណុល ។

២-ប្រយោជន៍នៃការកំណត់ពេលនេះអាចបោះបង់ចោលបាន លុះត្រាតែមិននាំឱ្យមានការខូចខាតដោយមិនត្រឹមត្រូវ ដល់ភាគីម្ខាងទៀត ។ ប៉ុន្តែ ប្រសិនបើការបោះបង់ចោលនោះធ្វើឱ្យមានការខូចខាតផលប្រយោជន៍របស់ភាគីម្ខាងទៀត ភាគីដែលធ្វើឱ្យមានការខូចខាតនោះ ត្រូវសងការខូចខាតដល់ភាគីម្ខាងទៀត ។

**មាត្រា ៣៣១.–** ការបាត់បង់ផលប្រយោជន៍នៃការកំណត់ពេល

កូនបំណុលត្រូវបាត់បង់ផលប្រយោជន៍នៃការកំណត់ពេល ក្នុងករណីដូចតទៅ :

ក-កូនបំណុលត្រូវបានប្រកាសក្ស័យធន ។

ខ-កូនបំណុលបានធ្វើឱ្យខូចខាតប្រាតិភោគ ។

គ-កូនបំណុលមានករណីយកិច្ចត្រូវដាក់ប្រាតិភោគ ប៉ុន្តែ មិនបានបំពេញករណីយកិច្ចនេះ ។

ឃ-មានហេតុដែលគូភាគីបានព្រមព្រៀងគ្នា បានកើតឡើង ។

## កថាភាគទី ៣

## អំឡុងពេល

**មាត្រា ៣៣២.–** របៀបកំណត់អំឡុងពេល

អំឡុងពេលអាចកំណត់ជា ម៉ោង នាទី វិនាទី ថ្ងៃ សប្ដាហ៍ ខែ ឬ ឆ្នាំបាន ។

**មាត្រា ៣៣៣.–** ការគណនាអំឡុងពេលជាម៉ោង នាទី ឬវិនាទី

ប្រសិនបើបានកំណត់អំឡុងពេលជាម៉ោង នាទី ឬវិនាទី ត្រូវធ្វើការគណនាពីពេលចាប់ផ្ដើមរហូតដល់ពេលចប់នៃអំឡុងពេលនោះ ។

**មាត្រា ៣៣៤.–** ការគណនាអំឡុងពេលជាថ្ងៃ សប្ដាហ៍ ខែ ឬឆ្នាំ

១-ប្រសិនបើបានកំណត់អំឡុងពេលជាថ្ងៃ សប្ដាហ៍ ខែ ឬ ឆ្នាំវិញ មិនត្រូវគិតបញ្ចូលថ្ងៃដែលចាប់ផ្ដើមនៃអំឡុងពេលនេះទេ លើកលែងតែអំឡុងពេលនេះបានចាប់ផ្ដើមពីម៉ោងសូន្យទៅ ។

២-ក្នុងករណីដែលបានកំណត់នៅកថាខណ្ឌទី ១ ខាងលើនេះ អំឡុងពេលត្រូវចប់ពេញលេញនៅពេលផុតថ្ងៃចុងក្រោយនៃអំឡុងពេលនោះ ។

៣-ប្រសិនបើថ្ងៃចុងក្រោយនៃអំឡុងពេលត្រូវជាថ្ងៃបុណ្យ ថ្ងៃអាទិត្យ ឬ ថ្ងៃឈប់សម្រាកផ្សេងទៀតដែលច្បាប់ ឬ បទដ្ឋានគតិយុត្តបានកំណត់ អំឡុងពេលត្រូវចប់ពេញលេញនៅពេលផុតថ្ងៃធ្វើការបន្ទាប់ពីថ្ងៃឈប់នោះ ។

**មាត្រា ៣៣៥.–** ការគណនាអំឡុងពេលតាមប្រតិទិនសុរិយគតិ

១-ក្នុងករណីដែលធ្វើការគណនាអំឡុងពេលជាសប្ដាហ៍ ខែ ឬ ឆ្នាំ ត្រូវធ្វើការគណនាតាមប្រតិទិនសុរិយគតិ ។

២-ក្នុងករណីដែលមិនធ្វើការគណនាអំឡុងពេលដោយគិតពីដើមសប្ដាហ៍ ដើមខែ ឬ ដើមឆ្នាំទេ អំឡុងពេលនេះត្រូវចប់ពេញលេញនៅមួយថ្ងៃមុនថ្ងៃដែលត្រូវនឹងថ្ងៃចាប់ផ្ដើមរាប់នៃសប្ដាហ៍ចុងក្រោយ ខែចុងក្រោយ ឬ ឆ្នាំចុងក្រោយនៃអំឡុងពេល ។ ប៉ុន្តែ ក្នុងករណីដែលត្រូវគណនាអំឡុងពេលជាខែ ឬ ជាឆ្នាំវិញ ប្រសិនបើខែ ឬ ឆ្នាំចុងក្រោយនៃអំឡុងពេលនោះ គ្មានថ្ងៃដែលត្រូវនឹងថ្ងៃដែលអំឡុងពេលបានចាប់ផ្ដើមទេ ថ្ងៃចុងក្រោយនៃខែនោះ ត្រូវជាថ្ងៃដែលអំឡុងពេលត្រូវចប់ពេញលេញ ។

## ជំពូកទី ២
## ការបង្ហាញឆន្ទៈ និង កិច្ចសន្យា

### ផ្នែកទី ១
### ការបង្កើតកិច្ចសន្យា

**មាត្រា ៣៣៦.–** ការបង្កើតកិច្ចសន្យាដោយសំណើ និង ស្ទីការ

១-កិច្ចសន្យាមានអានុភាពដោយសារសំណើ និង ស្ទីការត្រូវគ្នា ។

២-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ក៏កិច្ចសន្យាដែលភាគីម្ខាងទទួលករណីយកិច្ចធ្វើអនុប្បទាននូវកម្មសិទ្ធិលើអចលនវត្ថុ ឬ ករណីយកិច្ចធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុ នឹងមានអានុភាព លុះត្រាតែបានធ្វើលិខិតយថាភូត ។

**មាត្រា ៣៣៧.–** និយមន័យនៃសំណើ និង ស្ទីការ

១-សំណើគឺជាការសុំបង្កើតកិច្ចសន្យាដែលធ្វើឡើងដោយមានឆន្ទៈភ្ជាប់ខ្លួនជាមួយនឹងចំណងគតិយុត្តក្នុងករណីដែលមានស្ទីការរបស់ភាគីម្ខាងទៀតចំពោះសំណើនេះ ។

២-សំណើត្រូវមានអានុភាពនៅពេលដែលសំណើនោះបានដល់ភាគីម្ខាងទៀត ។ ប៉ុន្តែ ប្រសិនបើដំណឹងអំពីការដកសំណើវិញ ដល់ភាគីម្ខាងទៀត នៅពេលព្រមគ្នានឹងពេលសំណើដល់ ឬ មុនពេលសំណើដល់ នោះអានុភាពសំណើមិនត្រូវកើតឡើយ ។

៣-ស្ទីការគឺជាការបង្ហាញឆន្ទៈដែលអ្នកទទួលសំណើយល់ព្រមចំពោះសំណើនោះ ។

៤-ស្ទីការត្រូវមានអានុភាពនៅពេលដែលស្ទីការនោះបានដល់អ្នកស្នើ ។ ប៉ុន្តែ ប្រសិនបើដំណឹងអំពីការដកស្ទីការវិញ ដល់អ្នកស្នើ នៅពេលព្រមគ្នានឹងពេលស្ទីការដល់ ឬ មុនពេលស្ទីការដល់ នោះអានុភាពនៃស្ទីការ មិនត្រូវកើតឡើយ ។

**មាត្រា ៣៣៨.–** សំណើដែលមានកំណត់អំឡុងពេលសម្រាប់ស្ទីការ និង ការដកសំណើនោះ

១-សំណើអាចធ្វើឡើងបានដោយកំណត់អំឡុងពេលសម្រាប់ស្ទីការ ។ អំឡុងពេល

សម្រាប់ស្ទីការ ត្រូវគិតចាប់ពីថ្ងៃដែលជូនដំណឹងអំពីសំណើ បើមិនច្បាស់ថា អ្នកស្នើកំណត់ពេលផ្សេង ។

២-សំណើដែលត្រូវបានធ្វើឡើងដោយមានកំណត់អំឡុងពេលសម្រាប់ស្ទីការ មិនអាចដកវិញបានទេ ។

៣-ប្រសិនបើអ្នកស្នើមិនបានទទួលដំណឹងអំពីស្ទីការ ក្នុងអំឡុងពេលដែលបានកំណត់នៅកថាខណ្ឌទី ១ ខាងលើនេះទេ សំណើនោះត្រូវបាត់បង់អានុភាពដោយស្វ័យប្រវត្តិនៅពេលផុតអំឡុងពេលសម្រាប់ស្ទីការ ។ ក្នុងករណីដែលដំណឹងអំពីការបដិសេធសំណើបានដល់អ្នកស្នើក្នុងអំឡុងពេលសម្រាប់ស្ទីការនោះ សំណើនោះក៏ត្រូវបាត់បង់អានុភាពដែរ ។

**មាត្រា ៣៣៩.–** សំណើដែលគ្មានកំណត់អំឡុងពេលសម្រាប់ស្ទីការ និង ការដកសំណើនោះ

១-ចំពោះសំណើដែលត្រូវបានធ្វើឡើងដោយគ្មានកំណត់អំឡុងពេលសម្រាប់ស្ទីការរវាងគូភាគីដែលកំពុងនិយាយគ្នា នៅក្នុងស្ថានភាពដែលអាចឆ្លើយភ្លាមៗបាន ប្រសិនបើភាគីដែលទទួលសំណើមិនបានយល់ព្រមភ្លាមៗទេ សំណើនោះត្រូវបាត់បង់អានុភាព ។

២-ចំពោះសំណើដែលធ្វើរវាងគូភាគីដែលមិននិយាយគ្នា ដោយគ្មានកំណត់អំឡុងពេលសម្រាប់ស្ទីការទេ អ្នកស្នើមិនអាចដកសំណើនោះវិញក្នុងអំឡុងពេលសមរម្យបានឡើយ ។

៣-ការដកសំណើត្រូវមានអានុភាព លុះត្រាតែការជូនដំណឹងអំពីការដកសំណើនោះបានមកដល់ភាគីម្ខាងទៀត មុនពេលភាគីម្ខាងទៀតជូនដំណឹងអំពីស្ទីការ ។

**មាត្រា ៣៤០.–** ពេលនៃការបង្កើតកិច្ចសន្យា : គោលការណ៍នៃការមកដល់នៃស្ទីការ

កិច្ចសន្យាត្រូវកើតឡើងនៅពេលដែលដំណឹងអំពីស្ទីការបានមកដល់អ្នកស្នើ ។

**មាត្រា ៣៤១.–** ការមកដល់យឺតយ៉ាវនៃស្ទីការ

១-ក្នុងករណីដែលការជូនដំណឹងអំពីស្ទីការ ចំពោះសំណើដែលមានអំឡុងពេល

សម្រាប់ស្ទីការ មកដល់ភាគីម្ខាងទៀត ក្រោយពេលអំឡុងពេលសម្រាប់ស្ទីការនោះកន្លងផុត ប្រសិនបើអ្នកស្នើស្ថិតនៅក្នុងស្ថានភាពដែលអាចដឹងថា ភាគីម្ខាងទៀតជូនដំណឹងអំពីស្ទីការនោះ នៅពេលដែលអាចមកដល់ក្នុងអំឡុងពេលសម្រាប់ស្ទីការក្នុងករណីធម្មតា នោះអ្នកស្នើត្រូវជូនដំណឹងអំពីការមកដល់ស្ទីការដោយមានការយឺតយ៉ាវនោះ ទៅអ្នកធ្វើស្ទីការ ដោយគ្មានការយឺតយ៉ាវ ។ ក្នុងករណីដែលអ្នកស្នើធ្វេសប្រហែសក្នុងការជូនដំណឹងអំពីការមកដល់ស្ទីការដោយមានការយឺតយ៉ាវនោះ ស្ទីការដែលមកដល់ដោយមានការយឺតយ៉ាវនោះ មានសុពលភាព ។

២-អ្នកស្នើ អាចចាត់ទុកថា ស្ទីការដែលបានមកដល់អ្នកស្នើក្រោយពេលផុតអំឡុងពេលសម្រាប់ស្ទីការ ជាសំណើថ្មី ។

**មាត្រា ៣៤២.–** ស្ទីការដោយមានបន្ថែមការកែប្រែ

១-ស្ទីការដែលអ្នកធ្វើស្ទីការបានដាក់ល័ក្ខខ័ណ្ឌលើសំណើ ឬ កែប្រែសារធាតុផ្សេងនៃសំណើ មិនត្រូវក្លាយជាស្ទីការសុពល តែស្ទីការនោះមានអានុភាពជាសំណើថ្មី ។ កិច្ចសន្យាត្រូវកើតឡើងនៅពេលដែលអ្នកធ្វើសំណើដើម ធ្វើស្ទីការចំពោះសំណើថ្មីនោះ ។

២-ប្រសិនបើល័ក្ខខ័ណ្ឌ ឬ ការកែប្រែដែលភ្ជាប់ជាមួយនឹងស្ទីការមិនធ្វើឱ្យមានការកែប្រែសារធាតុនៃសំណើទេ ស្ទីការនោះមានសុពលភាព លុះត្រាតែអ្នកស្នើមិនតវ៉ាភ្លាម ។ អត្ថន័យនៃកិច្ចសន្យាដែលត្រូវកើតឡើងដោយស្ទីការនោះ ត្រូវទៅតាមអត្ថន័យនៃស្ទីការ លុះត្រាតែអ្នកស្នើដែលបានទទួលស្ទីការមិនតវ៉ាភ្លាមៗទេ ។

**មាត្រា ៣៤៣.–** ការបង្កើតកិច្ចសន្យាដោយសកម្មភាពដែលត្រូវបានចាត់ទុកថាជាស្ទីការ

ក្នុងករណីដែលមិនចាំបាច់ឱ្យមានដំណឹងអំពីស្ទីការ ដោយសារឆន្ទៈរបស់អ្នកស្នើ ឬ ដោយសារទំនៀមទម្លាប់នៃកិច្ចការជំនួញ កិច្ចសន្យាត្រូវកើតឡើងនៅពេលដែលមានសកម្មភាពអាចទទួលស្គាល់ថាជាស្ទីការ ។

**មាត្រា ៣៤៤.–** ការដកសំណើចំពោះបុគ្គលដែលមិនបានកំណត់ជាក់លាក់

សំណើចំពោះបុគ្គលដែលមិនបានកំណត់ជាក់លាក់តាមការផ្សាយជាសាធារណៈ

ឬ តាមវិធីផ្សេងទៀត អាចដកបានតែតាមវិធីដូចគ្នានឹងសំណើនោះ ។

## ផ្នែកទី ២

## វិការៈក្នុងការបង្ហាញឆន្ទៈ និង សុពលភាពនៃកិច្ចសន្យា

**មាត្រា ៣៤៥.–** ការបង្ហាញឆន្ទៈដែលមានវិការៈ

អ្នកដែលបង្ហាញឆន្ទៈអាចលុបចោលកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ តាមបញ្ញត្តិនៃផ្នែកទី ២ (វិការៈក្នុងការបង្ហាញឆន្ទៈ និង សុពលភាពនៃកិច្ចសន្យា) នេះ និង ផ្នែកទី ៣ (មោឃភាព និង ការលុបចោល) ក្នុងករណីដូចខាងក្រោមនេះ :

ក-ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយការភាន់ច្រឡំ ។

ខ-ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយការឆបោក ឬ ការគម្រាមកំហែង ឬ ការបង្ហាញការមិនពិតរបស់ភាគីម្ខាងទៀត ។

គ-ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយអំពើឆ្លៀតឱកាសដោយមានគោលបំណងកេងយកចំណេញហួសហេតុ ។

**មាត្រា ៣៤៦.–** ការភាន់ច្រឡំ

១-ក្នុងករណីដែលភាគីមានការភាន់ច្រឡំអំពីចំណុចសំខាន់ៗនៃកិច្ចសន្យា បើភាគីម្ខាងទៀតបានស្ថិតនៅក្នុងស្ថានភាពដែលអាចដឹងអំពីការភាន់ច្រឡំនេះ ភាគីដែលបានភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

២-ក្នុងករណីដែលភាគីម្ខាងនៃកិច្ចសន្យា មានការភាន់ច្រឡំអំពីចំណុចនៃកិច្ចសន្យាដែលខ្លួនយល់ឃើញថាសំខាន់ ឬ ចំណុចដែលខ្លួនយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា បើភាគីម្ខាងទៀតបានស្ថិតនៅក្នុងស្ថានភាពដែលអាចដឹងអំពីភាពសំខាន់នៃចំណុចនេះ និង ការភាន់ច្រឡំរបស់អ្នកបង្ហាញឆន្ទៈនោះ ភាគីដែលបានភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

៣-ក្នុងករណីដែលភាគីទាំងសងខាងមានការភាន់ច្រឡំអំពីចំណុចសំខាន់ៗនៃកិច្ចសន្យា ឬ ចំណុចនៃកិច្ចសន្យាដែលភាគីទាំងសងខាងយល់ឃើញថាសំខាន់ ឬ ចំណុចដែលភាគីទាំងសងខាងយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា ទោះបីជាភាគីម្ខាងមិនមានលទ្ធភាពអាចដឹងអំពីការភាន់ច្រឡំរបស់ភាគីម្ខាងទៀតក៏ដោយ ក៏ភាគីដែលបានភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបានដែរ ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

៤-ការលុបចោលនូវកិច្ចសន្យាដោយការភាន់ច្រឡំ ក្រៅពីភាគីម្ខាងទៀត អាចអះអាងចំពោះតតិយជនបាន ។ ប៉ុន្តែ ប្រសិនបើតតិយជនជាជនសុចរិត ហើយគ្មានកំហុសអំពីការភាន់ច្រឡំ មិនអាចអះអាងនូវការលុបចោលចំពោះតតិយជននោះបានឡើយ ។

**មាត្រា ៣៤៧.–** ការឆបោក

១-បុគ្គលដែលបានធ្វើការបង្ហាញឆន្ទៈ ដោយសារការឆបោករបស់ភាគីម្ខាងទៀត អាចលុបចោលនូវកិច្ចសន្យា ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

២-ក្នុងករណីដែលការបង្ហាញឆន្ទៈបានធ្វើឡើងដោយសារការឆបោករបស់តតិយជន អ្នកបង្ហាញឆន្ទៈអាចលុបចោលនូវកិច្ចសន្យា ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ លុះត្រាតែក្នុងករណីដែលភាគីម្ខាងទៀតនៃការបង្ហាញឆន្ទៈនោះ បានដឹង ឬ អាចដឹងអំពីការឆបោកនោះ ។

៣-ការលុបចោលនូវកិច្ចសន្យាដោយការឆបោក ក្រៅពីភាគីម្ខាងទៀត អាចអះអាងចំពោះតតិយជនបាន ។ ប៉ុន្តែ ប្រសិនបើតតិយជនជាជនសុចរិត ហើយគ្មានកំហុសអំពីការឆបោក មិនអាចអះអាងនូវអានុភាពនៃការលុបចោលចំពោះតតិយជននោះបានឡើយ ។

**មាត្រា ៣៤៨.–** ព័ត៌មានមិនពិត

១-នៅពេលធ្វើកិច្ចសន្យា បើហេតុដែលបានបង្ហាញដោយភាគីម្ខាងនោះខុសពីការពិត ហើយភាគីម្ខាងទៀតបានបង្ហាញឆន្ទៈដោយជឿជាក់ថា ហេតុទាំងនោះជាការពិត ប៉ុន្តែ ប្រសិនបើភាគីនោះដឹងថា ហេតុនោះមិនមែនជាការពិត ខ្លួននឹងមិនបង្ហាញឆន្ទៈទេ ភាគីនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមាន

វិការៈ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនរារាំងភាគីដែលបានបង្ហាញឆន្ទៈក្នុងការទាមទារសំណងនៃការខូចខាតពីបុគ្គលដែលបានបង្ហាញការណ៍មិនពិតនោះទេ ក្នុងករណីដែលបុគ្គលនេះមានកំហុស ។

៣-ការលុបចោលនូវកិច្ចសន្យាដោយព័ត៌មានមិនពិត ក្រៅពីភាគីម្ខាងទៀត អាចអះអាងចំពោះតតិយជនបាន ។ ប៉ុន្តែ ប្រសិនបើតតិយជនជាជនសុចរិត ហើយគ្មានកំហុសអំពីព័ត៌មានមិនពិត មិនអាចអះអាងនូវអានុភាពនៃការលុបចោល ចំពោះតតិយជននោះបានឡើយ ។

**មាត្រា ៣៤៩.–** ការរំលោភបំពានលើស្ថានភាព

១-នៅពេលធ្វើកិច្ចសន្យា បើភាគីម្ខាងនៃកិច្ចសន្យាបានប្រើឋានៈខ្លួនដែលមានអាទិភាពជាងភាគីម្ខាងទៀត ខាងផ្នែកសេដ្ឋកិច្ច ឬ ផ្នែកសង្គម ឬ បានប្រើស្ថានភាពផ្សេងទៀតដែលភាគីម្ខាងទៀតមិនអាចប្រឆាំងតបបានទេ ភាគីម្ខាងទៀតនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

២-ការលុបចោលនូវកិច្ចសន្យាដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនអាចអះអាងចំពោះតតិយជនដែលជាជនសុចរិត ហើយគ្មានកំហុសអំពីការរំលោភបំពានលើស្ថានភាពបានឡើយ ។

**មាត្រា ៣៥០.–** ការគម្រាមកំហែង

បុគ្គលដែលបានបង្ហាញឆន្ទៈដោយសារមានការគម្រាមកំហែងពីសំណាក់ភាគីម្ខាងទៀត ឬ ពីសំណាក់តតិយជន អាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

**មាត្រា ៣៥១.–** អំពើកេងយកចំណេញហួសហេតុ

ក្នុងករណីដែលភាគីម្ខាងបានធ្វើកិច្ចសន្យា ដោយឆ្លៀតឱកាសដែលភាគីម្ខាងទៀតកំពុងជួបប្រទះការលំបាកខាងផ្នែកសេដ្ឋកិច្ច ឬ ភាពល្ងង់ ឬ ការខ្វះការពិសោធន៍ ហើយ

បានកេងយកចំណេញយ៉ាងសន្ធឹកសន្ធាប់ពីកិច្ចសន្យានោះ ភាគីម្ខាងទៀតនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

**មាត្រា ៣៥២.–** ថបនីយផ្លូវចិត្ត

ប្រសិនបើកិច្ចសន្យាត្រូវបានបង្កើតឡើង ដោយការបង្ហាញឆន្ទៈដែលភាគីដឹងខ្លួនថាខុសឆន្ទៈពិតរបស់ខ្លួន កិច្ចសន្យានោះមិនត្រូវរារាំងនូវអានុភាពឡើយ ។ ប៉ុន្តែ ក្នុងករណីដែលភាគីម្ខាងទៀតក៏ដឹងថាការបង្ហាញឆន្ទៈនោះ ខុសនឹងឆន្ទៈពិតរបស់អ្នកបង្ហាញឆន្ទៈដែរ អ្នកបង្ហាញឆន្ទៈនោះអាចបដិសេធការអនុវត្តកិច្ចសន្យាបាន ។

**មាត្រា ៣៥៣.–** ការបង្ហាញឆន្ទៈមិនពិត

១-កិច្ចសន្យា ដោយផ្អែកលើការបង្ហាញឆន្ទៈមិនពិតដែលត្រូវបានធ្វើឡើង ដោយមានការឃុបឃិតជាមួយនឹងភាគីម្ខាងទៀត ត្រូវចាត់ទុកជាមោឃៈ ។

២-មោឃភាពនៃកិច្ចសន្យាដែលបានកំណត់នៅកថាខណ្ឌទី ១ ខាងលើនេះ មិនអាចអះអាងចំពោះតតិយជនដែលមានទំនាក់ទំនងផលប្រយោជន៍ ដោយយកកិច្ចសន្យាដែលផ្អែកលើការបង្ហាញឆន្ទៈមិនពិតជាមូលដ្ឋានបានឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលតតិយជននោះជាជនទុច្ចរិត ឬ មិនបានដឹងអំពីការបង្ហាញនូវឆន្ទៈមិនពិតដោយមានកំហុសធ្ងន់ធ្ងរ ។